ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទើបទទួលបាន
- ទឹកភ្នែកមួយដំណក់របស់ម្ដាយខ្ញុំ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៤០ ខែធ្នូ ឆ្នាំ២០១៩

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត

លេខ២៤០ ខែធ្នូ ឆ្នាំ២០១៩


## មាតិកា


**សំបុត្រ**

◆ ឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជា..............................១

**ផ្នែកឯកសារ**

◆ ប៊ិន បាន ហៅ បូ លេខាស្រុក........................................... ៤

**ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ**

◆ រៀបការដោយមិនបានត្រៀមខ្លួន........................................ ៧

◆ ខ្ញុំដឹងថាសង្គ្រាមនឹងកើតមាន ............................................. ៩

◆ ៤០ឆ្នាំក្រោយមក ...........................................................១១

◆ ទឹកភ្នែកមួយដំណក់របស់ម្ដាយ.........................................១៣

◆ គម្រោងប្រកួតជ្រើសរើសស្នាដៃ... ......................................៣០

**ផ្នែកច្បាប់**

◆ សាលក្រមសំណុំរឿង០០២/០២.......................................៣២

**វេទិកាពិភាក្សាសាធារណៈ**

◆ ភាពយន្តឯកសារឆ្នាំព្រៃ ................................................. ៣៦

**ទំព័រស្រាវជ្រាវរកក្រួសារ**

◆ ប៉ុត ជួន ..........................................................................៣៩

◆ តាំង ហាងម៉េង...................................................................៤៧

◆ អ៊ុម ស្បោង.......................................................................៤៩

◆ រូបថតពីវាលពិឃាតនៃដំរីស្រះកែវ.....................................៥១

◆ ប្រវត្តិរូប អ៊ឹង ជុយ ...........................................................៥៣

◆ បញ្ជីឈ្មោះអ្នកដែលបានស្លាប់.........................................៥៥





**ចាន់ គឹម ហៅ សាង និង កូនប្រុស**


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម,៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា


***ស្នេរលេខនេះ៖*** *ដាត ចាន់សុនិតា,ដារ៉ារដ្ឋ មេត្តា,ហូ ថុនា, សោម ប៊ុនថន, អ៊ុន សុដាវី, សួត្រ វិចិត្រ , ឡុង ដានី , វ៉ាន់ថាន់ ពៅដារ៉ា* ***អ្នកនិពន្ធនិងស្រាវជ្រាវ៖*** *ហូ ថុនា,ដារ៉ារដ្ឋ មេត្តា, អ៊ុន សុដាវី* ***អ្នកបកប្រែ៖*** *អ៊ុន សុដាវី* ***និពន្ធនាយកទូទៅ៖*** *សោម ប៊ុនថន* ***ជំនួយការនិពន្ធនាយក៖*** *ហូ ថុនា* ***ក្រាហ្វិកកុំព្យូទ័រ៖*** *ដាត ចាន់សុនិតា* ***គ្រប់គ្រងការចែកផ្សាយ៖*** *ឆេង វ៉េង*



**Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org**

# ឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទើបទទួលបាន

មជ្ឈមណ្ឌលឯកសារកម្ពុជាមានសេចក្តីសោមនស្ស ប្រកាសជូនដាដំណឹងថាយើងខ្ញុំ បានទទួលអំណោយជាបណ្ណសារដ៏វិសេសវិសាលពីលោកអគ្គរាជទូត ហ្វូលីយ៉ូ អេ.ហេលផ្ទ្រែស អតីតរាជលេខាផ្ទាល់និង អ្នកសរសេរជីវប្រវត្តិរបស់អតីតព្រះមហាវីរក្សត្រ ព្រះបាទនរោត្តម សីហនុ នៃព្រះរាជាណាចក្រកម្ពុជា, អ្នកស្រាវជ្រាវជាន់ខ្ពស់នៃវិទ្យាស្ថានសិក្សាអំពីទស្សនវិជ្ជាប្រវត្តិសាស្ត្រ និងអន្តរជាតិនៃសាកលវិទ្យាល័យម៉ូណាស និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់នៃវិទ្យាស្ថានស្លឹករឹត/មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងរាជធានីភ្នំពេញ។

បណ្ណសារជាអំណោយនេះរួមមានឯកសារផ្ទាល់ខ្លួនរបស់អគ្គរាជទូត ហេលផ្ទ្រែស ស្តីអំពីប្រទេសកម្ពុជាប្រទេសចិននិងតំបន់អាស៊ីអាគ្នេយ៍ ដែលត្រូវបានចងក្រងតាមរយៈការងារស្រាវជ្រាវក្នុងរយៈពេលជាង៤០ឆ្នាំកន្លងមក។ ឯកសារទាំងនេះរួមបញ្ចូលនូវសៀវភៅប្រើប្រាស់រួច,CDs,PictureFrames និងResearchPapers ស្តីពីប្រវត្តិសាស្ត្រកម្ពុជាសហសម័យរាប់រយពាន់ឯកសារ ដែលប្រមែប្រមូលមកពីប្រទេសអូស្ត្រាលី ប្រទេសអង់គ្លេស ប្រទេសកាណាដា ប្រទេសបារាំង ប្រទេសន័រវែស ប្រទេសស៊ុយអែត និងប្រទេសស្វីស។សរុបមកបណ្ណសារនេះរួមផ្សំនូវឯកសារនិងសម្ភារប្រវត្តិសាស្ត្រដ៏មានតម្លៃ ដែលមានទម្ងន់ប្រមាណ១តោននិង៥៨០គីឡូក្រាម។

ឆ្លើយតបទៅនឹងអំណោយនេះ នាយកមជ្ឈមណ្ឌល



*សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ, អតីតអគ្គរាជទូត ហ្វូលីយ៉ូ អេ.ហេលផ្ទ្រែស និង លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា*

ឯកសារកម្ពុជាគឺលោកឆាំង យុ បានលើកឡើងថា «ការចងក្រងឯកសារគឺបម្រើដល់គោលបំណងក្នុងការរក្សាតម្លាភាព និងការដាក់ឲ្យ ទទួលខុសត្រូវ ដោយសារមូលហេតុនេះយើងមិនត្រឹមតែត្រូវ ទទួលស្គាល់ អំណោយនេះ ជាការចូលរួមចំណែកនៅក្នុងការអប់រំនិង ការសិក្សា ស្រាវជ្រាវរបស់កម្ពុជាតែប៉ុណ្ណោះទេក៏ ប៉ុន្តែគឺជា ការចូលរួមចំណែកនៅក្នុងលទ្ធិប្រជាធិបតេយ្យ និងវប្បធម៌ដែលមានប្រជាជនជាអ្នកដឹកនាំ»។

មជ្ឈមណ្ឌលឯកសារកម្ពុជា នឹង ធ្វើឲ្យឯកសារជាអំណោយនេះទៅជាឯកសារឌីជីថល និងតម្កល់ច្បាប់ចម្លងនៃឯកសារទាំងនេះនៅបណ្ណាល័យ/ មជ្ឈមណ្ឌលស្រាវជ្រាវតាមបណ្ដាខេត្តទាំង៦ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជា កំពុងធ្វើប្រតិប ត្តិការដោយមានការរួមសហការ ជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។ គោលបំណងនៃបណ្ណាល័យនិងមជ្ឈមណ្ឌលស្រាវជ្រាវទាំង៦គឺដើម្បីបង្កើនប្រសិទ្ធភាព ក្នុងការបង្រៀន អំពីប្រវត្តិសាស្ត្រកម្ពុជាសហសម័យ ជាពិសេសប្រវត្តិសាស្ត្រ នៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យប៉ុលពត។

បន្ថែមទៅលើអំណោយនេះក្រោមកិច្ចសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាអគ្គរាជទូតហេលជ្រែសបាន បោះពុម្ពសៀវភៅសំខាន់ៗ មួយចំនួនថែមទៀតផង។ រួមសហការជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជាអគ្គរាជទូតហេលជ្រែស បានបញ្ចប់សៀវភៅមួយក្បាលស្ដីពីប្រវត្តិសាស្ត្រនៃមិត្តភាពរវាង អតីតព្រះមហាវីរក្សត្រ ព្រះបាទនរោត្តមសីហនុនៃព្រះរាជាណាចក្រកម្ពុជា និងប្រធានាធិបតីជូអេនឡាយនៃ សាធារណរដ្ឋប្រជាមានិតចិន និងបញ្ចប់ការបកប្រែសៀវភៅកំណត់ហេតុ របស់សម្តេចព្រះមហាក្សត្រិយ៍នរោត្តមមុនិនាថសីហនុ ដែលទ្រង់លិខិតនៅក្នុងអំឡុងព្រះរាជដំណើរទៅកាន់តំបន់រំដោះ ក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៧៣។បច្ចុប្បន្នអគ្គរាជទូតហេលជ្រែសកំពុងធ្វើការស្រាវជ្រាវសៀវភៅមួយក្បាល ស្ដីពីរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា (១៩៧០-១៩៧៦)។

មជ្ឈមណ្ឌលឯកសារកម្ពុជា មានការដឹងគុណយ៉ាងពន់ពេកនិងមានកិត្តិយសក្រៃលែង ចំពោះអំណោយដ៏សប្បុរសរបស់អគ្គរាជទូតហេលជ្រែស ដែលនឹងចូលរួមចំណែកនៅក្នុងការអប់រំយុវជន- យុវនារីកម្ពុជាអ្នកស្រាវជ្រាវនិងសាធារណជន។ មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណដល់ក្រសួងអប់រំយុវជននិងកីឡា ដែលបានគាំទ្រនិងជួយសម្រួលដល់ការផ្ទេរឯកសារទាំងនេះមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា។

គម្រោងចងក្រងឯកសារ និងលទ្ធិប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានជំនួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីក្រសួងការបរទេសសហរដ្ឋអាមេរិករួមជាមួយនឹងការគាំទ្រចម្បងពីទីភ្នាក់ងារ សហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**



ឯកសារប្រវត្តិសាស្ត្រប្រទេសកម្ពុជា ដែលដឹកជញ្ជូនមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ<br>របស់មជ្ឈមណ្ឌលឯកសារកម្ពុជា







បញ្ចាំងរៀងរាល់ថ្ងៃសុក្រ
វេលាម៉ោង១០:០០ ព្រឹក
ទីតាំងនៅវិចិត្រសាលសិល្បៈ
សហសម័យវិទ្យាស្ថានស្លឹករឹត
វិឡាលេខ១០, ផ្លូវ២៥៦ ភូមិ៣
សង្កាត់ចតុមុខ ខណ្ឌដូនពេញ
រាជធានី ភ្នំពេញ។










វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត ដែលមានទីតាំងស្ថិតនៅវិឡាលេខ១០, ផ្លូវ២៥៦, ភ្នំពេញ ជាទីតាំងមួយដើរតួនាទីជាកន្លែងអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រ និងកេរដំណែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែងដែលដាក់បង្ហាញពីស្នាដៃសិល្បៈ និងវប្បធម៌តាមរយៈការតាំងពិព័រណ៍ ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងការធ្វើបទបង្ហាញរបស់វាគ្មិននានា។ ជារួម វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត រួមចំណែកដល់ការលើកកម្ពស់ និងគាំទ្រដល់វិចិត្រករកម្ពុជាទាំងអស់ ដោយផ្តល់ជូននូវបរិវេណខាងក្នុងបន្ទប់ធំសម្រាប់ការដាក់តាំងពិព័រណ៍អំពីកិច្ចការសិល្បៈរបស់ខ្លួន។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង ស៊ាន ចិន្តា ទូរសព្ទលេខ ០២៣ ២១១ ៨៧៥ អ៊ីម៉ែល truthchenda.s@dccam.org

# ប៊ិន បាន ហៅ ប៊ូ លេខាស្រុកពាមជីលាំង តំបន់២១ ភូមិភាគបូព៌ា

ខ្ញុំ ឈ្មោះប៊ិនបានហៅប៊ូអាយុ៣៨ឆ្នាំ នៅឆ្នាំ១៩៧៧។ ខ្ញុំមានស្រុក កំណើតនៅឃុំបឹស ស្រុកពាមជីលាំង តំបន់២១ ភូមិភាគបូព៌ា។ នៅឆ្នាំ១៩៦៧ ខ្ញុំបានសឹកពីព្រះសង្ឃមកនៅផ្ទះជួយធ្វើស្រែឪពុកម្តាយ។ ថ្ងៃមួយនៅពេលខ្ញុំកំពុងភ្ជួរស្រែ អ្នកជិតខាងរបស់ខ្ញុំឈ្មោះ លឹម បានមកសួរនាំអំពីជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្ញុំ។ ខ្ញុំក៏បានប្រាប់ទៅ លឹម ថាជីវភាពរស់នៅរបស់ខ្ញុំមានការខ្វះខាតណាស់។ ព្ទដូច្នេះ លឹម ក៏បានបញ្ចុះបញ្ចូលខ្ញុំឲ្យធ្វើជាគិញស៊ើបការណ៍អំពីបដិវត្តន៍ ដោយឲ្យប្រាក់ខែខ្ញុំ៣០០រៀលក្នុងមួយខែ។ មួយឆ្នាំក្រោយមក ខ្ញុំបានទាក់ទងជាមួយចៅហ្វាយស្រុកក្រូចឆ្មារ ឈ្មោះ វ៉ង់ ម៉េង ហើយខ្ញុំបានឡើងធ្វើជាមេឃុំបឹសក្នុងឆ្នាំ១៩៧០។ ចាប់តាំងពីខ្ញុំធ្វើជាមេឃុំនៅបឹសមកបង ឆោម សាវ៉ាត លេខាស្រុកឆ្លូង បានពន្យល់ណែនាំខ្ញុំថាកម្លាំងបដិវត្តន៍មិនអាចយកជ័យជម្នះលើកម្លាំងទ័ព ដែលមានសហរដ្ឋអាមេរិកជាអ្នកគាំទ្របានទេ។ដូចច្នេះទិសដៅរបស់ក្រុមយើងគឺត្រូវតែប្រឆាំងបដិវត្តន៍ ប៉ុន្តែពេលនេះយើងធ្វើការដើម្បីបង្កប់ស៊ីរូងផ្ទៃក្នុងរដ្ឋអំណាចក្នុងការធ្វើសកម្មភាពប្រឆាំងបដិវត្តន៍។

នៅឆ្នាំ១៩៧១ ខ្ញុំ បានផ្លាស់មកធ្វើជាប្រធានឃុំស្វាយឃ្លាំងស្រុកក្រូចឆ្មារវិញ។ ក្រោយមកទៀតក្នុងឆ្នាំ១៩៧២ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានមន្ទីរកសិកម្មតំបន់២១ ភូមិភាគបូព៌ា។នៅឆ្នាំ១៩៧៤ម៉ែដូបានចាត់តាំងខ្ញុំឲ្យចុះតាមស្រុកដើម្បីធ្វើការសម្រិតសម្រាំងអ្នកស្មោះត្រង់ បដិវត្តន៍ចេញពីសមាគមកសិករឲ្យអស់។ពេលនោះខ្ញុំបានចុះទៅស្រុកត្បូងឃ្មុំ និងស្រុកតំបែរ។នៅខែមិថុនា ឆ្នាំ១៩៧៥ ខ្ញុំបានធ្វើជាលេខាស្រុកពាមជីលាំង។ នៅខែសីហា ឆ្នាំដដែលមានការប្រជុំមួយនៅក្បែរផ្សាររជុបចាស់ដែលមានអ្នកចូលរួម៖ ចាន់,មុន, លីផែន,ប៊ុនសានី,ម៉ែដូ,ចក្រី,ឆោមសាវ៉ាត,ជុំ,ផា និងអ្នកផ្សេងទៀត។ខ្លឹមសារនៃកិច្ចប្រជុំនោះ បានលើកឡើងអំពីការរៀបចំឡាន,កាណូត,គ្រាប់រំសេវ,អាវុធ, ថ្នាំពេទ្យ, ស្បៀង ដើម្បីត្រៀមវាយផ្តួលរំលំបក្សកុម្មុយនីស្តកម្ពុជា នៅថ្ងៃទី៣០ ខែកញ្ញា១៩៧៥ដោយមានវៀតណាមជាអ្នកជួយគាំទ្រ។ ប៉ុន្តែនៅពាក់កណ្តាលខែកញ្ញាឆ្នាំ១៩៧៥ បន្ទាប់ពីខ្ញុំបានជួបបងចាន់បងចាន់បាន ណែនាំខ្ញុំ ឲ្យពន្យាសកម្មភាពធ្វើរដ្ឋប្រហារសិនដោយរក្សាទុកអាវុធនៅដដែល។ នៅដើមឆ្នាំ ១៩៧៦ខ្ញុំបានទៅជួបបងចាន់នៅមន្ទីរសេដ្ឋកិច្ចភូមិភាគបូព៌ា ដើម្បីស្នើសុំកម្លាំងនៅពាមជីលាំងបន្ថែម។ កងកម្លាំងដែលស្នើសុំទាំងនោះរួមមានសុតប្រធានឃុំ កំពង់ទ្រាស,វុទ្ធី សមាជិកឃុំ,ម៉ោងប្រធានឃុំសំរោង,ហុង ប្រធានឃុំពាមជីលាំង,ថុនប្រធានឃុំបឹងព្រួល,ផាតប្រធានឃុំជីរ៉ូទី១និងស៊ាប្រធានឃុំថ្មពេជ្រ។ បន្ទាប់មក បងចាន់ណែនាំឲ្យខ្ញុំចុះទាក់ទងខ្សែក្បត់ ដើម្បីបំផុសធ្វើវិច្ឆេទកម្មទូទៅនៅក្នុងតំបន់២១ ដូចជាទម្លាយទំនប់,លាក់ស្រូវទុក,បង្អត់ជីវភាពរស់នៅរបស់ប្រជាជន និងបង្ខំប្រជាជនឲ្យធ្វើការជាទម្ងន់។នៅចុងឆ្នាំ១៩៧៦មានកិច្ចប្រជុំនៅសេនាធិការភូមិភាគបូព៌ា ដោយមានអ្នកចូលរួមដូចជា ម៉ុន,ផន ប្រធានកងពលលេខ៤របស់ភូមិភាគបូព៌ា,ប៉ូលី វ៉ាន់លេខាស្រុកសំរោងតំបន់២៣,ធុចអនុលេខាតំបន់២៣,ម៉ែដូ,គីម,ជុំ ,វ៉ើនហុន,ផា និងឆោមសាវ៉ាត។ ខ្លឹមសារ នៃកិច្ចប្រជុំគឺដើម្បីត្រៀមខ្លួនអនុវត្ត ផែនការវាយប្រហារភ្លាមៗ ទៅលើបក្សកុម្មុយនីស្តកម្ពុជានៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៧។មួយវិញទៀតកិច្ចប្រជុំនេះធ្វើឡើង ដើម្បីត្រៀមបោះខិតបណ្ណប្រកាសឲ្យប្រជាជនដឹងមុនពេលធ្វើរដ្ឋប្រហារ ហើយផ្តល់ព័ត៌មានទាំងនេះទៅឲ្យខ្សែបណ្តាញរបស់បក្ខពួកក្បត់។

ចាត់តាំង ទុយ គណៈយោធាស្រុកពាមជីលាំងត្រៀមអាវុធ១២០ដើម។ ប៉ុន្តែក្រោយមកទៀតផែនការធ្វើរដ្ឋប្រហារនេះក៏ត្រូវអាក់ខានវិញ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៧ បងចាន់បានបើកកិច្ចប្រជុំមួយ ដើម្បីខ្ទេសនាមអំពីមូលហេតុដែល

មិនបានអនុវត្តដែ នការធ្វើរដ្ឋប្រហារនេះ គឺដោយសារ ធុច និង ប៉ូលី វ៉ាន់ ដែលជាខ្មែរទាក់ទងជាមួយវៀតណាម ត្រូវអង្គការចាប់ខ្លួនហើយខ្មែរទាក់ទងនីរសារពីតំបន់មួយទៅតំបន់ មួយក៏ដាច់ទំនាក់ទំនងទៀតៗ ដូច្នេះ មានតែរក្សាការសម្ងាត់ ហើយលើកផែនការធ្វើរដ្ឋប្រហារនេះទៅថ្ងៃ១៥ ខែមេសា ឆ្នាំ ១៩៧៧វិញៗ ប្រសិនបើកម្លាំងទ័ពក្បត់ណាបាក់ទ័ពត្រូវរត់ទៅប្រទេសវៀតណាម ចំណែកកម្លាំងក្បត់ ដែលមិនទាន់បាក់ទ័ពឬបែកការណ៍ទេគឺត្រូវនៅបង្កប់ខ្លួនបន្តទៀតៗ

ក្រោយមក បងម៉ុន បានសរសេរសំបុត្រហៅខ្ញុំទៅជួបនៅសេនាធិការយោធាភូមិភាគៗខ្ញុំក៏បានទៅជួបកឹមដា,ម៉ែដូ, ភនសោម,ជុំផន និងហន់ៗ បងម៉ុន បានរាយការណ៍អំពីសភាពការណ៍ដែលអង្គការ កំពុងតែចាប់ខ្មែរក្បត់ជាច្រើននៅភូមិភាគបូព៌ា ហើយគាត់បានពន្យាពេលធ្វើសកម្មភាពដោយលើកទៅខែឧសភា ឆ្នាំ១៩៧៧វិញៗ ចំពោះសកម្មភាពដែលក្រុមខ្ញុំត្រូវធ្វើបន្តទៀត គឺប្រឆាំងមាគ៌ាកសាងប្រទេសរបស់បក្ស ដើម្បីរួមចំណែកធ្វើឲ្យបក្សបរាជ័យក្នុងពេលឆាប់ៗ តាមរយៈការធ្វើសកម្មភាពដូចជា បង្ករទំនាស់ក្នុងសហករណ៍ក្នុងជួរកងទ័ព ធ្វើវិទ្ធេទកម្មបំផ្លាញទំនប់និងបំផ្លាញស្រូវ ជាដើមៗ

បន្ទាប់ពីការប្រជុំលើកនេះរួច ខ្ញុំក៏បានចុះតាមមូលដ្ឋានចាត់ចែងដឹកនាំខ្មែរបណ្តាញក្បត់ឲ្យធ្វើសកម្មភាពជាបន្តបន្ទាប់ៗ ក្រោយមកទៀត សកម្មភាពប្រឆាំងបដិវត្តន៍របស់ខ្ញុំបានបែកការណ៍ ហើយខ្ញុំក៏ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៧ៗ



*យោធាខ្មែរក្រហមនៅសមរភូមិតាមបណ្តោយព្រំដែន*

**កំណត់ចំណាំ៖** រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ ការបង្ខិតបង្ខំនិងធ្វើទារុណកម្មធ្ងន់ធ្ងរ ពីកងសួរចម្លើយ របស់ខ្មែរក្រហមៗ ដូច្នេះយើង មិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ប៊ិនបានហៅបូពិតប្រាកដឬយ៉ាងណានោះទេៗ

**ដាត ចាន់សុនិតា**

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរគឺ ជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុខាងកើតវិមានឯករាជ្យ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោងប្រាំបី ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ ដល់ម៉ោង៥។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា តាមរយៈទូរសព្ទលេខ៖ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល៖ truthchenda.s@dccam.org។






























# រៀបការដោយមិនបានត្រៀមខ្លួន

ស្នេហាគឺជាសេចក្ដីស្រឡាញ់ រវាងចិត្តនិងចិត្តដោយគ្មានការបង្ខិតបង្ខំ ហើយអាចឈានទៅដល់ ការរៀបការទៅតាមទំនៀមទម្លាប់ប្រពៃណី និងមានទទួលស្គាល់ ដោយច្បាប់រដ្ឋដើម្បីកសាងគ្រួសារថ្មីៗប៉ុន្តែនៅក្នុងរបបខ្មែរក្រហម ការរៀបការតែងតែរៀបចំ ដួដួងឡើង ដោយអង្គការដោយសាមីខ្លួនមិនអាចប្រកែក តវ៉ាបានឡើយ។ ញ៉ែម សារី ភេទប្រុស សព្វថ្ងៃមាន អាយុ ៧៣ឆ្នាំ រស់នៅក្នុងភូមិរោទិ៍ ឃុំញរ ស្រុក កំពង់រោទិ៍ ខេត្តស្វាយរៀង បានរៀបការនៅក្នុងរបបខ្មែរក្រហមប៉ុន្តែគាត់ទទួលបាន ការស្រឡាញ់ ពីប្រពន្ធរបស់គាត់ដែលខុសពីគូស្វាមីមួយចំនួនទៀត។ សារី បានសើចនិងមានទឹកមុខអៀនខ្មាសនៅពេលដែលគាត់ រំឭក ដល់រឿងរ៉ាវស្នេហារបស់គាត់នៅក្នុងរបបខ្មែរក្រហម៖

នឹកដល់របបខ្មែរក្រហម ខ្ញុំតែងតែនឹកឃើញ ដល់ថ្ងៃរៀបការរបស់ខ្ញុំ។ថ្ងៃនោះគឺជាថ្ងៃមួយដែលខ្ញុំរំភើបយ៉ាងខ្លាំងបំផុតក្នុងជីវិត។ នាល្ងាចថ្ងៃមួយ ពេលដែលព្រះអាទិត្យអស្ដង្គតហើយផ្ទៃមេឃចាប់ផ្ដើមងងឹតមានបុរសម្នាក់ក្នុងសម្លៀកបំពាក់ពណ៌ខ្មៅបានដើរចូលមកក្នុងផ្ទះរបស់ខ្ញុំហើយ ប្រាប់ខ្ញុំថា« មិត្តឯងប្រញាប់ប្រញាល់ស្លៀកពាក់និងទៅជួបជុំគ្នានៅឯរោងបាយ»។ ខ្ញុំក៏បានឆ្លើយយល់ព្រម និងមិនបានសួរដេញដោលរកមូលហេតុហៅខ្ញុំទៅកាន់រោងបាយធ្វើអ្វីនោះទេ។នៅក្នុងរបបខ្មែរក្រហម គឺយើងគ្មានសិទ្ធិសួរនាំរកហេតុផលឬប្រកែកតវ៉ាឡើយ។ ខ្ញុំបានស្លៀកពាក់សម្លៀកបំពាក់ពណ៌ខ្មៅរបស់ខ្ញុំ និងរួសរាន់ធ្វើដំណើរទៅកាន់រោងបាយ។ លុះទៅដល់រោងបាយ ខ្ញុំឃើញមានកងស្ត្រីផ្ដុំគ្នានៅម្ខាង និងកងបុរសឈរនៅម្ខាងទៀតក្នុងសម្លៀក បំពាក់ពណ៌ខ្មៅ ហើយអ្នកខ្លះមានបង់កក្រមា។នៅក្នុងរបបខ្មែរក្រហម ពេលមានមនុស្សបង់កក្រមាដែលរំលេចទៅដោយពណ៌ហើយយើងក្រឡេកមើលទៅអ្នកទាំងនោះគឺស្រស់ស្អាតខ្លាំងណាស់។



ញ៉ែម សារី កំពុងអង្គុយនៅក្រោមផ្ទះរបស់គាត់

ខ្ញុំក៏នៅតែមិនទាន់ដឹងច្បាស់នៅក្នុងចិត្តថា តើអង្គការហៅខ្ញុំមកដើម្បីអ្វីនៅឡើយ។ នៅពេលដែលមកជួបជុំគ្នាបុរសក្នុងសម្លៀកបំពាក់ពណ៌ខ្មៅម្នាក់ បានប្រាប់ខ្ញុំឲ្យចូលជួរនិងចូលអង្គុយតាមគូ ដែលបានរៀបចំរួចជាស្រេច។ បុរសនោះក៏ចាប់ផ្ដើមហៅឈ្មោះបុរសម្នាក់ និងស្ត្រីម្នាក់មកអង្គុយជាគូៗពេលនោះហើយដែលខ្ញុំដឹងថា អង្គការកំពុងតែរៀបការឲ្យខ្ញុំ។ខ្ញុំមានអារម្មណ៍ភ័យផងអរផងរកនឹកមិនត្រូវ នៅក្នុងចិត្តឡើយ។ខ្ញុំខំប្រឹងផ្ទៀងត្រចៀកស្ដាប់យ៉ាងប្រុងប្រយ័ត្ន ព្រោះខ្ញុំពិតជាចង់ដឹងថាតើនរណាគឺជាប្រពន្ធរបស់ខ្ញុំ។ ខ្ញុំនិងប្រពន្ធរបស់ខ្ញុំគឺជាគូស្នេហ៍ចុងក្រោយគេបង្អស់ ដែលអង្គការបានហៅឈ្មោះហើយខ្ញុំក៏មិនដែលជួបមុខ និងស្គាល់ប្រពន្ធរបស់ខ្ញុំពីមុនមកដែរ។ បន្ទាប់ពីហៅឈ្មោះចប់អង្គការបានឲ្យយើងឡើងប្ដេជ្ញាម្ដងម្នាក់ៗ។ខ្ញុំក៏បានឡើងប្ដេជ្ញាដែរ។ ខ្ញុំបានប្ដេជ្ញានៅចំពោះមុខមនុស្សគ្រប់គ្នាថា «ខ្ញុំសូមប្ដេជ្ញាថា ខ្ញុំនឹងស្ម័គ្រ

ស្មោះថែរក្សាប្រពន្ធរបស់ខ្ញុំអស់មួយជីវិត»។នៅពេលខ្ញុំប្ដេជ្ញាចប់គូរស្នេហ៍ផ្សេងៗទៀតនាំគ្នាទះដៃ ហើយស្រែកទ្រហោកងរំពងដើម្បីអបអរសាទរខ្ញុំ។ របបខ្មែរក្រហម បានដួលរលំបន្ទាប់ពីខ្ញុំរៀបការមិនបានប៉ុន្មានខែផង។ ខ្ញុំដឹងថាការរៀបការរវាងខ្ញុំនិងប្រពន្ធរបស់ខ្ញុំ បានកើតឡើងដោយការរៀបចំពីអង្គការនិងស្ថិតក្នុងស្ថានភាពលំបាកបំផុត ប៉ុន្តែសម្រាប់ខ្ញុំវាគឺជាស្នេហាពិត និងមានអត្ថន័យជ្រាលជ្រៅណាស់។ ខ្ញុំជឿទៅលើចិត្តគំនិតស្អាតស្អំនិងអំពើល្អ ហើយខ្ញុំក៏គិតថានេះគឺជាវាសនារបស់ខ្ញុំដែរ។

ខ្ញុំមិនសង្ឃឹមថា ខ្ញុំអាចមានជីវិតរស់នៅបានរហូតដល់សព្វថ្ងៃទេ ព្រោះនៅមុនពេលរបបខ្មែរក្រហមឡើងកាន់អំណាច ខ្ញុំធ្លាប់បានរត់ភៀសខ្លួនទៅរស់នៅក្នុងភូមិប៊ិនហៀបនៃប្រទេសវៀតណាម និងមានគម្រោងបន្ត ទៅរស់នៅតំបន់ផ្សេងទៀតក្នុងទឹកដីនៃប្រទេសវៀតណាម។ ប៉ុន្តែឪពុកម្ដាយនិងបងប្អូនរបស់ខ្ញុំបានហៅខ្ញុំត្រឡប់មកផ្ទះវិញ។ ខ្ញុំបានត្រឡប់មកផ្ទះវិញដោយជឿជាក់ថា ខ្ញុំអាចរស់នៅជួបជុំក្រុមគ្រួសារ។ ប៉ុន្តែ ជាអកុសល ខ្ញុំត្រូវបានខ្មែរក្រហមយកទៅអប់រំនិងលត់ដំយ៉ាងធ្ងន់ធ្ងរ។ នៅក្នុងឆ្នាំ១៩៧៥ ខ្ញុំត្រូវបានចាប់បញ្ជូនឲ្យទៅរស់នៅជាមួយជនជាតិស្លៀង និងឈ្លើយសឹកដែលជាអតីតទាហានលន់នល់ ចំនួនប្រហែល៣០០នាក់ផ្សេងទៀតនៅក្នុងស្រុកមេមត់ខេត្តកំពង់ចាម ព្រោះខ្មែរក្រហមបានដឹងថាខ្ញុំធ្លាប់បានរត់ទៅប្រទេសវៀតណាម។ រយៈពេល៦ខែក្រោយមកខ្ញុំត្រូវចាប់បញ្ជូនត្រឡប់ មករស់នៅក្នុងសហករណ៍ក្នុងស្រុកកំពង់រោទិ៍ ជាមួយទាហាន លន់ នល់ វិញលើកលែងតែអ្នកដែលមានទោសធ្ងន់ធ្ងរ មិនអាចលើកលែងបាន។ រយៈពេល៣ខែបន្ទាប់មក ខ្ញុំត្រូវបានបញ្ជូនឲ្យទៅមន្ទីរសន្តិសុខ ឫស្សីសាញ់ ជាមួយទាហាន លន់ នល់ ប្រមាណ៥០នាក់ផ្សេងទៀត ដោយមានឈ្មោះអឿន ជាប្រធាននៅទីនោះ។ មន្ទីរសន្តិសុខឫស្សីសាញ់មានចម្ងាយ ប្រហែល១០គីឡូម៉ែត្រពីសហករណ៍កំពង់រោទិ៍ដែលខ្ញុំរស់នៅ។ កន្លងផុតមិនយូរប៉ុន្មានប្រធានមន្ទីរសន្តិសុខឫស្សីសាញ់បានហៅឈ្មោះ អ្នកទោស៤០នាក់ឲ្យទៅរស់នៅភូមិអូរដូនរាម ឃុំព្រះពន្លា ស្រុកកំពង់រោទិ៍វិញ។ចំណែកអ្នកទោសដែលមិនមានឈ្មោះចេញត្រូវបានកងឈ្លបយកទៅសម្លាប់ចោល។រយៈពេល៣ ខែក្រោយមកទៀត ខ្ញុំ និងប្រជាជនក្នុងភូមិ ត្រូវបានជម្លៀសឲ្យទៅរស់នៅក្នុងវត្តចំបក់ដោយសារតែមានការវាយប្រហារពីកងទ័ពវៀតណាម។ នៅអំឡុង ឆ្នាំ១៩៧៨ ខ្ញុំបានឃើញឈ្លបយកយុវជនយកទៅសម្លាប់ លើកទីមួយ មានយុវជនចំនួន៧០នាក់និងលើកទី២ មានយុវជនចំនួន៧៤នាក់។ កងយុវជនទាំងនោះត្រូវបានហៅចេញពីកងយុវជនដែលខ្ញុំរស់នៅជាមួយ។ មូលហេតុដែលយុវជនទាំងអស់នោះត្រូវយកទៅសម្លាប់ ព្រោះមានឪពុកម្ដាយរត់គេចខ្លួនទៅប្រទេសវៀតណាម ដែលធ្វើឲ្យខ្ញុំភិតភ័យយ៉ាងខ្លាំង។

ក្រុមគ្រួសារខ្ញុំ ត្រូវបានជម្លៀសមកនៅក្នុងភូមិជាមួយខ្ញុំ ប៉ុន្តែយើងមិនត្រូវអនុញ្ញាតឲ្យរស់នៅជុំគ្នាឡើយ។ខ្ញុំធ្លាប់បានរស់នៅក្នុងក្រុមយុវជន ដូច្នេះ ខ្មែរក្រហមបានប្រើខ្ញុំឲ្យធ្វើការងារទាំងយប់ទាំងថ្ងៃ។ ខ្ញុំ បានធ្វើការងារគ្រប់យ៉ាងទៅតាមបញ្ជារបស់អង្គការ ប៉ុន្តែ ខ្ញុំពុំដែលទទួលបានអាហារហូបចុកគ្រប់គ្រាន់ឡើយ។ ខ្ញុំឃើញប្រជាជនខ្លះឈឺស្លាប់ឯប្រជាជនខ្លះទៀតស្លាប់ដោយសារការអត់ឃ្លាន។ ខ្ញុំមិនអាចដើរតាមចិត្តបានទេ។នៅពេលទំនេរពីការងារ នៅវាលស្រែខ្ញុំតែងតែឆ្លៀតដាំត្រកួននៅជុំវិញផ្ទះ។នៅពេលវាដុះលូតលាស់ល្អទើបខ្ញុំបេះវាយមកហូបម្ដង។ ប៉ុន្តែ ចុងភៅតែងតែលួចខ្សិបខ្សៀវគ្នាទៅវិញទៅមក ដោយសម្ដែងទឹកមុខ មិនសូវល្អនៅពេលឃើញខ្ញុំបេះត្រកួននោះ។ ពេលនោះហើយ ដែលខ្ញុំព្រួយបារម្ភយ៉ាងខ្លាំង ព្រោះខ្ញុំអាចត្រូវបានខ្មែរក្រហមយកទៅរៀនសូត្រឬសម្លាប់ចោល។ ប៉ុន្តែខ្ញុំមានសំណាងល្អដោយសារបានប្រពន្ធរបស់ខ្ញុំជួយលើកចិត្តឲ្យខិតខំធ្វើការងារ រហូតបានរួចផុតពីការសង្ស័យរបស់ខ្មែរក្រហម។ រហូតមកដល់សព្វថ្ងៃនេះខ្ញុំមានកូនចំនួន៤នាក់គឺស្រី៣នាក់ និងប្រុស១នាក់។ ខ្ញុំ និងប្រពន្ធប្រកបមុខរបរធ្វើស្រែហើយឆ្លៀតពេលទំនេរ ខ្ញុំធ្វើជាអាចារ្យនៅវត្តមួយនៅក្បែរផ្ទះរបស់ខ្ញុំ។ **អ៊ុន សុដាវី**

# ខ្ញុំដឹងថាសង្គ្រាមនឹងកើតមាន

នៅរវាងឆ្នាំ១៩៧៣ ពេលនោះមានការទម្លាក់គ្រាប់បែកយ៉ាងច្រើនពីសំណាក់យោធារបស់អាមេរិក។ ភូមិរបស់ខ្ញុំស្ថិតនៅក្នុងតំបន់ប្រទាញប្រទង់គ្នារវាងយោធាខ្មែរក្រហម និងទាហានវៀតកុង(វៀតណាមខាងត្បូង)។ ប្រជាជនទាំងអស់នៅក្នុងភូមិរបស់ខ្ញុំបាន នាំគ្នារត់ចេញពីភូមិទៅរស់នៅ ទីកន្លែងផ្សេងៗជាបណ្ដោះអាសន្នដើម្បីគេចពីគ្រោះថ្នាក់។

ឪពុកខ្ញុំមានកង់ខ្មែរពីរគ្រឿង។ មួយគ្រឿងសម្រាប់ខ្ញុំជិះនិងមួយគ្រឿងទៀតសម្រាប់គាត់ដឹកអីវ៉ាន់។ កង់របស់ខ្ញុំមានគ្រៀមសម្ភារប្រើប្រាស់ទុកជាស្រេចរួមមាន ឆ្នាំងចក្រខ្មែរ(ឆ្នាំងដាំបាយដាក់អង្ករបានប្រាំកំប៉ុង), ខោអាវ, កន្ទេល, អង្ករ និងខស។ បន្ទាប់ពីខ្ញុំ យកសម្ភារទាំងនេះមកប្រើប្រាស់រួចខ្ញុំមិនហ៊ានទុកវាចោលឡើយគឺខ្ញុំត្រូវយកវាទៅចងជាប់ជាមួយកង់របស់ខ្ញុំវិញ ព្រោះខ្ញុំខ្លាចរៀបចំមិនទាន់។

ពេលខ្ញុំជិះកង់តាមផ្លូវ ខ្ញុំបានឃើញមនុស្សជាច្រើនធ្វើដំណើរចេញពីភូមិរោទ៍ទៅកាន់ផ្សារប្រសូត្រ។នៅលើកង់របស់ខ្ញុំផ្ទុកពេញដោយរបស់របរប្រើប្រាស់ និងបានឌុបប្អូនរបស់ខ្ញុំពីរនាក់ទៅជាមួយផង។ ប្អូនរបស់ខ្ញុំគឺសុខឡឹង និងប្អូនស្រីសុខចិន្ដាបានអង្គុយគោងចង្កេះរបស់ខ្ញុំ។ ចំណែក ឪពុករបស់ខ្ញុំបានដឹកខោអាវ(សម្រាប់គ្រួសារទាំងអស់),អង្ករ,ខស, កន្ទេលនិងរបស់របរប្រើប្រាស់មួយចំនួនដែលចាំបាច់។ម្ដាយរបស់ខ្ញុំបានធ្វើដំណើរដោយថ្មើរជើង និងពរប្អូនរបស់ខ្ញុំម្នាក់ដែលទើបមានអាយុជាងមួយខួបនៅលើចង្កេះ។ ចំណែកប្អូនរបស់ខ្ញុំម្នាក់ទៀតបានជិះក្របីឈ្មោលមួយក្បាល និងដឹកក្របីមួយក្បាលទៀតតាមពីក្រោយ។ ខ្ញុំ តែងឈប់កង់ទៅជួយប្អូនទាញក្របីបំបែកពីគ្នា ព្រោះវាតែងវ័ធគ្នានៅពេលដើរកៀកគ្នា។ រីឯប្អូនម្នាក់ទៀត បានរស់នៅជាមួយបងរបស់ខ្ញុំដែល



*សុខ មើយ អង្គុយនៅលើអង្រឹងមុខផ្ទះ*

មានរៀបការរួចហើយ ដើម្បីជួយមើលកូនរបស់គាត់ៗ ខ្ញុំមិនបានធ្វើដំណើរចេញទៅដំណាលគ្នា ជាមួយឪពុករបស់ខ្ញុំទេប៉ុន្តែយើងបានជួបគ្នានៅតាមផ្លូវៗ ខ្ញុំតែងសុំបសួរដំណឹងពីទាហានវៀតណាម និងយោធាខ្មែរក្រហមថាពួកគេ បានចាកចេញពីភូមិអស់ឬនៅដើម្បីខ្ញុំបានវិលត្រឡប់មកផ្ទះរបស់ខ្ញុំនៅក្នុងភូមិរោទិ៍វិញៗ នៅតាមសងខាងផ្លូវខ្ញុំឃើញស្រូវទុំពេញវាលស្រែ ប៉ុន្តែខ្ញុំមិនហ៊ានបូតស្រូវរបស់អ្នកភូមិទេៗ ឪពុកខ្ញុំគាត់មានប្រាក់ខ្លះជាប់ខ្លួន ដូច្នេះយើងអាចទិញស្រូវរបស់អ្នកភូមិ រួចហើយសុំត្បាល់របស់អ្នកភូមិបុកដើម្បីវែងយកអង្ករដាំហូបៗ ក្រុមគ្រួសាររបស់ខ្ញុំបានស្នាក់នៅជាមួយប្រជាជននៅភូមិប្រសូត្ររយៈពេល១ខែ ទើបបានវិលត្រឡប់មកផ្ទះវិញៗ

យើងបានមករស់នៅផ្ទះវិញបាន មួយរយៈពេលខ្លីក៏បាននាំគ្នាភៀសខ្លួនទៅរស់នៅក្រៅភូមិម្តងទៀត ដើម្បីគេចពីការទម្លាក់គ្រាប់បែករបស់អាមេរិកៗ ទីនោះ ហៅថា «វាលដំរំ» ដែលជាវាលស្រែ មានចម្ងាយ២គីឡូម៉ែត្រពីផ្ទះរបស់ខ្ញុំក្នុងភូមិរោទិ៍ៗ គ្រួសាររបស់ខ្ញុំ មានអង្ករគ្រប់គ្រាន់ប៉ុន្តែមិនមានទឹកគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ទេៗ នៅទីនោះមានអណ្តូងបុរាណមួយ ដែលមានជម្រៅប្រហែលជា៥០០ម៉ែត្រ ប៉ុន្តែខ្ញុំមិនដែលបានទៅដងទឹកទាន់គេឡើយៗ ទំរាំដល់វេនខ្ញុំទឹកអណ្តូងលែងចេញទឹកហើយៗ ចំណែកបឹងឬប្រឡាយនៅជិតនោះមិនអាចប្រើបានទេព្រោះធំក្លិនលាមក និងទឹកនោមគោ និងក្របីៗ ដូច្នេះ យើងគ្មានមធ្យោបាយអ្វីក្រៅប្រថុយគ្រោះថ្នាក់ចូលទៅដងទឹកនៅក្នុងភូមិយកមកប្រើប្រាស់ទេៗ ខ្ញុំនិងបងប្អូនព្រមទាំងឪពុករបស់ខ្ញុំ តែងផ្លាស់វេនគ្នាចូលទៅក្នុងភូមិដងទឹកៗ

នៅដើមឆ្នាំ១៩៧៥ ភូមិរោទិ៍ ឃុំញរ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមទាំងស្រុងៗ ខ្ញុំត្រូវបានចាត់តាំងឲ្យចូលធ្វើការនៅក្នុងកងយុវនារី ជីកប្រឡាយ លើកទំនប់ៗ ចំណែកប្អូនខ្ញុំដែលនៅតូចខ្មែរក្រហមឲ្យនៅជាមួយកងម៉ែៗៗ ប្អូនរបស់ខ្ញុំ មានវ័យធំល្មមធ្វើជាកងកុមារ ចំណែកប្អូនប្រុសរបស់ខ្ញុំម្នាក់ទៀតដែលមានអាយុប្រមាណ១២ឆ្នាំ ឈ្មោះ សុខ គឹម ត្រូវបានខ្មែរក្រហមស្នើឲ្យធ្វើជាយោធាខ្មែរក្រហម ហើយបានបាត់រហូតៗ

**ដារ៉ារដ្ឋ មេត្តា**



*រង្វង់មូលក្រពើ ផ្លូវបំបែកទៅផ្សារប្រសូត្រ ស្ថិតនៅក្នុងស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង*

# ៤០ឆ្នាំក្រោយមក រូបថតមួយសន្លឹក និងឯកសារបានបញ្ជាក់ការពិត

ការនឹករឭករវាងកូនស្រីទៅកាន់ឪពុកដែលបានបាត់ដំណឹងនៅក្នុងរបបខ្មែរក្រហម បានផុសឡើងសាជាថ្មីបន្ទាប់ពីបានឃើញរូបថតមួយសន្លឹក ដែលទើបតែរកឃើញនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ សេក សាយ តែងតែទន្ទឹងរង់ចាំមើលផ្លូវឪពុកវិលត្រឡប់មកជួបជុំគ្រួសារវិញនៅថ្ងៃណាមួយ ប៉ុន្តែជាអកុសល្យការទន្ទឹងរង់ចាំរបស់គាត់គឺបានត្រឹមតែដំណឹងនៃការស្លាប់ រួមជាមួយនឹងរូបថតមួយសន្លឹក និងឯកសារចម្លើយសារភាព ដែលមានកម្រាស់ ២២០ទំព័ររបស់ឪពុកគាត់ ដែលនៅសេសសល់ប៉ុណ្ណោះ។ រូបថត និងឯកសារទាំងនេះត្រូវបាន បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាយកទៅប្រគល់ជូនគាត់ នៅផ្ទះស្ថិតនៅក្នុងភូមិព្រៃទួប ឃុំស្ទូងក្រពើ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩ កន្លងមក ។ ទោះបី សេក សាយ បានទទួលដំណឹងដ៏ក្រៀមក្រំនេះក៏ដោយ ក៏គាត់ទទួលយក ព្រោះជាព័ត៌មានដ៏ជាក់លាក់ពិតប្រាកដមួយ ដែលធ្វើឲ្យគាត់អស់ចិត្ត ។ ឪពុករបស់ សេក សាយ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧៨ យកមកឃុំឃាំង សួរចម្លើយ និងសម្លាប់នៅមន្ទីរសន្តិសុខ ស-២១។

សេក សាយ ស្ថិតក្នុងវ័យ៥២ឆ្នាំ បានរៀបរាប់ទាំងអារម្មណ៍ក្តុកក្តួល លាយឡំជាមួយទឹកភ្នែកថា «ខ្ញុំបានបែកពីឪពុក (សេក សាត ហៅ និន ហៅ ប្រាក់ នាទីលេខាតំបន់២៥)អស់រយៈពេលជាង៤០ឆ្នាំហើយ តាំងពីខ្ញុំមានអាយុ១១ឆ្នាំ។ការជួបគ្នាជាលើកចុងក្រោយរវាងឪពុកហើយនឹងខ្ញុំគឺនៅពេលដែលម្តាយរបស់ខ្ញុំបានយកខ្ញុំទៅផ្ញើនៅមន្ទីរ



*សេក សាយ ហៅ សេក សុធី និង កូនស្រី*

ពេទ្យសំប៉ាន ក្នុងខេត្តកណ្តាល នៅឆ្នាំ១៩៧៨។ ក្រោយមក ខ្ញុំ ត្រូវបានបញ្ជូនទៅមន្ទីរឃុំឃាំង ជ្រៃអូរញៅ នៅខេត្តកំពង់ស្ពឺ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ខ្ញុំបានព្យាយាមតាមរកដំណឹងឪពុករបស់ខ្ញុំនៅគ្រប់ទីកន្លែង និងបានប្រកាសសួររកដំណឹងរបស់គាត់នៅតាមវិទ្យុ។ ប៉ុន្តែ មិនបានទទួលដំណឹងគាត់ទាល់តែសោះ។ ថ្ងៃមួយ ខ្ញុំបានសួរទៅកាន់បងប្រុសជីដូនមួយរបស់ខ្ញុំថា តើមានបានទទួលដំណឹងពីឪពុករបស់ខ្ញុំដែរឬទេ? គាត់ បានឆ្លើយតបមកខ្ញុំវិញថា គាត់បានព្យាយាមរកអស់ជាច្រើនកន្លែងដែរ ប៉ុន្តែនៅតែមិនទទួលបានដំណឹងអ្វីសោះ។ ប្រហែលជាគាត់ បានស្លាប់ហើយ ហើយប្រសិនបើគាត់នៅរស់គាត់ នឹងមករកយើងមិនខាន។ ក្តីសង្ឃឹមដ៏តិចតួចរបស់ខ្ញុំ បានរសាយប៉ុន្តែអារម្មណ៍របស់ខ្ញុំនៅតែគិតថា ឪពុករបស់ខ្ញុំគឺនៅរស់រានមានជីវិតនៅឡើយ។ ខ្ញុំនឹករឭកដល់ឪពុករបស់ខ្ញុំជារៀងរាល់ថ្ងៃ។ មានពេលខ្លះខ្ញុំបានព្យាយាមស្វែងរកឪពុករបស់ខ្ញុំតាមរណ្តៅសាកសព និងផ្នូរមួយចំនួនដែលត្រូវបានគេគាស់។

បន្ទាប់ពី ខ្ញុំទទួលបានរូបថតមួយសន្លឹកនេះ និងចម្លើយសារភាពមួយច្បាប់របស់ឪពុកខ្ញុំ ដែលត្រូវបានបង្ខំសួរចម្លើយរបស់ឆ្មាំគុកនៃមន្ទីរសន្តិសុខ ស-២១ នៅថ្ងៃនេះខ្ញុំមានអារម្មណ៍តក់ស្លុត និងរំជួលចិត្តយ៉ាងខ្លាំង ព្រោះដំណឹងនេះបានបញ្ជាក់ឲ្យខ្ញុំដឹងថា ឪពុករបស់ខ្ញុំពិតជាបានស្លាប់នៅក្នុងមន្ទីរសន្តិសុខ ស-២១ ពិតមែន។ ខ្ញុំគិតថាឪពុករបស់ខ្ញុំត្រូវបានឆ្មាំគុកវាយបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរដើម្បីឆ្លើយសារភាព។

រូបថតឪពុករបស់ខ្ញុំដែលខ្ញុំទទួលបាននេះ គឺមើលទៅហាក់ដូចជាគាត់នៅវ័យក្មេងនៅឡើយ ដោយសារតែខ្ញុំបានបែកពីគាត់យូរឆ្នាំមកហើយ។ ប៉ុន្តែអ្វីដែលខ្ញុំដឹងច្បាស់ពីគាត់នៅពេលនោះ គឺគាត់មានឈ្មោះ សេក សាត ហៅ ប្រាក់។ ខ្ញុំ នឹងប្រាប់ពីដំណឹងឪពុករបស់ខ្ញុំ និងរូបថតឪពុករបស់ខ្ញុំ ទៅបងប្អូននៅស្រុកកំណើត នៅខេត្ត ស្វាយរៀង ហើយខ្ញុំនឹងឲ្យកូនស្រីរបស់ខ្ញុំដែលបច្ចុប្បន្នកំពុងរៀនថ្នាក់ទី៧នៅអនុវិទ្យាល័យ អានចម្លើយរបស់ជីតាឲ្យខ្ញុំស្តាប់ ព្រោះខ្ញុំមិនបានរៀនសូត្រ។ កូនស្រីច្បងក្នុងចំណោមកូនប្រាំនាក់របស់ សេក សាយ ឈ្មោះ សន សែម អាយុ២៩ឆ្នាំ បាននិយាយថា «ខ្ញុំធ្លាប់បានឮម្តាយរបស់ខ្ញុំនិយាយប្រាប់ខ្ញុំថាយាយរបស់ខ្ញុំបានជាប់ឃុំឃាំងនៅគុកទួលស្លែង និងត្រូវបានខ្មែរក្រហមសម្លាប់ចោល។ កាលនោះខ្ញុំស្ថិតនៅវ័យក្មេងនៅឡើយដូច្នេះខ្ញុំមិនសូវយល់ពីរឿងរ៉ាវរបស់យាយខ្ញុំទេ»។ ម្តាយខ្ញុំ បានបញ្ជាក់ថាប្រសិនបើយាយរបស់ខ្ញុំនៅរស់គ្រួសាររបស់យើងនឹងមានភាពកក់ក្តៅជាងនេះ។ ខ្ញុំតែងតែស្រមៃចង់ជួបយាយតារបស់ខ្ញុំជានិច្ច ហើយខ្ញុំក៏តែងគិតថា ជីតារបស់ខ្ញុំនៅរស់រានមានជីវិត។ ខ្ញុំសង្ឃឹមថាថ្ងៃណាមួយតារបស់ខ្ញុំច្បាស់ជាទាក់ទងរកម្តាយខ្ញុំ និងបងប្អូនរបស់គាត់។ ប៉ុន្តែនាពេលឥឡូវនេះក្តីសង្ឃឹមរបស់ខ្ញុំត្រូវបានរលាយបាត់អស់បន្ទាប់ពីខ្ញុំបានឃើញរូបថត និងឯកសារដែលនៅសេសសល់របស់គាត់។ ខ្ញុំមានអារម្មណ៍សោកស្តាយខ្លាំងណាស់ ចំពោះដំណឹងនេះ ប៉ុន្តែវាក៏ជាដំណឹងមួយដែលខ្ញុំត្រូវទទួលស្គាល់ថា តារបស់ខ្ញុំពិតជាបានស្លាប់នៅគុកទួលស្លែងពិតមែន។ **ហូ ថុនា**



*សេក សាយ កាន់រូបថតឪពុក ឈ្មោះ សេក ប្រាក់ ដែលជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខស-២១*

# «ទឹកភ្នែកមួយដំណក់របស់ម្តាយ»

នេះគឺជារឿងរ៉ាវរបស់របស់ស្រ្តីម្នាក់ ដែលត្រូវបានចាប់ខ្លួនឃុំឃាំងសួរចម្លើយ និងសម្លាប់នៅមន្ទីរសន្តិសុខស-២១ប៉ុន្តែកូនស្រីរបស់គាត់ម្នាក់ក្នុងចំណោមកូនទាំងបីរបស់គាត់នៅរស់រានមានជីវិតរហូតមកដល់សព្វថ្ងៃនេះ។

រូបថតមួយសន្ទីកក្នុងចំណោមរូបថតរាប់ពាន់សន្ទីកដែលដាក់តាំងបង្ហាញជាសាធារណៈ នៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង បានទាក់ទាញចំណាប់អារម្មណ៍អ្នកចូលទស្សនាយ៉ាងខ្លាំង។ រូបថតនោះគឺជារូបថតរបស់ស្រ្តីម្នាក់ដែលមានឈ្មោះថា ចាន់ គឹមស្រ៊ុន ហៅសាង។រូបថតរបស់ចាន់គឹមស្រ៊ុនត្រូវបានយកទៅផ្តិតលើកដំបូងនៅប្រទេសអាល្លឺម៉ង់ខាងកើត ដើម្បីដាក់តាំងបង្ហាញដល់សាធារណជនបន្ទាប់ពីរបបខ្មែរក្រហម បានដួលរលំនៅឆ្នាំ១៩៧៩។នៅក្នុងសម្លៀកបំពាក់ពណ៌ខ្មៅគាត់សក់ខ្លីត្រឹមកអង្គុយនៅលើកៅអីដើម្បីថតរូប ចាន់ គឹមស្រ៊ុនបានបីកូនប្រុសតូចរបស់គាត់ម្នាក់នៅក្នុងរង្វង់ដៃ។ ប៉ុន្តែនៅពេលសម្លឹង មើលទៅលើរូបថតរបស់គាត់កាន់តែកៀកនឹងឃើញ ដំណក់ទឹកភ្នែកមួយដំណក់ដែលស្រក់ចុះ និងជិតដាមនៅលើថ្ពាល់ផ្នែកខាងស្តាំជាមួយទឹកមុខក្រៀមក្រំ ដែលហាក់បីដូចជាកំពុងតែបារម្ភនិងគិតទៅដល់រឿងរ៉ាវ ដែលនឹងកើតឡើងចំពោះរូបគាត់។

ទឹកភ្នែកគឺជាអំណោយប្រទានពីទេវតា។ ទឹកភ្នែកបរិយាយប្រាប់អំពីអារម្មណ៍ ដែលប៉ះទង្គិចទៅនឹងរឿងរ៉ាវអ្វីមួយដែលបានកើតឡើងឬនឹកឃើញ បណ្តាលឲ្យការរំជួលចិត្ត



ម្តាយ និង ប្អូនប្រុស របស់ សេក សាយ



សេក សាត ឪពុក របស់ សេក សាយ

កើតមានឡើងៗជួនពេលខ្លះវាអាចជាការរំជួលចិត្តដែលកើតឡើងដោយសេចក្តីរីករាយរំភើប ហើយពេលខ្លះទៀតវាអាចកើតឡើងដោយសារតែការ ជួបប្រទះនឹងភាពសោកសង្រេងនិងភ័យរន្ធត់ៗទឹកភ្នែកបានតំណាងឲ្យបេះដូងដែលពិបាកនៅក្នុងការបរិយាយចេញមកខាងក្រៅ។

ដំណក់ទឹកភ្នែករបស់ ចាន់ គីមស្រ៊ុន នេះហាក់ដូចជាបាននិយាយរៀបរាប់អំពីរឿងរ៉ាវជីវិត និងក្រុមគ្រួសាររបស់គាត់នៅក្នុងអំឡុងរបបខ្មែរក្រហម៖

ខ្ញុំឈ្មោះ ចាន់ គីមស្រ៊ុន ហៅសាងកើតនៅក្នុងស្រុកក្រូចឆ្មារខេត្តកំពង់ចាម។ នៅក្នុងឆ្នាំ១៩៦៧ខ្ញុំបានរៀបការជាមួយប្តីឈ្មោះ សេក សាតមានស្រុកកំណើតនៅខេត្តស្វាយរៀង។ យើងមានកូនចំនួន៣នាក់ គឺស្រី២នាក់ និងប្រុស១នាក់។ ខ្ញុំនិងប្តីបានចូលរួមតស៊ូ ជាមួយខ្មែរក្រហមអស់រយៈពេលជាច្រើនឆ្នាំចាប់តាំងពីមុនពេលដែលរបបខ្មែរក្រហមទទួលបានជ័យជម្នះ។ ដំបូងឡើយយើងរស់នៅភ្នំពេញ។ ក្រោយមកយើងបានផ្លាស់ប្តូរទៅរស់នៅក្នុងខេត្តតាកែវវិញ។ នៅទីនោះខ្ញុំបានធ្វើសៀងយ៉ាងច្រើនដើម្បី ផ្គត់ផ្គង់ដល់កងទ័ពខ្មែរក្រហម។ នៅក្នុងឆ្នាំ១៩៧៥ របបខ្មែរក្រហម ទទួលបានជ័យជម្នះនិងបានឡើងកាន់កាប់អំណាចទាំងស្រុង នៅក្នុងប្រទេសកម្ពុជា។ពេលនោះខ្ញុំទទួលបានតួនាទីជាប្រធានរោងចក្រតម្បាញតំបន់២៥។ ចំណែកឯ ប្តីរបស់ខ្ញុំទទួលបានតំណែងជាលេខាតំបន់២៥។ក្រោយមកយើងបានផ្លាស់ប្តូរទៅរស់នៅឯតាខ្មៅវិញ។ខ្ញុំក៏បានបង្កើតកូនប្រុសជាទីស្រឡាញ់ម្នាក់។

កូនប្រុសរបស់ខ្ញុំ ដែលទើបតែកើត នៅដើមឆ្នាំ១៩៧៨ មានអាយុ៥ខែ។ កាលនោះ គ្រួសារខ្ញុំបានផ្លាស់ចេញពីខេត្តតាកែវ ទៅរស់នៅតំបន់២៥ ក្នុងក្រុងតាខ្មៅហើយ។ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៧៨ យោធាខ្មែរក្រហមបានមកហៅខ្ញុំចេញពីមន្ទីរដែលខ្ញុំរស់នៅ ដោយខ្ញុំបាននាំទាំងកូនប្រុ



សេក សាយ ទទួលរូបថត និងឯកសាររបស់ឪពុក

សតូចរបស់ខ្ញុំទៅជាមួយដែរ ព្រោះខ្ញុំមិនចង់បែកពីវាទេនិងមិនចង់ឲ្យកូនរបស់ខ្ញុំទៅអ្នកផ្សេងមើលថែដែរ។ ចំណែកកូនស្រីច្បងរបស់ខ្ញុំឈ្មោះសេកសាយ និងកូនស្រីបន្ទាប់របស់ខ្ញុំឈ្មោះសេកញ៉ិកហៅច្រិបមិនបានទៅជាមួយខ្ញុំទេ។ ពេលនោះកូនស្រីទាំងពីររបស់ខ្ញុំធ្វើការនៅមន្ទីរកុមារ។ ខ្ញុំមិនដឹងថាយោធាខ្មែរក្រហមនាំខ្ញុំទៅកាន់ទីណាឡើយ។ ពេលខ្ញុំទៅដល់ឃើញកន្លែងនោះមានរបងស័ង្កសីបាំង និងមានលួសបន្ទាហ៊ុំព័ទ្ធជាច្រើនជាន់។ មានអ្នកយាមអ្នកសួរប្រវត្តិរូប និងមានអ្នកថតរូបខ្ញុំ។ខ្ញុំឃើញមនុស្សជាច្រើននៅទីនោះ។ ប្តីរបស់ខ្ញុំប្រហែលជាមិនបានដឹងថាខ្ញុំ និងកូនប្រុសតូចត្រូវបានយោធាបញ្ជូនមកទីនេះទេ។ ខ្ញុំក៏មិនដឹងថា ខ្ញុំបានប្រព្រឹត្តអ្វីខុសដែរ។ខ្ញុំតក់ស្លុតយ៉ាងខ្លាំង។ខ្ញុំត្រូវបានអ្នកយាមឃុំឃាំង និងបានធ្វើទារុណកម្មខ្ញុំយ៉ាងធ្ងន់ធ្ងរ ដើម្បីបង្ខំឲ្យខ្ញុំឆ្លើយ។ ខ្ញុំប្រហែលជាមិនរស់ទេ។ ចំណែកកូនប្រុសតូចរបស់ខ្ញុំត្រូវបានបំបែកទៅដាក់នៅកន្លែងផ្សេង។ កូនប្រុសរបស់ខ្ញុំនៅជាមួយខ្ញុំរហូតចាប់តាំងពីវាកើតមក។ ខ្ញុំអាណិតកូនប្រុសរបស់ខ្ញុំខ្លាំងណាស់។ខ្ញុំក៏មិនដឹងថាកូនប្រុសរបស់ខ្ញុំបាននរណាមើលថែទេ។ កូនប្រុសរបស់ខ្ញុំមិនស៊ាំនឹងអាកាសធាតុនៅខាងក្រៅឡើយ ហើយនៅមន្ទីរឃុំឃាំងនេះមានក្លិនស្អុះស្អាបដូច្នេះនឹងធ្វើឲ្យកូនរបស់ខ្ញុំឈឺមិនខាន។ ខ្ញុំ បានសួរឆ្មាំគុកពីដំណឹងកូនរបស់ខ្ញុំ ប៉ុន្តែ ឆ្មាំគុកមិនបានប្រាប់ទេ ហើយថែមទាំងសំឡុតនិងគំរាមកំហែងខ្ញុំទៀត។

ខ្ញុំខ្សោយកម្លាំង និងចុះស្គមដោយសារជំងឺទាស់ព្រោះឆ្មាំគុកបានធ្វើទារុណកម្មខ្ញុំ និងមិនឲ្យអាហារហូបគ្រប់គ្រាន់។ខ្ញុំប្រហែលជាលែងបាន ឃើញមុខកូនប្រុសរបស់ខ្ញុំទៀតហើយ។ខ្ញុំក៏បារម្ភខ្លាចកូនប្រុសរបស់ខ្ញុំ មិនស្គាល់មុខឪពុកនិងបងស្រីរបស់វា។

## កូនស្រីពីរនាក់ដែលបែកគ្នា



*សេក សាយ ទទួលរូបថត និងឯកសាររបស់ឪពុក*

នៅពេលយោធាបញ្ជូនខ្ញុំមកទីនេះ កូនស្រីច្បងពីរនាក់ទៀតរបស់ខ្ញុំមិនបានស្នាក់នៅក្នុងផ្ទះ នៅក្រុងតាខ្មៅជាមួយខ្ញុំទេ។ពេលនោះកូនស្រីទីមួយ ឈ្មោះសេក សាយ មានអាយុប្រហែល១១ឆ្នាំត្រូវបានយកទៅផ្ញើនៅមន្ទីរពេទ្យសំប៉ាន ដែលមានទីតាំងនៅខេត្តកណ្តាល។ មន្ទីរពេទ្យសំប៉ាន ជាកន្លែងផលិតថ្នាំពេទ្យនិងព្យាបាលអ្នករបួសដាច់ដៃដាច់ជើងដែលត្រូវបានបញ្ជូនពីសមរភូមិប្រយុទ្ធមកព្យាបាលនៅទីនោះ។ ចាប់តាំងពីកូនរបស់ខ្ញុំសេកសាយធ្វើការ និងស្នាក់នៅមន្ទីរពេទ្យសំប៉ានវាមិនដែលមានឱកាសបាន មកលេងខ្ញុំទេ។ចំណែកឯកូនស្រីម្នាក់ទៀត ឈ្មោះសេកញឹកហៅប្រិបធ្វើការនៅកងកុមារ។ កូនស្រីច្បងនិងកូនស្រីទី២ របស់ខ្ញុំប្រហែលជាមិនបានដឹងអំពីហេតុការណ៍ដែល យោធាខ្មែរក្រហមចាប់បញ្ជូនខ្ញុំមកឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ឡើយ។ ខ្ញុំអាណិតនិងបារម្ភពីកូនស្រីរបស់ ខ្ញុំខ្លាំងណាស់ព្រោះមិនដឹងថា កូនរបស់ខ្ញុំនឹងស្វែងរកខ្ញុំដល់ទីណា ហើយត្រូវជួបប្រទះនូវរឿងអ្វីខ្លះ? បើទោះបីខ្ញុំត្រូវអង្គការសម្លាប់យ៉ាងណាក៏ដោយ ប៉ុន្តែខ្ញុំចង់ឲ្យកូនៗរបស់ខ្ញុំទទួលបានដំណឹងពីខ្ញុំ។



រូបថតរបស់ សេក សាត ដែលក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានយកទៅជូន សេក សាយ ដែលជាកូនស្រីរបស់គាត់

មិនអាចទប់ទឹកភ្នែកបានឡើយនៅពេលគិតទៅដល់វាសនាកូនស្រីរបស់ខ្ញុំទាំងពីរនាក់ទៀតដែលនឹងអាចត្រូវបានយោធាចាប់បញ្ជូនមកឃុំឃាំងដូចខ្ញុំ និងកូនប្រុសតូចរបស់ខ្ញុំដែរៗអង្គការប្រាកដជា មិនលើកលែងឲ្យវាឡើយសូម្បីតែកូនប្រុសតូចរបស់ខ្ញុំ ដែលមានអាយុទើបតែ៥ខែ ក៏ត្រូវអង្គការចាត់ទុកថាខ្មាំងដែរៗ ខ្ញុំ និងប្តីរបស់ខ្ញុំចូលបដិវត្តន៍ជាមួយខ្មែរក្រហមតាំងពីមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានដឹងពី

រឿងទាំងអស់នេះច្បាស់ណាស់ ប្រសិនបើឪពុកម្តាយត្រូវអង្គការចោទថាជាខ្មាំង ហើយនោះកូនក៏ត្រូវបានចាត់ទុកថាខ្មាំងដូចគ្នាដែរ។ ប្តីរបស់ខ្ញុំក៏ប្រហែលជាជាប់ទោសពីបទក្បត់បដិវត្តន៍ដូចខ្ញុំដែរ ហើយអង្គការនឹងមិនលើកលែងឲ្យគាត់ឡើយ។ ក្រុមគ្រួសាររបស់ខ្ញុំនឹងមិនអាចគេចផុតពីការតាមចាប់ខ្លួនឡើយ។

និងគ្មានទីពឹងពាក់ស្នាក់អាស្រ័យឡើយ។

ចាប់ពីពេលយោធាខ្មែរក្រហម បញ្ជូនខ្ញុំមកមន្ទីរឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ ខ្ញុំពុំត្រូវបានដោះលែងឲ្យដើរចេញក្រៅទេ។ ខ្ញុំត្រូវទទួលរង នូវទារុណកម្ម យ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយជាប្រចាំ។ ខ្ញុំមិនសង្ឃឹមថាខ្ញុំនិងកូនប្រុសដែលយោធាបញ្ជូនមកឃុំនៅគុកនេះ អាចគេចផុតពីសេចក្តីស្លាប់



*សេក សាយ និង កូនស្រីច្បងរបស់គាត់*

កូនស្រីច្បងនិងកូនស្រីបន្ទាប់របស់ខ្ញុំ គឺជាក្មេងដែលពិបាកក្នុងការហូបចុកហើយថែមទាំង ខស្សរាហ៍ឈឺញឹកញាប់ទៀត។នៅពេលកូនរបស់ខ្ញុំឈឺម្តងៗខ្ញុំតែងតែបញ្ជូនពួកគេទៅមន្ទីរពេទ្យ ដើម្បីព្យាបាលជំងឺនិងមើលថែពួកគេដោយផ្ទាល់ ប៉ុន្តែចាប់ពីពេលនេះទៅខ្ញុំលែងមានឱកាសបានមើលថែពួកគេទៀតហើយ។ កូនរបស់ខ្ញុំទាំងពីរនាក់នឹងទៅជាក្មេងកំព្រាឡើយ។ខ្ញុំក៏នឹកអាល័យដល់ប្តី និងកូនស្រីរបស់ខ្ញុំពីរនាក់ទៀតដែលនឹងត្រូវព្រាត់ប្រាស់លែងបានឃើញមុខរបស់ខ្ញុំជារៀងរហូត។

អង្គការនឹងមិនលើកលែងឲ្យ កូនស្រីរបស់ខ្ញុំទាំងពីរនាក់ឡើយទោះបីជាពួកវាធ្វើការ នៅកន្លែងផ្សេងក៏ដោយ។ចំណែកប្តីរបស់ខ្ញុំក៏ប្រហែលជាមិនអាច គេចផុតពីសេចក្តីស្លា

ប់ដែរព្រោះកងសួរចម្លើយបាន បង្ខំខ្ញុំឲ្យឆ្លើយទម្លាក់កំហុសលើគាត់ទោះបីគាត់មិនបានក្បត់អង្គការបដិវត្តន៍ក៏ដោយ។ខ្ញុំមិនបានដឹងពីរឿងរ៉ាវ និងការងារជាប្រចាំថ្ងៃរបស់ប្តីខ្ញុំច្បាស់លាស់ទេ ព្រោះយើងត្រូវលាក់ការណ៍សម្ងាត់រៀងៗខ្លួន។ប៉ុន្តែដោយសារខ្ញុំមិនអាចទ្រាំទ្រនឹងទារុណកម្ម ដ៏ធ្ងន់ធ្ងរ និងសាហាវយោរយៅពីកងសួរចម្លើយទើបខ្ញុំរៀបរាប់ពីសកម្មភាពការងាររបស់គាត់ និងអ្នកផ្សេងទៀត ដែលខ្ញុំស្គាល់ដែលរឿងរ៉ាវរបស់ខ្ញុំរៀបរាប់ខ្លះមិនមែនជាការពិតឡើយ។

ចាន់ គឹមស្រ៊ុន ប្រហែលជាមិនបានដឹងថាប្តីរបស់គាត់ត្រូវបានអង្គការចាប់ខ្លួនបញ្ជូនមកឃុំឃាំង សួរចម្លើយនិងសម្លាប់នៅមន្ទីរសន្តិសុខស-២១(គុកទួលស្លែង) ដូចគាត់ទេ។ ខាងក្រោមនេះគឺជាការៀបរាប់របស់ប្តីគាត់ប្រាប់ទៅកងសួរចម្លើយ៖

ខ្ញុំឈ្មោះ សេក សាត ហៅនិន ឈ្មោះបដិវត្តន៍ហៅប្រាក់ នាទីលេខាតំបន់២៥ មានស្រុកកំណើតនៅភូមិតាប៉ោ ឃុំសំឡី ស្រុកកំពង់រោទិ៍ខេត្តស្វាយរៀង។ ខ្ញុំមានប្រពន្ធឈ្មោះ ចាន់ គឹមស្រ៊ុន ព្រមទាំងមានកូនបីនាក់ស្រីពីរនាក់ និងប្រុសម្នាក់។ មុនអង្គការចាប់បញ្ជូនខ្ញុំ មកមន្ទីរសន្តិសុខស-២១ (គុកទួលស្លែង)នៅឆ្នាំ១៩៧៨ខ្ញុំបានធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ជាច្រើនដូចខាងក្រោម ៖

### សកម្មភាពមុនឆ្នាំ១៩៧០

កាលពីកុមារភាពខ្ញុំរៀនសូត្រ បានត្រឹមថ្នាក់ទី៧ក្នុងសង្គមចាស់។ប្រាំពីរខែក្រោយនៃ ការឈប់រៀនរបស់ខ្ញុំមានអាចារ្យម្នាក់ឈ្មោះ ចាន់សុខា ហៅរ៉ាបានទៅបង្រៀនភាសាបាលីនៅស្រុកកំណើតរបស់ខ្ញុំ។ ពេលនោះ គាត់បានស្នើសុំម្តាយខ្ញុំយកខ្ញុំមកបន្តការសិក្សានៅទីក្រុងភ្នំពេញ។ កាលនោះគឺជាឆ្នាំ១៩៦៤។ខ្ញុំបានមករៀននៅភ្នំពេញក្នុងសាលាឯកជនមួយមានឈ្មោះថាវិទ្យាល័យតារាវិជ្ជាសាស្ត្រ ដោយស្នាក់អាស្រ័យនៅវត្តមហាមន្ត្រីជាមួយតាអាចារ្យ ចាន់ សុខា ផ្ទាល់។ អំឡុងពេលដែលខ្ញុំស្នាក់នៅវត្តខ្ញុំ តែងតែទិញកាសែតអាននៅក្នុងកុដ្ឋិជាញឹកញាប់។ ក្រៅពីអានកាសែតខ្ញុំបានចូលរួមស្តាប់ការពិភាក្សាអំពីនយោបាយ ដោយមាន ព្រះសង្ឃពីវត្តស្រះចកវត្តលង្កាវត្តកោះ និងវត្តកំសាន្តចូលរួម។ លោកបានលើកយករឿងរ៉ាវទំនាស់ ក្នុងសង្គមកម្ពុជាមកពិភាក្សា។ក្រៅពីនេះក៏ជជែកអំពីលទ្ធិកុម្មុយនីស្ត និងលទ្ធិលោកសេរីដែរ។ តាមរយៈការចូលរួមស្តាប់របស់ ខ្ញុំបានធ្វើឲ្យខ្ញុំមានពន្លឺខាងនយោបាយមួយកម្រិតថែមទៀត។

នៅឆ្នាំ១៩៦៥អាចារ្យម៉ែនស៊ុនអាចារ្យចាន់ សុខា និងសុខហេងបានហៅខ្ញុំមកប្រជុំ។ ក្នុងអង្គប្រជុំម៉ែន ស៊ុបាននិយាយអំពីចលនានៅប្រទេសកម្ពុជា គឺមានចលនារបស់គណបក្សប្រជាជនកម្ពុជាចលនា របស់គណបក្សប្រជាធិបតេយ្យនិងចលនាតស៊ូរបស់ខ្មែរក្រហម។ ចលនាទាំងបីនេះមានទិសដៅមាគ៌ាប្រហាក់ប្រហែលគ្នា ប៉ុន្តែពេលនេះ ម៉ែនស៊ុនបានលើកយកតែគណបក្សប្រជាធិបតេយ្យមកនិយាយតែប៉ុណ្ណោះ។ ពីឆ្នាំ១៩៦៦ ដល់ឆ្នាំ១៩៦៧ ខ្ញុំបានប្រឡងជាប់ឌីប្លូមនិងបានផ្លាស់មកបន្តការសិក្សានៅវិទ្យាល័យពញាយ៉ាត។បួនខែក្រោយមកខ្ញុំបានជួបសិស្សថ្នាក់ទី៣។ការជួបនេះខ្ញុំបានលើកយកព្រឹត្តិការណ៍បាតុកម្មដេញ លន់ នល់ចេញពីតំណែងទៅកាន់សិស្សទាំងនោះ។ គោលបំណងនៃការនិយាយនេះគឺខ្ញុំចង់ដឹងថាតើ មានសិស្សណាខ្លះដែលបានចូលរួមដើម្បីងាយស្រួលបោសសម្អាត។ ក្រោយមក អាចារ្យចាន់សុខាបានខ្ទេសនាមខ្ញុំឲ្យធ្វើការជាមួយជា។

ខ្ញុំបានធ្វើការជាមួយជា អស់រយៈពេលមួយខែទើបជាណែនាំខ្ញុំឲ្យស្គាល់តាម៉ាប់ហៅឆយ។ ចាប់តាំងពីពេលនោះមកខ្ញុំបានធ្វើការជាមួយ ឆយ រហូតមក។ មិនយូរប៉ុន្មានឆយបានហៅខ្ញុំ និងជាទៅប្រជុំដើម្បីដាក់ផែនការ។ ផែនការនោះគឺរកវិធីបំផ្លាញកម្លាំងបដិវត្តន៍ ដែលបាចត្រាក់ និងឃោសនាវាយប្រហារកុម្មុយនីស្តវាយប្រហារ ចលនាតស៊ូបដិវត្តន៍និងវាយប្រហារចលនាខ្មែរក្រហម។ ក្រោយពីទទួលបានផែនការរួចមកខ្ញុំបានយកផែនការនោះ ទៅអនុវត្តនៅក្នុងសាលា។ តាមរយៈការឃោសនាអប់រំនេះខ្ញុំ អប់រំយុវជន និងសិស្សបានចំនួនពីរនាក់គឺមានឈ្មោះសារឿន និងយុាំ។ រីឯជាក៏អប់

វិសិស្សបានចំនួនពីរនាក់ដែរគឺមានឈ្មោះនារី ហ៊ុន និងនារី លីវ។

នៅខែមករា ឆ្នាំ១៩៦៨ អង្គការបានចាត់តាំងខ្ញុំឲ្យទៅខាងកើតទន្លេបាសាក់។ ពេលនោះ ឆយបាននាំខ្ញុំទៅច្បារអំពៅដើម្បីខទ្វេសនាមឲ្យសួន ហៅសែនស្គាល់ដោយណែនាំថានេះគឺជាខ្មែរសេ.អ៊ី.អាដែរ សូមធ្វើការជាមួយគ្នាតទៅ។ ក្រោយពីនេះឆយ បានណែនាំខ្ញុំឲ្យរកដីមួយកន្លែងខាងកើតទន្លេពីស្ពានផ្ដោះទៅកោះធំដើម្បីសាងសង់ផ្ទះ។ មួយខែក្រោយមកខ្ញុំបានសាងសង់ផ្ទះស្ថិតនៅ ភូមិព្រែកប្រា ឃុំព្រែកថ្មី ស្រុកកៀនស្វាយ។ ក្រោយមកឆយបានលើកផែនការឲ្យខ្ញុំនិងសួនធ្វើសកម្មភាពស្រាវជ្រាវរកស្ទួលបដិវត្តន៍បង្កប់នៅទីនេះ ។ខ្ញុំបានព្យាយាមឃោសនាអប់រំប្រជាជន ដើម្បីឲ្យជឿជាក់លើបដិវត្តន៍។រហូតដល់ចុងខែឧសភា ឆ្នាំ១៩៦៩ ខ្ញុំបានធ្វើជីវទស្សន៍ជូនអង្គការ។ ពេលមកដល់ភ្នំពេញ ខ្ញុំបានចូលចំផ្ទះនីរសារ។ ពេលនោះខ្មាំងក៏ចាប់ខ្ញុំហើយ ឆែកឆេរឃើញឯកសារជីវទស្សន៍និងបានសួរចម្លើយខ្ញុំប៉ុន្តែខ្ញុំមិនបានឆ្លើយប្រាប់ទេរហូតឈានដល់ការធ្វើទារុណកម្មហើយអូសខ្ញុំចូលបន្ទប់ឃុំឃាំង។ ក្រោយឃុំឃាំងខ្ញុំពីរថ្ងៃ ខ្មាំងបានសួរចម្លើយខ្ញុំម្ដងទៀតពេលនោះ ខ្ញុំបានឆ្លើយសារភាពជូនខ្មាំងគ្រប់កិច្ចការទាំងអស់ដែលធ្លាប់ធ្វើកន្លងមក។ ក្រោពីនេះខ្ញុំក៏បានសារភាពអំពីកម្លាំងបដិវត្តន៍ ដែលខ្ញុំស្គាល់មានឈ្មោះ វ៉ាន់ សុក និងនីរសារឆយជាដើម។ក្រោយសួរចម្លើយចប់ ខ្ញុំបានជួបសារឿននៅក្នុងគុក។ កាលនោះសារឿន បានខទ្វេសនាមខ្ញុំឲ្យស្គាល់អ្នកជាប់គុកទាំងអស់សុទ្ធតែខ្មែររយៈរបស់ ឆយ និង មានភ្នាក់ងារសេ.អ៊ី.អាមានឈ្មោះគីមព្រឹងហៅផលនាទីនីរសារនៅកងពល៩០២។ ថាច់ សុចិតរី ហៅប៉ែនវណ្ណានាទីនីរសារនៅកងពល១១និង នារីឡុង ម៉ាមីរិតហៅមាន។ នៅអំឡុងពេលជាប់ឃុំឃាំងខ្ញុំ និងសារឿន បានធ្វើសកម្មភាពបំបែកកម្លាំងជាពីរផ្នែកដោយមួយផ្នែកតូច គឺជាកម្លាំងរបស់នារីឡុងម៉ាមីរិត និងមួយផ្នែកធំធ្វើសកម្មភាពបំបែកកម្លាំងបដិវត្តន៍ដែលជាប់គុកឲ្យទន់ខ្សោយ។

## សកម្មភាពចន្លោះពីឆ្នាំ១៩៧០-១៩៧៥

មួយរយៈក្រោយមកមានមេគិញម្នាក់ឈ្មោះសួងសិទ្ធិបានសួរខ្ញុំថាតើចង់ចេញពីគុកដែរឬទេ? ខ្ញុំឆ្លើយថាចង់។ សួងសិទ្ធិបានសួរទៀតថាប្រសិនបើចង់រួចខ្លួនគឺ ខ្ញុំត្រូវស្រាវជ្រាវរកកម្លាំងខ្មែរក្រហមដែលធ្វើសកម្មភាពនៅកន្លែងណាគឺត្រូវរាយការណ៍ប្រាប់គាត់។ ប្រាំពីរខែក្រោយមក ខ្ញុំត្រូវបានបញ្ជូនបន្តមកគុកព្រៃស។ ខ្ញុំជាប់ឃុំឃាំងនៅគុកព្រៃសអស់រយៈពេលបួនខែទើបខ្មាំងបាន ដោះលែងខ្ញុំក្រោយពេលរដ្ឋប្រហាររួច។ នៅខែឧសភា ឆ្នាំ១៩៧០ អង្គការបានចាត់តាំងខ្ញុំឲ្យមកនៅព្រែកប្រា និងតំបន់២៥។ នៅអំឡុងពេលនោះ ឆយបានណែនាំខ្ញុំថាត្រូវរៀបចំមូលដ្ឋាន នៅព្រែកប្រាឲ្យទៅជាបង្អែករបស់យើង។ ក្រោពីនេះ ព្យាយាមកសាងកម្លាំងយុវជនយុវនារីឲ្យបានច្រើន ដើម្បីបញ្ជូនទៅបង្កប់ក្នុងជួរបដិវត្តន៍ហើយត្រូវធ្វើសកម្មភាពឲ្យបានយូរអង្វែងតទៅទៀត។ ក្រោយការជួបគ្នារយៈពេលដប់ថ្ងៃឆយ បានទៅព្រែកប្រាដើម្បីប្រជុំដាក់ផែនការដូចតទៅ៖ ទី១) រៀបចំកម្លាំងសេ.អ៊ី.អាឲ្យបានគ្រប់កន្លែងក្នុងស្រុកកៀនស្វាយ ទី២) ត្រូវទប់ទល់កម្លាំងប្រជាជន និងបំបែកកម្លាំងប្រជាជនកុំឲ្យទៅខាងបដិវត្តន៍ឬជឿជាក់ទៅលើ បដិវត្តន៍ឲ្យសោះគឺត្រូវ រកវិធីឃោសនាអប់រំរារាំងគ្រប់បែបយ៉ាង។ប្រហែលមួយខែក្រោយមក ឆយបានធ្វើដំណើរចុះតាមតំបន់រំដោះស្ពានកោះធំ ហើយបានឆ្លៀតចូលប្រាប់ខ្ញុំថាកងកម្លាំង ដែលធ្វើដំណើរកាត់តាមនេះមានពីរផ្នែកមួយផ្នែកគឺជា កងកម្លាំងរបស់បក្សវៀងមួយផ្នែកទៀតគឺជាកម្លាំងរបស់យើង។ ក្រោយពីទទួលបានផែនការរួចមក ខ្ញុំបានយកមកអនុវត្តដោយ រៀបចំកម្លាំងឈរជើងនៅកៀនស្វាយនិងបញ្ជូនទៅខាងក្រោមជាហូរហែរ។ ក្រោពីនេះខ្ញុំចេញទៅធ្វើសកម្មភាពឃោសនា អប់រំ ប្រជាជនដោយនិយាយវាយប្រហារបំបែកកម្លាំងរណសិរ្សរបស់បក្ស។

នៅខែកញ្ញាឆ្នាំ១៩៧០ ដោយស្ថានការណ៍មិនអនុគ្រោះនៅខាងព្រែកប្រាខ្ញុំក៏សម្រេចចិត្ត ចុះទៅតំបន់រំដោះ។ ពេលនោះឆយបានប្រគល់ភារកិច្ចឲ្យ ខ្ញុំធ្វើជាសមាជិកនគរ

បាលតំបន់២៥។ឆយ បានបញ្ជាក់អំពីបញ្ហាខ្លះៗថាសភាពការផ្ទៃក្នុងមិនឯកភាពគ្នានោះទ ព្រោះក្នុងនោះមានកែវសំផនធ្វើជាទីប្រឹក្សា។ ចំពោះបក្ខពួករបស់ សុខប៊ុតចំរើនក៏ត្រូវគ្នាជាមួយយួនខ្លាំងណាស់ ដោយពួកនេះចង់បានអំណាចរៀងៗខ្លួន។ ដូច្នេះ ពេលចុះធ្វើការគឺត្រូវក្តាប់មហាជន និងត្រូវចេះធ្វើការវាយប្រហារគ្រប់វិធី។ បន្ទាប់ពីខ្ញុំធ្វើការបានប្រាំពីរថ្ងៃក៏មានព្រឹត្តិការណ៍ យួនបាញ់សម្លាប់ កែវ សំផន។ លើសពីនេះទៀតសុខ និងចំរើនក៏បានចាប់បងសម្បត្តិយកទៅសម្លាប់ និងបានចាប់ឆយយកទៅឃុំឃាំងនៅព្រៃល្វាៗរីឯនីរសាររបស់ ឆយ ឈ្មោះណារិន និងខែមត្រូវបានចាប់ឃុំឃាំងនៅស្រុកកោះធំ។ ក្រោយមក ក៏បានចាប់សមមិត្តលីនិងខ្ញុំឃុំឃាំងទៀត។ មិនយូរប៉ុន្មានបងឌុច(តំណាងបក្សនៅស-២១) និងមហាជនបានធ្វើការតវ៉ាទើបព្រមដោះលែងខ្ញុំនិងសមមិត្តលីវិញ។ តមកទៀតសុខបានប្រគល់ភារកិច្ចឲ្យខ្ញុំធ្វើការនៅរោងពុម្ពមួយកន្លែង។ ពេលនោះ ខ្ញុំបានបំផុសឲ្យមហាជនបំផ្លាញក្រដាសបំផ្លាញទឹកថ្នាំ និងសម្ភារនៅក្នុងរោងពុម្ពជាច្រើន។

នៅឆ្នាំ១៩៧១ខ្ញុំ បានទៅភូមិភាគនិរតីហើយអង្គការបានចាត់តាំងខ្ញុំឲ្យដឹកនាំនៅតំបន់៣៣។ នៅពេលដែលខ្ញុំទៅដល់ព្រៃល្វាបានរយៈពេលប្រាំពីរថ្ងៃ ទើបខ្ញុំបានជួបជាមួយ ឆយ នៅក្នុងផ្ទះប្រជាជនហើយឆយក៏បានសួរខ្ញុំអំពីសភាពការណ៍នៅតំបន់២៥ថា តើយ៉ាងដូចម្តេចដែរ។ ខ្ញុំបានរាយការណ៍ពីសកម្មភាពជាក់ស្តែងជូន ឆយ រហូតដល់ចប់ៗ ក្រោយមក ឆយ បានហៅខ្ញុំដើម្បីខទ្ទេសនាមឲ្យស្គាល់ខ្សែរយៈសេ.អ៊ី.អា ដែលមកពី តំបន់២៥ បន្ថែមទៀតមានឈ្មោះដោក, ប៉ូឡូញ ហៅ សាត,ហឹមរ៉េតហៅសានិត,វុធធីហៅម៉េងនិងនារីឡុងសុផល។ ក្រោយពីខទ្ទេសនាមរួចមក ឆយ បានចាប់ផ្តើមបើកវគ្គរៀនសូត្រ ដោយមានអ្នកចូលរួមមានឈ្មោះប៉េងគ្រី មកពីវប្បធម៌តំបន់៣៣ តាភនគណៈស្រុក៥៥ព្រមទាំងមាននីរសារពីរនាក់ផ្សេងទៀត។ រីឯខ្ញុំបាននាំបងប្អូនមកដល់ផ្លូវលេខ៣ពេលនោះ ម៉ែន ស៊ិន ប្រធានរណសិរ្សស្រុកសំរោងបានចេញមក ទទួលខ្ញុំហើយរៀបចំកន្លែងឲ្យសម្រាក។ នៅព្រឹកថ្ងៃបន្ទាប់អុន និងឆយបានជិះម៉ូតូមកជួបខ្ញុំដើម្បីប្រាប់ឲ្យនារីៗទៅសម្រាកនៅមន្ទីរតំបន់វិញ។ លើសពីនេះទៀតឆយបានប្រាប់ថាអង្គការនឹងប្រគល់អាវុធនិងកងទ័ពផងដែរ។ មិនយូរប៉ុន្មាន អុន និងឌុចបានធ្វើដំណើរមកជួបខ្ញុំដើម្បីសួរថាតើកម្លាំងសរុបមានប៉ុន្មាន ជាពិសេសកម្លាំងសេ.អ៊ី.អា។ពេលនោះ ខ្ញុំក៏បានរាយឈ្មោះជូនអុននិងឌុចដូចតទៅ៖ គឺមានឈ្មោះដោក,វុធធី,គឹម,សានិត,ប៉ូឡូញ,ជឿន,ស៊ុយ,នារីសយ,នារីមាយ,នារីឡុងសុផល,នារី គ្រប់និងខ្ញុំ។

រហូតដល់ ឆ្នាំ១៩៧២ ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យទទួលតួនាទីជាស្នងការវរសេនាតូចលេខ១៩ ក្នុងតំបន់៣៣។ នៅក្នុងវរសេនាតូចនេះ មានគណៈមេបញ្ជាការបីនាក់មានឈ្មោះវុទ្ធី,ម៉ុន និងខ្ញុំ។ បន្ទាប់មក អុនបានខទ្ទេសនាមខ្ញុំឲ្យស្គាល់ខ្សែរយៈសេ.អ៊ី.អានៅកងវរៈផ្សេងទៀត គឺមានឈ្មោះហមបញ្ជាការវរសេនា១១ តំបន់៣៣សយ អនុបញ្ជាការវរៈ១១ក្រោយវរៈ៣៣០និរតីអួងអនុសេនាធំ ក្នុងវរៈ១១ក្រោយអនុវរៈ៣៣០ទូចស្នងការវរៈ១៧ តំបន់៣៣ និងកឿនស្នងការវរៈ១៥តំបន់៣៣។នៅពាក់កណ្តាលឆ្នាំ១៩៧២ តាស៊ីបានបញ្ជូន ហ៊ូយន់ ទៅធ្វើប្រធាននៅតំបន់៣៣វិញ។លុះដល់យប់ឡើង តាស៊ីបានប្រជុំសំណេះសំណាលជាមួយអុន,ឌុច,ឃឹម,នារីជឹម និងខ្ញុំ។ ក្នុងការប្រជុំសំណេះសំណាលនេះតាស៊ីបានលើកពីបញ្ហារបស់បក្សពីរ គឺមានបក្សកុម្មុយនីស្តកម្ពុជានិងបក្សពលករកម្ពុជា។

នៅចុងឆ្នាំ១៩៧២ អង្គការបានណែនាំឲ្យវាយសម្រុកចូលតំបន់ខ្មាំងគ្រប់ទីកន្លែង ប៉ុន្តែ ខ្ញុំបានលើកនូវមតិថាយើងគួរវាយខ្មាំងល្មមៗ បានហើយព្រោះការវាយសម្រុកពីឥឡូវក៏មិនអាចឈ្នះខ្មាំងបានដែរ។ ម្យ៉ាងទៀតទាហាន លន់នល់ មានសុទ្ធតែយន្តហោះរថក្រោះកាំភ្លើងតូចធំគ្រប់ធុន។ ដល់ឆ្នាំ១៩៧៣ ខ្ញុំទទួលបានមុខងារជាស្នងការវរសេនាតូច១៣៤ភូមិភាគនិរតី។ ក្រោយមក ខ្ញុំបានហៅក្រុមខ្ញុំមកប្រជុំដើម្បីដាក់ផែនការរុករានខ្មាំង កាន់តែខ្លាំងឡើងរួមទាំងរដូវប្រាំ

ផនិងវស្សា។ រាល់ផែនការ របស់បដិវត្តន៍ទាំងអស់យើងត្រូវតែបំផ្លាញចោល។ ក្នុងអង្គប្រជុំបានកំណត់ឲ្យតាសៀង និងសំអាតទៅទាក់ទងពូមឿន នៅភូមិស្នំក្រពើឃុំស្នំក្រពើតំបន់៣៣ព្រោះពូមឿន គឺជាអ្នកធ្លាប់ចេញចូលនៅត្រាំខ្នាដើម្បីងាយស្រួលទាក់ទងសក្តិបីខ្ទយនៅ បន្ទាយត្រាំខ្នានេះ។

ចំពោះការទាក់ទងនេះគឺ បានរាយការណ៍ឲ្យខ្ទយចំនួនបីលើកដោយលើកទីមួយរាយការណ៍អំពីការ រាតត្បាតកម្លាំងមកតំបន់រំដោះ។ លើកទីពីររាយការណ៍ពីកម្លាំងដែលចុះតាមផ្លូវលេខ៣ទៅក្បាលថ្នល់វត្តប្រាសាទ។ និងលើកទីបីរាយការណ៍កម្លាំងដែលចុះចន្លោះពីផ្លូវលេខ២ និងលេខ៣ដើម្បីអុកឡុកកងកម្លាំងខាងកើតត្រាំខ្នា។ សកម្មភាពមួយទៀតនៅពេលដែលខ្ញុំទៅដល់ភូមិភាគ ខ្ញុំបានបំផុសឲ្យកម្មាភិបាលនិងយុទ្ធជនៅកង១៣៤ទាស់ទែងជាមួយកង១៨០ ដែលជាកងភូមិភាគចាស់ៗការធ្វើបែបនេះក្នុងគោលបំណងឲ្យ កងទ័ពមិនអាចសហការគ្នាបានរឹងមាំនិងកុំឲ្យជឿទុកចិត្តគ្នា។ ក្រោយមកអង្គការលើកទិសរំដោះផ្លូវលេខ២ ពេលនោះខ្ញុំបានសួរសមមិត្តម៉ុននិងភឿនថា តើយើងគួររកវិធីបំផ្លាញផែនការនេះយ៉ាងដូចម្តេចដែរ?

ទោះជាយ៉ាងណា អង្គការបានកំណត់រួចហើយថាត្រូវបំផ្លាញគ្រប់វិធី។ អង្គការបានចាត់តាំងកងពលខ្ញុំមកទប់ជំនួយនិងតាមដានស្តាប់វិទ្យុ ដើម្បីរាយការណ៍។ ខ្ញុំបានរាយការណ៍ថាឥឡូវខ្មាំងពង្រីកមុខបានចំនួន៤ម៉ែត្រ ហើយប៉ុន្តែយើងត្រូវមានកម្លាំងជំនួយបន្ថែមប្រសិនបើមិនដូច្នេះទេកម្លាំងកងពលខ្ញុំមិនអាចទប់ទល់បានឡើយ។ គណៈបញ្ជាការសមរភូមិឮដូចនេះក៏ប្រញាប់ដកទ័ពចេញវិញ។ ពេលកងពលខ្ញុំដកចេញទៅខ្មាំងបានវាយសម្រុក ចូលដល់ផ្លូវលេខ២ទើបកងពលយើងហ៊ុំព័ទ្ធចាប់បានទាំងអស់ៗរីឯកងពលទី៧ចេញពីថ្នល់លេខ២ពេលនោះអុន បានស្កាត់មកជួបខ្ញុំ ដើម្បីរាយការណ៍អំពីទុក្ខលំបាករបស់បដិវត្តន៍ ព្រោះសកលលោកលែងឧបត្ថម្ភដោយគេងាកទៅខាងចរចា។ ពេលនោះ អាមេរិកបានទម្លាក់គ្រាប់បែកកាន់តែខ្លាំងឡើង ដើម្បីបង្ខំឲ្យបដិវត្តន៍ចរចា។ ដូច្នេះ ឈរលើសកម្មភាពនេះ យើងត្រូវធ្វើសកម្មភាពអូសទាញជាបុគ្គលក្តីអូសទាញ ជាអង្គភាពក្តីជាពិសេសអូសទាញកុំឲ្យបដិវត្តន៍ទៅសមរភូមិមុខទៀត។ ក្រៅពីនេះបំភ័យអំពីរឿងយន្តហោះបេ៥២ និងអេស១១១។ សរុបសេចក្តីមកគឺធ្វើសន្តិសម្ព័ន្ធ ដើម្បីផ្តួលគោលជំហរកងទ័ពបដិវត្តន៍។

ក្រោយទទួលផែនការនេះហើយខ្ញុំ បានយកទៅផ្សាយឲ្យសមមិត្តម៉ុន,ភឿន,តាសៀង និងវ៉ាណាក់ ដើម្បីអនុវត្តឲ្យបានទាន់ពេលវេលា។ ខ្ញុំ ខំរកគ្រប់វិធីធ្វើយ៉ាងណាអូសទាញយុទ្ធជន និងកម្មាភិបាលឲ្យងាកទៅខាងចរចា។ នៅខែវិច្ឆិកាឆ្នាំ១៩៧៣អង្គការចាត់តាំងខ្ញុំឲ្យ ទទួលស្នងការវរសេនាធំលេខ១២ដោយនៅក្នុងកងនេះមាន៤វរសេនាតូចគឺមានកងពល៣៤០,៣៥០,៤០១,និង៤០៥។ ក្រោយមកខ្ញុំបានជួបសំណេះសំណាលជាមួយកងនីមួយៗថា នៅពេលធ្វើសកម្មភាពត្រូវប្រុងប្រយ័ត្នកុំឲ្យកង៤០៥ ចាប់ចំណុចខ្សោយបានឲ្យសោះប្រសិនបើកងនេះចាប់ចំណុចខ្សោយបានច្បាស់ជាបែកការហើយ។ មួយខែក្រោយមក អង្គការបានចាត់តាំងឲ្យអង្គភាពខ្ញុំវាយសម្រុកចូលសមរភូមិ តាមផ្លូវលេខ៤។ពេលនោះខ្ញុំបានប្រាប់ទៅកងពល៣៥០ ថាប្រសិនបើមានខ្មាំងវាយសម្រុកចូលទោះបី ថ្មើរជើងក្តីឬរថក្រោះក្តីមិត្តត្រូវបំផុសឲ្យយុទ្ធជនដកចោលខ្សែត្រៀម ដើម្បីរំខានផែនការរំដោះផ្លូវលេខ៤។រហូតដល់ខែមករាឆ្នាំ១៩៧៤អង្គការបានបើកសមរភូមិភ្នំពេញពេលនោះខ្ញុំបានប្រជុំជាមួយសមមិត្តម៉ុន,ភឿន,សំអាត,សឿន,ធី និងភួន។ ខ្ញុំបានរាយការណ៍អំពីផែនការរបស់បក្ស គឺរំដោះភ្នំពេញ។ ដូច្នេះ វាគឺជាផែនការដែលយើងត្រូវបំផ្លាញចំពោះការរំដោះភ្នំពេញ ដោយកងនីមួយៗត្រូវម្ចាស់ការប្រសិនបើខ្មាំងវាយសម្រុកចូល យើងត្រូវបំផុសឲ្យយុទ្ធជននិងកម្មាភិបាលដក និងរត់ចូលខ្សែត្រៀម។ នៅពេលវាយខ្មាំងខ្ញុំតែងតែធ្វើការរាយការណ៍ តាមវិទ្យុជាញឹកញាប់ជូនគណៈបញ្ជាការសមរភូមិ។ បំណងនៃការរាយការណ៍នេះដើម្បីឲ្យខ្មាំងចាប់ចំណុចខ្សោយបាន ហើយកងទ័ពក៏បានដកថយជាហូរហែ។សកម្មភាពមួយទៀត អង្គភាពរបស់

ខ្ញុំបានបំផុសឲ្យយុទ្ធជនមិនចូលខ្មែរគ្រៀមជាច្រើន ដោយបំផុសថាមិត្តណាមិនស្រួលខ្លួនអាចទៅសម្រាក នៅមន្ទីរពេទ្យបាន។ កាលនោះកងកម្លាំងមួយវរសេនាធំរបស់ខ្ញុំបានបំផុសឲ្យយុទ្ធជនចូលទៅដេកពេទ្យជិត២០០នាក់។

ក្រោយមក ខ្ញុំបានចេញពីសមរភូមិ ភ្នំពេញ ដោយអង្គការបានលើកទិសទៅវាយរំដោះទីក្រុងកំពត។ ខណៈនោះ ខ្ញុំបានហៅសមមិត្តម៉ុន,គឿន, សឿន និងសំអាតមកប្រជុំដាក់ផែនការដើម្បី បំផ្លាញគម្រោងរំដោះក្រុងកំពត។ សកម្មភាពនោះគឺវាយទីតាំងខ្លាំងនៅចំពោះមុខ កុំឲ្យសម្រេចបានឲ្យសោះគឺយើងត្រូវបន្លំធ្វើជាបាញ់ឆាវៗ ឲ្យឮសូរស្នូរកាំភ្លើង ប៉ុន្តែកុំឲ្យចំទីតាំងខ្មាំង។ ក្រៅពីនេះ មិនឲ្យលើកខ្មែរគ្រៀមទៅមុខឡើយ។ មិនតែប៉ុណ្ណោះ ក៏បានបំផ្លាញគ្រាប់រំសេវជាច្រើនដោយបាញ់ពាសវាលពាសកាល និងបំផុសឲ្យរត់ចោលសមរភមិទៀតផង។ នៅពេលវាយចូល សមរភូមិកំពត ខ្ញុំបានជួបជាមួយអុនព្រោះអង្គការហៅគាត់មកជួប។ ពេលជួបខ្ញុំអុនសួរខ្ញុំ ថាតើសម្រេចឬទេចំពោះសមរភូមិកំពតនេះ? ខ្ញុំបានឆ្លើយថាទៅមិនរួចទេព្រោះមុខសញ្ញាផែនការរំដោះនៅឆ្ងាយខ្លាំងណាស់។ អុន បានបញ្ជាក់ប្រាប់ខ្ញុំថាឥឡូវធ្វើយ៉ាងណាកុំឲ្យសម្រេច។ បន្ទាប់មក អង្គការបានចាត់តាំងខ្ញុំឲ្យចាកចេញ ពីសមរភូមិកំពតផ្លាស់ទៅឈរជើងនៅវាលវេញ និងកោះកុង។ ពេលនោះ ខ្ញុំបានហៅសមមិត្តម៉ុន,គឿនភួន,សំអាត,គ្រន,រ៉ាណាក់ និងសៀងមកប្រជុំ ដើម្បីជ្រើសរើសកម្លាំងដាក់ផែនការឲ្យអនុវត្តជាបន្តបន្ទាប់។ រហូតដល់ខែកក្កដាក្នុងឆ្នាំដដែលអង្គការបានឲ្យខ្ញុំ ចេញពីកោះកុងវិញ។មួយខែក្រោយមកខ្ញុំត្រូវបាន អង្គការចាត់តាំងឲ្យធ្វើជាអនុលេខាតំបន់៣៣ ដោយទទួលភារកិច្ចដាច់ដោយឡែកគឺខាងយោធា។ ពេលខ្ញុំមកដល់តំបន់៣៣ ខ្ញុំបានឆ្លៀតចូលប្រាប់សមមិត្តម៉ុនថាយើងនឹងបន្តការទាក់ទងគ្នាដដែល។ នៅខែធ្នូឆ្នាំ១៩៧៤ពេលទទួលបានផែនការពីបក្សថា រំដោះភ្នំពេញ និងរំដោះប្រទេសកម្ពុជាទាំងស្រុងក្នុងឆ្នាំ១៩៧៥ ខាងមុខនេះខ្ញុំក៏បានហៅចិត្ត,បូ,ឈាន,ឆេង,ផាត,សុផៃ និងនារីវ៉េងមកប្រជុំដើម្បីដាក់ផែនការតទៅទៀត។

## សកម្មភាពចន្លោះពីឆ្នាំ១៩៧៥ រហូតដល់ចាប់ខ្លួន

បន្ទាប់ពី ខ្មែរក្រហមទទួលបានជ័យជម្នះ លើកងកម្លាំងសាធារណរដ្ឋខ្មែរនៅខែមេសា ឆ្នាំ១៩៧៥ ពេលនោះកងកម្លាំងរបស់នារីវ៉េងនិងកងកម្លាំងរបស់ផាតបានធ្វើសកម្មភាពដុតផ្ទះប្រជាជនអស់៣០ខ្នង និងបានបំផ្លាញសម្ភារជ័យភណ្ឌជាច្រើនផ្សេងទៀត។ នៅមុនពេលរៀបចំរំដោះអង្គការបានណែនាំរួចហើយថា ចំពោះសម្ភារជ័យភណ្ឌដែលប្រមូលពីភ្នំពេញទាំងអស់អ្នករាល់គ្នា ហាមប៉ះពាល់ឲ្យសោះ គឺទុកឲ្យអង្គការជាអ្នកចាត់ចែងនិងដោះស្រាយជូន។ ពេលនោះខ្ញុំបានប្រាប់នីរសារនា ពេលឥឡូវនេះឆាប់ទៅដញ្ជូនឡានថ្នាំពេទ្យនិងសម្ភារផ្សេងទៀតដែលដឹកមកពីភ្នំពេញ ត្រូវយកមករក្សាទុកក្នុងតំបន់យើងដើម្បី ប្រើប្រាស់នៅថ្ងៃខាងមុខ។ ក្រោយរំដោះបានកន្លះខែរួចមក អង្គការចាប់ផ្ដើម លើកផែនការបោសសម្អាតពួកបណ្ដាសក្តិភូមិ។ ក្នុងពេលនោះដែរខ្ញុំបានលើកឡើង ក្នុងអង្គប្រជុំគណៈស្រុកថា តើយើងមានកម្លាំងឯណាគ្រប់គ្រាន់ដើម្បី បោសសម្អាតពួកសក្តិភូមិទាំងនេះលុះត្រាតែមានការជ្រំជ្រែងពីកម្លាំង មូលដ្ឋានជួយទើបអាចសម្រេចបាន។ ពេលនោះ កម្លាំងមូលដ្ឋានមួយចំនួនបានធ្វើសកម្មភាពពាសវាលពាសកាល បណ្ដាលឲ្យប្រជាជនមានការភ្ញាក់ផ្អើល រហូតដល់រត់ចេញពីភូមិមួយទៅភូមិមួយជាហូរហែ។

រីឯខ្ញុំបានទៅព្រៃល្វាជាមួយបងចុងហើយក៏បានជួបសួង និងសិទ្ធិដែលស្នាក់នៅផ្សារខាងលិចព្រៃល្វា។ ក្រោយមកខ្ញុំនិងបងចុងក៏បានបន្តដំណើរឆ្ពោះទៅមន្ទីរស្រុក៥៥។ ប៉ុន្មានថ្ងៃក្រោយមកហមអនុលេខាស្រុក៥៥ បានមកជួបខ្ញុំនៅមន្ទីរពាពាបាននិយាយប្រាប់ខ្ញុំថា មានអ្នកជម្លៀសម្នាក់ស្នាក់នៅផ្សារព្រៃល្វាស្គាល់ខ្ញុំ ប៉ុន្តែអ្នកជម្លៀសនេះ ត្រូវបានបញ្ជូនទៅរស់នៅភូមិខ្វែងគគង់ឃុំកំពង់រាប រួចទៅហើយព្រោះនៅខាងលិចព្រៃល្វា មានប្រជាជនរស់នៅច្រើនកុះករទើបត្រូវបែងចែកប្រជាជនបណ្ដាក់តាមឃុំនីមួយៗ។ មុននឹងខ្ញុំវិលត្រឡប់

ទៅតំបន់២៥វិញខ្ញុំបានជួបតាស៊ី ចំនួនពីរដងដោយលើកទីមួយខ្ញុំបានជួបគាត់នៅមន្ទីរស្រុកជាំសង្កែ និងលើកទីពីរនៅវិទ្យាល័យកំពង់ស្ពឺ។ ក្នុងការជួបនេះតាស៊ីបាននិយាយប្រាប់ខ្ញុំថា យើងត្រូវធ្វើសកម្មភាពបែបជាក់ស្តែង គឺប្រឆាំងបំផ្លិចបំផ្លាញបង្កការអុកឡុក ដើម្បីបង្កើតភាពចលាចល និងរារាំងដល់ចលនាតស៊ូបដិវត្តន៍តទៅទៀត។ រហូតដល់ខែមិថុនាឆ្នាំ១៩៧៥ អង្គការបានចាត់តាំងខ្ញុំឲ្យទទួលតួនាទីជាអនុលេខាតំបន់២៥។

ក្រោយមកយាយលីប្រពន្ធតាស៊ី បានធ្វើដំណើរមកតាខ្មៅដោយយកកូនខ្ញុំ ដែលរស់នៅជាមួយគាត់មកជាមួយផង។ពេលនោះយាយលី, ជា និងខ្ញុំក៏បានបើកអង្គប្រជុំសំណេះសំណាលអំពីការងារដែលតាស៊ី បានផ្តាំផ្ញើតាមរយៈប្រពន្ធរបស់គាត់។ យាយលីបានឲ្យដឹងថា ខ្ញុំត្រូវធ្វើការទាក់ទងឲ្យជាប់ជាមួយជានាពេលខាងមុខព្រោះជា និងតាស៊ីគ្មានអ្វីខុសគ្នានោះទេ។ក្រោយពីនេះ ខ្ញុំក៏ត្រូវទាក់ទងជាមួយតាសៀនដែលមកពីកំពង់ត្រាចផ្លាស់ មកនៅតំបន់២៥ នេះដែរ។ ចាប់តាំងពីពេលនោះមកខ្ញុំ និងជាចាប់ផ្តើមទាក់ទងគ្នា។ជាចាប់ផ្តើមឲ្យឧទ្ទេសនាមគណៈស្រុកមួយចំនួនឲ្យខ្ញុំបានស្គាល់ដើម្បីកាន់តែងាយស្រួលធ្វើការ។ ជាបាននិយាយថាមានគណៈស្រុកខ្លះគឺជាកម្លាំងរបស់គាត់ផ្ទាល់ ហើយគណៈស្រុកខ្លះទៀតគឺជាកម្លាំងចាស់របស់ជ័យរបស់ចំរើន,សុខ និងសេ។ ខ្ញុំសូមជម្រាបជូនបក្សបន្ថែមទៀតថា កាលពីចុងខែវិច្ឆិកាឆ្នាំ១៩៧៥ គឺជាពេលដែលខ្ញុំ មករៀននៅសាលាបក្សហើយបក្សបានរៀបចំធ្វើសន្និបាតសេដ្ឋកិច្ច។ ពេលនោះ ខ្ញុំបានជួបជាមួយតាស៊ីក្នុងសន្និបាតនេះ។ ខ្ញុំនិងតាស៊ីបានពិគ្រោះអំពីសកម្មភាពដែលធ្លាប់បានធ្វើកន្លងមក អស់រយៈពេលប្រហែល១០នាទីរួចក៏វិលត្រឡប់ទៅកន្លែងរៀងៗខ្លួនវិញ។

នៅដើមឆ្នាំ១៩៧៦ ជាបានណែនាំអំពីផែនការដូចតទៅនេះ៖ឥឡូវបក្សកុម្មុយនីស្តកម្ពុជា បានប្រកាសអំពីមាគ៌ាបន្តបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម។ដូចនេះផែនការយើងគឺត្រូវបំផ្លាញ រារាំងចលនានេះកុំឲ្យទៅមុខ។ បន្ទាប់ពីណែនាំរួចខ្ញុំ បានយកផែនការនេះទៅណែនាំបន្តខាងស្រុកកោះធំ និងតាមមន្ទីរព្រមទាំងកងទ័ព។ ម្យ៉ាងទៀតហាមប្រាមមិនឲ្យប៉ះពាល់ដល់ កងទ័ពវៀតណាមនៅតាមព្រំដែនដែលជា សម្ព័ន្ធមិត្តយើងតាំងតែពីពេលមុន និងទៅថ្ងៃអនាគត។ នៅខែឧសភា ក្នុងឆ្នាំដដែលខ្ញុំបានជួបជាមួយឆយ នៅស្ថានីយ៍អគ្គិសនីចាក់អង្រែ។ ពេលនោះ ឆយសួរខ្ញុំ ថាតើយ៉ាងម៉េចចំពោះសភាពការនៅតំបន់២៥នេះ? ខ្ញុំឆ្លើយប្រាប់ឆយវិញថា អង្គការបានបោសសម្អាតខ្សែចំរើន,សុខនិងសេអស់ជាច្រើនរួចមកហើយ។ ចំពោះការទាក់ទងរបស់ខ្ញុំសព្វថ្ងៃនេះគឺជាមួយជាផ្ទាល់តែម្តង។ ដល់ខែកក្កដាឆ្នាំ១៩៧៦ជ័យបានធ្វើដំណើរមកស្រុកកោះធំហើយបានឆ្លៀតចូលសួរសុខទុក្ខខ្ញុំ។ ក្នុងឱកាសនោះដែរខ្ញុំក៏បានសួរជ័យថាតើជ័យឯងអញ្ជើញមកមានការអ្វីដែរ? ពេលនោះជ័យបានឆ្លើយតបវិញថាខ្ញុំមករកស្រូវពូជក្រមួនស៤-៥បាវ។ ក្រៅពីនេះជ័យបានសួរត្រឡប់មកខ្ញុំវិញថា តើសកម្មភាពប្រជាជននិងកម្មាភិបាលយ៉ាងម៉េចដែរ? ស្រាប់តែពេលនោះ ខ្ញុំបានឆ្លើយតាមរបៀបគោលជំហរបដិវត្តន៍ថា គ្មានបញ្ហាអ្វីនោះទេរួមទាំងប្រជាជនចាស់និងប្រជាជនថ្មី។ មិនយូរប៉ុន្មានជ័យក៏វិលត្រឡប់ទៅវិញរីឯខ្ញុំ ក៏បានរៀបចំដំណើរទៅប្រជុំដំណាច់ខែប៉ុន្តែមិនទាន់ដល់គោលដៅផង ស្រាប់តែឡានបែកកង់។ ខ្ញុំក៏បានទៅសម្រាកនៅកន្លែងតាសៀនលេខាស្រុកស្អាង។លុះព្រឹកឡើងទើបយើងបន្តដំណើរទៅជាមួយគ្នា។ អំឡុងពេលដែលខ្ញុំស្នាក់នៅមួយយប់ខ្ញុំ បានឆ្លៀតពេលសំណេះសំណាលជាមួយតាសៀនជាច្រើនហូរហែរ ទើបខ្ញុំបានដឹងថាតាសៀនគឺជាខ្សែរយៈរបស់តាស៊ី ដែលបានឧទ្ទេសនាមឲ្យស្គាល់ជាសមាជិកបក្សពលករ។ ពីរបីខែក្រោយមកខ្ញុំទទួលបានភារកិច្ចទៅខេត្តកំពត ដើម្បីជួបតាផនសួរអំពីផែនការប្រឆាំងនិងរារាំងបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមនេះ។ ក្រោយពីប្រជុំដំណាច់ខែរួច ហើយខ្ញុំបានវិលត្រឡប់មកសម្រាកនៅតាខ្មៅវិញតាមទម្លាប់ចាស់។ នៅពេលមកដល់តាខ្មៅខ្ញុំតែងតែប្រជុំជាមួយជាជាញឹកញាប់ ដោយលើកអំពីប

ក្សពលករមកនិយាយជាហូរហែរ។ ក្រោយពីនិយាយអំពីបញ្ហានេះចប់ជាសួរខ្ញុំថា កាលពីថ្ងៃមុនមានឃើញជ័យចុះទៅក្រោមដែរឬទេ? ខ្ញុំបានឆ្លើយថាឃើញហើយបានចូលកន្លែងខ្ញុំដែរប៉ុន្តែមិនបាននិយាយអ្វីច្រើននោះទេ គ្រាន់តែសួរខ្ញុំអំពីសភាពប្រជាជននិងកម្មាភិបាលតែប៉ុណ្ណោះ។ ជាបានបន្តថាជ័យទៅនេះក្នុងគោលបំណង ក្តាប់សភាពការណ៍ប្រជាជនដើម្បីធ្វើការវាយប្រយុទ្ធនាពេលខាងមុខ។ ក្រោយមកខ្ញុំបានធ្វើការណែនាំពីវិធីអនុវត្តធ្វើយ៉ាងណា បំផ្លាញឧបករណ៍កសិកម្មដោយប្រើមធ្យោបាយតូចធំក្តី ដែលទាក់ទងខាងផ្នែកកសិកម្មដែលអាចបំផ្លាញបាន។ រីឯការងារធ្វើស្រែចម្ការវិញខ្ញុំបានណែនាំមិនឲ្យពង្រាបដីខ្លាំងពេកទេ ព្រោះដីស្រុកទន្លេមិនដូចដីស្រុកស្រែនោះទេ។ ចំពោះសកម្មខាងលើនេះខ្ញុំតែងតែណែនាំជាញឹកញាប់។

នៅខែកញ្ញាឆ្នាំ១៩៧៦ជាបានហៅខ្ញុំនិងតាសៀនទៅណែនាំថានៅពេលបុណ្យខួបបក្សខាងមុខនេះយើងនឹងរៀបចំធ្វើរដ្ឋប្រហារ។ ចំពោះរដ្ឋប្រហារនេះ គឺយើងសម្រេចយកប្រជាជនពីខាងតំបន់យើងដើម្បីធ្វើបាតុកម្ម។ រីឯកន្លែងផ្សេងៗគឺរៀបតាមមុខសញ្ញាដាច់ដោយឡែកពីគ្នា។ មុខសញ្ញាខាងយើង គឺត្រូវទៅតាមផ្លូវលេខ១ និងតាមផ្លូវតាខ្មៅនេះ។ ដូច្នេះស្នើត្រៀមរៀបចំផង។ បន្ទាប់ពី ទទួលបានផែនការរួចហើយខ្ញុំក៏បានយកផែនការទាំងនេះ ទៅផ្សព្វផ្សាយទៅដល់មូលដ្ឋានតាមស្រុកកោះធំតាមមន្ទីរ និងកងទ័ព។ មុនថ្ងៃបុណ្យខួបបីថ្ងៃខ្ញុំបាន ធ្វើដំណើរមកជួបជាមួយជានៅ តាខ្មៅដើម្បីទទួលផែនការលម្អិត។ ពេលជួបជាគាត់បានប្រាប់ថាមិនទាន់ទទួលការណែនាំថ្មីទៀតទេ។ ខ្ញុំរង់ចាំផែនការនេះរហូតដល់ជិតមួយខែទើបដឹងថាផែនការនេះ គឺបែកការណ៍ហើយ។ឥឡូវនេះអង្គការចាប់ផ្តើម បោសសម្អាតជាបន្តបន្ទាប់។ ក្រោយពេលឮដំណឹងនេះខ្ញុំបានវិលទៅធ្វើការងារបដិវត្តន៍ជាធម្មតាវិញ។រហូតដល់ខែវិច្ឆិកា ក្នុងឆ្នាំដដែលខ្ញុំបានមករៀនវគ្គសិក្សារបស់បក្ស។ ពេលនោះខ្ញុំបានជួបជាមួយឆយហើយគាត់បានសួរខ្ញុំពីសភាពនៅតំបន់២៥ យ៉ាងដូចម្តេចដែរ? ខ្ញុំបានឆ្លើយថាអង្គការនៅ តែបោសសម្អាតខ្សែបំរើន,សុខជាបន្តបន្ទាប់។ ម្តងឃើញឈ្មោះនេះឯម្តងទៀត ឃើញឈ្មោះនោះ។ប៉ុន្តែឈ្មោះទាំងអស់នោះ ខ្លះក៏ចាប់បញ្ជូនទៅអង្គការរួចរាល់ហើយ។ ឆយ បានបន្តថាត្រូវព្យាយាមការពារកម្លាំងចាស់ប្រយ័ត្នបែកការណ៍។ចំពោះការទាក់ទងខ្សែរយៈនៅខាងបូព៌ាវិញ គឺត្រូវផ្អាកមួយរយៈសិនព្រោះអង្គការកំពុងបោសសម្អាតជុំវិញ រឿងរ៉ាវរដ្ឋប្រហារនៃថ្ងៃបុណ្យខួបបក្ស។ ឆយ បានបន្តទៀតថាបដិវត្តន៍សង្គមនិយមនាពេលឥឡូវនេះគឺកាន់តែជ្រាលជ្រៅ ហើយដូច្នេះ ការងារត្រូវប្រុងប្រយ័ត្នឲ្យបានមែនទែន និងត្រូវខំប្រឹងប្រែងកសាងកម្លាំងសេ.អុី.អាឲ្យបានច្រើនថែមទៀត។

តាមការឃោសនាអប់រំជាបន្តបន្ទាប់កន្លងមកនេះ ខ្ញុំបានអប់រំមានឈ្មោះដូចតទៅ៖ឈ្មោះកែម,ប៉ាក,ស្រី,ទួន,នារីសុខា,នារីមុំ,នារីម៉ុន,នារីថៃ,នារី ផាត,នារីមឿននិងនារីអុន។ កម្លាំងទាំងនេខ្ញុំបានអប់រំកសាងហើយបានចាត់តាំងជាភ្នាក់ងារ សេ.អុី.អារួចហើយដែរព្រមទាំងបានធ្វើសកម្មភាពប្រឆាំង និងបំផ្លាញបដិវត្តន៍ជាហូរហែរតាមផែ្នករបស់ពួកគេដូចជា នៅតាមមន្ទីរពេទ្យដោយបំផ្លាញថ្នាំពេទ្យចាក់ថ្នាំធ្វើឲ្យអាប់សែ និងវះកាត់ឲ្យមានគ្រោះថ្នាក់រហូតដល់ស្លាប់។ នៅខាងតម្បាញគឺត្រូវបំផ្លាញអំបោះបំផ្លាញកីធ្វើឲ្យយឺតយ៉ាវមិនគ្រប់ផែនការរបស់អង្គការ។ចំពោះខាងម៉ាស៊ីនកិនស្រូវត្រូវបំផ្លាញស្រូវអង្ករ និងម៉ាស៊ីនកិនស្រូវ។ រីឯខាងការដ្ឋានវិញណែនាំឲ្យបំផ្លាញឧបករណ៍កសិកម្មនិងបំផ្លាញស្រូវពោតជាដើម។

នៅឆ្នាំ១៩៧៧ បក្សកុម្មុយនីស្តកម្ពុជាបានលើកគោលការណ៍វាយសម្រុកបោសសម្អាតខ្លាំង យ៉ាងខ្លាំងក្លាខុសពីឆ្នាំមុនៗទាំងអស់។ ជាពិសេសបោសសម្អាតខ្លាំងស៊ីរូងផ្ទៃក្នុងក្នុងបក្សគ្រប់ជាន់ថ្នាក់។ ក្រោយមកជាបានរាយការណ៍មកថាខ្សែរយៈសេ.អុី.អារបស់យើងត្រូវបានអង្គការបោសសម្អាតអស់ជាច្រើនរួចមកហើយ រួមទាំងផ្នែកថ្នាក់ក្បាលម៉ាស៊ីនដឹកនាំ និងថ្នាក់ក្រោមៗតមកទៀត។ដូច្នេះស្ថានការ

ណ៍ប្រែប្រួលមួយកម្រិតថែមទៀតៗ ដូចនៅតំបន់យើងបក្សក៏បានបោសសម្អាតជាបន្តបន្ទាប់ដែរៗ ដល់ខែមីនា ក្នុងឆ្នាំដដែលនេះជាបានហៅខ្ញុំទៅជួបនៅតាខ្មៅ ដើម្បីដាក់ផែនការតទៅទៀតៗផែនការដែលប្រជុំនោះគឺត្រូវបំផុសឲ្យឃើញពីសន្តមសមូហភាពរបស់បក្សកុម្មុយនីស្ត លំបាកគ្រប់ផ្នែកគ្មានអ្វីល្អជាងឯកជននោះទេៗ ជាពិសេស ត្រូវបំផុសយ៉ាងម៉េចធ្វើឲ្យប្រជាជនអស់ជំនឿលើសមូហភាពៗ ខ្ញុំបានធ្វើសកម្មភាពទាំងនេះជាហូរហែរ និងជាបន្តបន្ទាប់ដើម្បីប្រឆាំងនឹងអង្គការបដិវត្តន៍ៗនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ អង្គការបានចាត់តាំងខ្ញុំឲ្យទទួលតួនាទីលេខាតំបន់២៥ រហូតដល់អង្គការចាប់ខ្លួនខ្ញុំបាននៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧៨ៗ

**កូនស្រីម្នាក់របស់ចាន់គីមស្រ៊ុនក្នុងចំណោមកូនទាំងបីនាក់ដែលនៅរស់រានមានជីវិត បានរៀបរាប់ថា ៖**

ខ្ញុំឈ្មោះ សេក សាយ ហៅសេកសុធី គឺជាកូនស្រីច្បងក្នុងចំណោមបងប្អូនបីនាក់ៗ ខ្ញុំមានឪពុកឈ្មោះសេកប្រាក់និងម្តាយឈ្មោះ ចាន់គីមស្រ៊ុន ហៅ សាងៗឪពុកម្តាយរបស់ខ្ញុំបានបម្រើការជាកងទ័ពខ្មែរក្រហម តាំងពីមុនពេលកងទ័ពខ្មែរក្រហមឡើងកាន់អំណាចៗ

ឪពុករបស់ខ្ញុំ មានសប្បុរស្រអែមប៉ុន្តែមិនសូវខ្ពស់នោះទេៗ គាត់ជាមនុស្សម្នាក់ចូលចិត្តនិយាយលេងសើចច្រើននៅក្នុងគ្រួសារហើយកូនៗនិងប្រពន្ធស្រឡាញ់គាត់ណាស់ៗ ចំណែក ឯម្តាយរបស់ខ្ញុំមានសប្បុរសរាងស្គមស្តើងនិងកម្ពស់ខ្ពស់ៗខ្ញុំរស់នៅជាមួយគាត់ច្រើនជាងរស់នៅជាមួយឪពុករបស់ខ្ញុំៗ នៅពេលឪពុកម្តាយរបស់ខ្ញុំបម្រើការនៅស្រុកត្រាំខ្នារ(បច្ចុប្បន្នស្រុកបាទី)ខេត្តតាកែវខ្ញុំត្រូវបានជីដូនឈ្មោះយាយលី និងជីតាឈ្មោះតាស៊ី អតីតលេខាភូមិភាគបស្ចិមយកទៅចិញ្ចឹមនៅឯខេត្តកំពង់ស្ពឺៗ យូរៗម្តងទើបឪពុករបស់ខ្ញុំមកយកខ្ញុំទៅលេងផ្ទះម្តងៗ ពេលខ្ញុំទៅលេងផ្ទះនៅខេត្តតាកែវម្តងៗ ខ្ញុំឃើញម្តាយខ្ញុំ ធ្វើសៀងយ៉ាងច្រើនសម្រាប់ផ្គត់ផ្គង់ដល់កងទ័ពៗចំណែកឪពុករបស់ខ្ញុំបានចេញធ្វើការបាត់ៗតាំងពីព្រលឹម ហើយពេលល្ងាចទើបត្រឡប់មកផ្ទះវិញៗ

មានពេលមួយខ្ញុំបានធ្លាក់ខ្លួនឈឺធ្ងន់ ជីដូនរបស់ខ្ញុំក៏បានបញ្ជូនខ្ញុំឲ្យទៅព្យាបាលនៅឯមន្ទីរពេទ្យ ក្រុងកំពង់សោមៗពេលដឹងដំណឹងថាខ្ញុំនៅឯមន្ទីរពេទ្យម្តាយរបស់ខ្ញុំបានទៅយកខ្ញុំមកព្យាបាលនៅក្នុងក្រុងភ្នំពេញវិញ ដែលមានទីតាំងក្បែរស្ពានព្រះមុន្នីវង្សៗ ស្នាក់នៅឯមន្ទីរពេទ្យក្នុងក្រុងភ្នំពេញខ្ញុំមិនសូវមានអ្វីហូបនោះទេៗ ពេលជាសះស្បើយហើយខ្ញុំបានសុំម្តាយទៅរស់នៅជាមួយជីដូននៅឯខេត្តកំពង់ស្ពឺវិញៗ

មួយរយៈក្រោយមកឪពុកម្តាយរបស់ខ្ញុំ បានផ្លាស់មករស់នៅឯក្រុងតាខ្មៅវិញហើយក៏បានយកខ្ញុំ មកនៅជាមួយដែរៗពេលមកដល់ខ្ញុំឃើញម្តាយរបស់ខ្ញុំបង្កើតបានកូនប្រុសម្នាក់ទៀតៗ ម្តាយរបស់ខ្ញុំបានសួរខ្ញុំថាតើដាក់ឈ្មោះឲ្យប្អូនថាម៉េច? ខ្ញុំក៏ប្រាប់គាត់វិញថាខ្ញុំស្រឡាញ់ឈ្មោះវណ្ណៈៗ ប៉ុន្តែរហូតមកដល់សព្វថ្ងៃនេះខ្ញុំមិនដឹងថា ម្តាយរបស់ខ្ញុំបានដាក់ឈ្មោះឲ្យប្អូនប្រុសរបស់ខ្ញុំអ្វីឡើយៗ រយៈពេលពីរបីខែនៅផ្ទះក្នុងក្រុងតាខ្មៅពេលដែលម្តាយរបស់ខ្ញុំសរសេរខ្ទី គាត់តែងតែប្រាប់ឲ្យខ្ញុំទៅបើករបបអាហារហូប ប៉ុន្តែខ្ញុំមិនហ៊ានទៅបើករបបអាហារហូបទៀងទាត់នោះទេ ព្រោះខ្ញុំមិនបានធ្វើការងារដូចគេៗ ឃើញដូច្នេះឪពុកម្តាយរបស់ខ្ញុំបានយកខ្ញុំទៅផ្ញើនៅរោងសិប្បកម្មតម្បាញមួយរយៈ ដើម្បីឲ្យខ្ញុំមានការងារធ្វើនឹងគេ និងទទួលបានរបបអាហារៗ ក្រោយមកឪពុកម្តាយរបស់ខ្ញុំបានយកខ្ញុំទៅផ្ញើនៅមន្ទីរពេទ្យសំប៉ានវិញៗ

ឪពុកម្តាយរបស់ខ្ញុំបានយកខ្ញុំទៅផ្ញើ ខាងផ្នែកផលិតឱសថគ្រាប់ព្រោះក្នុងផ្នែកនេះមានកុមារី ធ្វើការប្រហែលជា៣០នាក់និងគ្រូពេទ្យចំណាស់៧៤-៥នាក់ គឺជាអ្នកមើលការខុសត្រូវលើកុមារនិងការផលិតថ្នាំគ្រាប់ៗមីងរបស់ខ្ញុំឈ្មោះវ៉ិនក៏ធ្វើការនៅទីនោះដែរៗ នៅក្នុងចំណោមកុមារទាំងនោះខ្ញុំមានអាយុតិចជាងគេៗ ពេលថ្ងៃខ្ញុំ និងកុមារីផ្សេងទៀតនាំគ្នាសែងសម្បកដបទៅលាងទឹកទន្លេៗ ភារកិច្ចរបស់ខ្ញុំគឺគ្រាន់តែឈរចាំចុចយកគ្រាប់ថ្នាំ ដែលធ្លាក់ចេញពីម៉ាស៊ីនសង្កត់ថ្នាំបន្ទាប់មកប្រមូលយកគ្រាប់ថ្នាំដែលផលិតបានទៅហាលថ្ងៃឲ្យស្ងួតៗ ពេលទំនេរពីការងារ ខ្ញុំបានយកបន្លែទៅលាងសម្រា

ប់ចុងក្រោយកទៅធ្វើម្ហូប។ នៅទីនោះខ្ញុំទទួលបានរបបបាយគ្រប់គ្រាន់។

ចាប់តាំងពីធ្វើការនិងស្នាក់នៅមន្ទីរពេទ្យ នោះមកខ្ញុំមិនដែលមានឱកាសទៅលេងឪពុកម្តាយ នៅក្រុងតាខ្មៅឡើយ។ ថ្ងៃមួយ នៅវេលាប្រហែលម៉ោង៥ល្ងាចមានបុរសម្នាក់បានមកទទួលខ្ញុំចេញពីមន្ទីរពេទ្យ។ ខ្ញុំស្គាល់ថាបុរសនោះឈ្មោះខនជាអ្នកបើករថយន្តជូនឪពុក និងម្តាយរបស់ខ្ញុំ។ ខន បានប្រាប់ខ្ញុំថាអង្គការឲ្យទៅលេងឪពុកម្តាយ នៅស្រុកថ្មី ភូមិថ្មី ដូច្នេះមិនចាំបាច់យកមុងភួយទៅទេ។ ប៉ុន្តែខ្ញុំនៅជម្នះយកអីវ៉ាន់ដែលខ្ញុំមានទៅជាមួយ តាមបណ្តាំរបស់ម្តាយខ្ញុំដែលផ្តាំថា «ពេលទៅណាវេចទៅឲ្យអស់»។ ខនបានទទួលបញ្ជាពីថ្នាក់លើឲ្យនិយាយដូច្នេះដើម្បីលួងលោម ឲ្យខ្ញុំឡើងជិះរថយន្ត។ខ្ញុំត្រូវបានដឹកកាត់តាមផ្ទះរបស់ខ្ញុំ នៅក្នុងក្រុងតាខ្មៅ។ ខ្ញុំបានសុំខនដាក់ខ្ញុំចុះ ប៉ុន្តែខនប្រាប់ខ្ញុំថាឪពុកម្តាយរបស់ ខ្ញុំនៅភូមិថ្មីឯណោះ។ ខ្ញុំបានប្រកែកថាហួសផ្ទះរបស់ខ្ញុំហើយ ប៉ុន្តែខនមិនឲ្យចុះ។

ខ្ញុំបានទៅដល់មន្ទីរសន្តិសុខជ្រៃអូរញ្ញោ នៅម៉ោង៩យប់។អ្នកគ្រប់គ្រងនៅទីនោះបានឲ្យខ្ញុំហូបបាយ និងរកកន្លែងឲ្យខ្ញុំសម្រាករង់ចាំរហូតដល់ព្រឹកដើម្បីទៅរកឪពុកម្តាយ។ នៅទីនោះ ខ្ញុំ បានជួបប្អូនស្រីនិងសាច់ញាតិខាងឪពុករបស់ខ្ញុំចំនួន៤គ្រួសារ។ អ្នកទាំងអស់ត្រូវបានបញ្ជូនមកមន្ទីរសន្តិសុខនេះរយៈពេលពីរថ្ងៃមុនខ្ញុំទៅដល់។ អ្នកទាំងអស់ត្រូវបានអង្គការបែងចែកឲ្យទៅធ្វើការនៅកងផ្សេងៗគ្នានៅជាប់ជើងភ្នំខាងស្រុកជុំគិរី។ យូរៗម្តងខ្ញុំបានសុំប្រធានកងទៅលេងអ៊ំនិងម្តាយមីងដែលធ្វើការខាងជើងភ្នំ។ ចំណែកប្អូនស្រីរបស់ខ្ញុំរស់នៅក្នុងកងកុមារ។ ខ្ញុំបានសួរអ្នកនៅទីនោះស្ទើរគ្រប់គ្នាពីដំណឹងឪពុកម្តាយ។ ខ្ញុំក៏បានសួរតាខុនអ្នកគ្រប់នៅមន្ទីរសន្តិសុខនោះ ប៉ុន្តែតាខុន មិនបាននិយាយអ្វីច្រើនទេគ្រាន់តែប្រាប់ថា«ដើរទៅរកទៅឃើញហើយ»។ តាខុនមិនបានយកទោសពៃរ៍ចំពោះការដើរគ្មានវិន័យរបស់ខ្ញុំទេ ព្រោះយល់ឃើញថាខ្ញុំនៅក្មេង។ខ្ញុំតាមរកឪពុកម្តាយ ស្ទើរគ្រប់កន្លែងនៃបរិវេណមន្ទីរនោះ ប៉ុន្តែគ្មាននរណាម្នាក់ដឹងថា អ្នកទាំងពីរនៅទីណានោះទេហើយក៏មិនដឹងស្រុកថ្មី ភូមិថ្មីនៅកន្លែងណាដែរ។ខ្ញុំដើរអស់ចិត្តនៅតែមិនឃើញក៏វិលត្រឡប់មកធ្វើការនៅកងកុមារវិញ។ខ្ញុំមិនដឹងថា ជ្រៃអូរញ្ញោគឺជាកន្លែងលត់ដំនោះទេ ពេលឃើញអ៊ំរែកដីខ្ញុំបានសួរថា «អ៊ំៗពីណាឲ្យអ៊ំរែកដីខ្ញុំមិនដែលឃើញអ៊ំរែកដីទេឃើញតែអ៊ំស្រោចទឹកកកឆាយ»។ អ៊ំរបស់ខ្ញុំបាននិយាយណែនាំខ្ញុំថា «កុំសួរអ៊ំអីខំធ្វើការទៅ»។ ខ្ញុំបានប្រាប់អ៊ំរបស់ខ្ញុំថា «គេឲ្យមកលេងម៉ែនៅស្រុកថ្មី ភូមិថ្មី ហើយគេមិនឲ្យយកសម្លៀកបំពាក់មកជាមួយទេ ដល់ពេលនេះខ្ញុំដើររកតែរកមិនឃើញសោះ។ អ៊ំរបស់ខ្ញុំក៏មិនបាននិយាយប្រាប់ខ្ញុំដែរ»។

ខ្ញុំតែងតែឮកុមាររបស់អង្គការច្រៀងបទ «សុភាពរាបសារកូនអង្គការអត់មានម៉ែឪ»។ ពេលច្រៀងម្តងៗកុមារទាំងនោះសម្លឹងមើលមុខខ្ញុំជានិច្ច។ ខ្ញុំ ឆ្ងល់ហើយបានសួរទៅអ៊ំរបស់ខ្ញុំប៉ុន្តែគាត់មិនបានបកស្រាយឡើយ។ អ៊ំរបស់ខ្ញុំបានប្រាប់ខ្ញុំថា«ក្មួយកុំមាត់កុំកគេឲ្យធ្វើអ្វីធ្វើហ្នឹងទៅ»។ ខ្ញុំត្រូវបានចាត់តាំងឲ្យបេះសណ្តែកដីបោចស្មៅដំឡូងមីនិងធ្វើការងារផ្សេងៗទៀត។

នៅទីនោះខ្ញុំទទួលការយកចិត្តទុកដាក់ ពីស្ត្រីម្នាក់ឈ្មោះវ៉ាន់ដែលបម្រើការនៅក្នុងមន្ទីរនេះ និងបុរសម្នាក់ឈ្មោះខន។វ៉ាន់ធ្លាប់មើលថែនិងពខ្ញុំតាំងពីតូច។ វ៉ាន់ដឹងថាខ្ញុំគឺជាក្មេងដែលពិបាកក្នុងការហូបចុក និងខស្សរាហ៍ឈឺដូច្នេះរាល់ពេលបើករបបអាហារម្តងៗ វ៉ាន់តែងផ្តាំចុងភៅឲ្យយកម្ហូបដែលខ្ញុំហូបបានប៉ុណ្ណោះ។ ចំណែកខនតែងតែឆៀងយកផ្លែឈើផ្ញើឲ្យខ្ញុំរាល់ពេលដែលគាត់មកដឹកដីនៅបរិវេណមន្ទីរនេះ។ខនបានទុកផ្លែឈើដូចជាផ្លែមៀន និងសេដានៅអ្នកយាមតាមទម្លាប់នៅពេលគាត់មកដឹកដី នៅក្បែរនោះម្តងៗ។ គាត់បានផ្តាំអ្នកយាមថាពេលថ្ងៃខ្ញុំនឹងមកហើយ ខ្ញុំប្រាកដជាដឹងថាគាត់យកផ្លែឈើមកផ្ញើ។

នៅឆ្នាំ១៩៧៩ កងទ័ពវៀតណាម និងយោធាខ្មែរក្រហមបានផ្ទោងគ្រាប់ដាក់គ្នាធ្វើឲ្យ ប្រធានមន្ទីរសន្តិសុខរត់

គេចចេញចំណែកអ្នកផ្សេងទៀត ក៏រត់គេចពីគ្រាប់ផ្លោងដែរ។ ដោយសារភ័យខ្លាចគ្រាប់ខ្ញុំ មិនហ៊ានទៅរកសាច់ញាតិ និងបងប្អូនទេខ្ញុំ បន្តរត់ទៅមុខតាមគណៈកងរហូតដល់ពេជ្រនិល។ នៅទីនោះ ខ្ញុំបានជួបស្ត្រីមេម៉ាយម្នាក់ ឈ្មោះ អេត គុល។ គុល បានហៅខ្ញុំឲ្យរួមដំណើរត្រឡប់មកខេត្តកំពង់ស្ពឺវិញជាមួយគ្នា។ ដោយសារតែក្តីអាណិតអាសូរគុល បានយកខ្ញុំធ្វើជាកូនចិញ្ចឹមរហូតមក។

### រកឃើញរូបថតម្តាយ

ក្នុងរយៈពេលដំបូង ដែលខ្ញុំបែកពីម្តាយខ្ញុំតែងតែយំនឹកគាត់គ្រប់ពេលវេលា និងដើររកគាត់គ្រប់ទីកន្លែងប៉ុន្តែខ្ញុំមិនបានជួបនិងមិនបានទទួលដំណឹងពីគាត់ឡើយ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ម្តាយចិញ្ចឹមរបស់ខ្ញុំបានជូនខ្ញុំទៅរកម្តាយនៅខេត្តកំពង់ចាម ហើយនៅពេលដែលខ្ញុំត្រឡប់មកវិញខ្ញុំ និងម្តាយចិញ្ចឹម បានជួបគ្រោះថ្នាក់ចរាចរណ៍ដោយក្រឡាប់រ៉ឺម៉ក។ ខ្ញុំស្មានថាខ្ញុំអស់ជីវិតពេលនោះហើយ។ ទោះបីយ៉ាងណា ខ្ញុំមិនបានបញ្ឈប់ការតាមរកឪពុកម្តាយខ្ញុំត្រឹមពេលនោះឡើយ។ ក្រោយមក ខ្ញុំបានទៅស្ថានីយទូរទស្សន៍ប៉ុស្តិ៍លេខ៣ឲ្យជួយផ្សព្វផ្សាយដំណឹង ស្វែងរកឪពុកម្តាយរបស់ខ្ញុំ។ក្រោយមកខ្ញុំក៏បានទៅប៉ុស្តិ៍សំបុកឃ្មុំ ដើម្បីសុំឲ្យវិទ្យុជួយផ្សព្វផ្សាយដំណឹងនេះទៀត ប៉ុន្តែពុំទទួលបានដំណឹងពីគាត់ឡើយ។ ខ្ញុំដើរសួរអ្នកភូមិ ប៉ុន្តែអ្នកទាំងនោះនិយាយថាមិនធ្លាប់បានជួបម្តាយខ្ញុំ ទេប្រហែលជាអង្គការសម្លាប់ចោលហើយ។នៅយប់មួយ ពេលដែលខ្ញុំត្រឡប់មកពីសួរដំណឹងរកគាត់វិញ ខ្ញុំក៏បានយល់សប្តិឃើញម្តាយរបស់ខ្ញុំប្រាប់ខ្ញុំថាមិនបាច់ទៅរកគាត់ទីណាទេទៅរកគាត់នៅគុកទួលស្លែងទៅ។

នៅពេលខ្ញុំភ្ញាក់ឡើង ខ្ញុំក៏បានប្រាប់អំពីការយល់សប្តិនេះទៅកាន់ម្តាយចិញ្ចឹមរបស់ខ្ញុំ។ គាត់ក៏ប្រាប់ខ្ញុំឲ្យឈប់ដើររកតទៅទៀតព្រោះឪពុកម្តាយរបស់ខ្ញុំ ប្រហែលជាស្លាប់អស់ហើយ។ខ្ញុំចង់ដឹងពីម្តាយរបស់ខ្ញុំ ដោយខ្ញុំគិតថាទោះបីជាឪពុករបស់ខ្ញុំស្លាប់ក៏មានម្តាយនៅរស់ដែរ។

ក្រោយមកខ្ញុំក៏បានទទួលដំណឹងពីម្តាយរបស់ខ្ញុំតាមរយៈពូម្នាក់ត្រូវជាជនដូនម្តាយចិញ្ចឹមរបស់ខ្ញុំ ដែលបានអានទស្សនាវដ្តីស្វែងរកការពិត នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបានឃើញរូបថតម្តាយរបស់ខ្ញុំ ឈ្មោះ ចាន់គឹមស្រ៊ិន នៅលើទស្សនាវដ្តីនេះ។ ខ្ញុំក៏បានទាក់ទងទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយក៏បានទទួលដំណឹងពីបងប្រុសជីដូនមួយខាងឪពុកឈ្មោះ សេក សារ៉ុន ដែលបានប្រកាសស្វែងរកខ្ញុំ។

***សេក សារ៉ុន ត្រូវជាក្មួយរបស់ សេក សាត ហៅ ប្រាក់និងត្រូវជាបងជីដូនមួយរបស់សេក សាយដែលនៅរស់រានមានជីវិតបានរៀបរាប់ថា ៖***

រយៈពេល៤ថ្ងៃ បន្ទាប់ពីរបបខ្មែរក្រហមទទួលជ័យជម្នះខ្ញុំត្រូវបានឪពុកមាខាងម្តាយឈ្មោះ តាប្រាក់ មកយកខ្ញុំពីស្រុកកំពង់រោទិ៍ ក្នុងខេត្តស្វាយរៀង ទៅរស់នៅជាមួយគាត់នៅតំបន់២៥ ដែលមានទីតាំងនៅទីរួមស្រុកគាខ្មៅ ខេត្តកណ្តាល។

ខ្ញុំគឺជាក្មេងដែលមានសំណាងជាងគេ ក្នុងចំណោមក្មេងជាច្រើននាក់ទៀតនៅក្នុងភូមិ។ ភារកិច្ចដំបូងរបស់ខ្ញុំនៅមន្ទីរតំបន់២៥ គឺធ្វើជាកងការពារ និងជាអ្នកបើកឡានឲ្យតាប្រាក់។ខ្ញុំឃើញមានតែបុគ្គលិកជាង១០នាក់ ជាអ្នកធ្វើបញ្ជីឯកសារផ្សេងៗ។ក្នុងនោះមានប្រធានមន្ទីរឈ្មោះខេមរ៉ាមានស្រុកកំណើតនៅខេត្តព្រៃវែង។

នៅចុងឆ្នាំ១៩៧៥ ខ្ញុំត្រូវបានបញ្ជូនឲ្យទៅហាត់ក្បួនយុទ្ធសាស្ត្ររយៈពេលបីខែ ជាមួយយុវជនជាង១០០នាក់នៅស្រុកគាខ្មៅ ដើម្បីត្រៀមវាយជាមួយវៀតណាម។ បន្ទាប់ពីចប់វគ្គហ្វឹកហ្វឺនខ្ញុំមិនបានបញ្ជូនទៅព្រំដែនដូចយុវជនឯទៀតទេ។ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើជាកងការពារ និងនីរសាររបស់តាប្រាក់ដដែល។តាប្រាក់បាន ប្រគល់ម៉ូតូម៉ាកសេអិលឲ្យខ្ញុំមួយគ្រឿងសម្រាប់ជិះរត់សំបុត្រពីស្រុកមួយទៅស្រុកមួយនៅក្នុងភូមិភាគនិរតី។ ពេលខ្លះខ្ញុំត្រូវចុះតាមការដ្ឋានជាមួយតាប្រាក់ ដើម្បីពិនិត្យមើលប្រជាជនធ្វើស្រែលើកទំនប់ជីកប្រឡាយ និងអមដំណើរតាប្រាក់ទៅចូលរួមប្រជុំនៅមន្ទីរភូមិភាគនិរតីនិងទៅព្រំដែនវៀតណាម ដើម្បីលើកទឹកចិត្តកងទ័ពឲ្យ

មានដំហាររីងប៉ឹងក្នុងការប្រយុទ្ធជាមួយកងទ័ពវៀតណាម។

ភារកិច្ចរបស់ខ្ញុំគឺ គ្រាន់តែយកសំបុត្រទៅឲ្យលេខាស្រុកដោយផ្ទាល់ដៃ និងត្រឡប់មកវិញដោយពុំមានបង្អែបង្អង់តាមផ្លូវឡើយ។ ថ្ងៃមួយខ្ញុំបានយកសំបុត្រទៅឲ្យគណៈតំបន់១៣ក្នុងស្រុកត្រាំកក់។ ខ្ញុំបានជួបតាម៉ុកនៅតាមផ្លូវ។ដោយឃើញខ្ញុំជិះម៉ូតូបែបសង្ហាហើយមិនគោរពគាត់។ តាម៉ុកបានបញ្ជាឲ្យកងការពាររបស់គាត់ចាប់ខ្ញុំមកសួរចម្លើយ ហើយដុតម៉ូតូខ្ញុំចោលនៅចំពោះមុខខ្ញុំ។ ខ្ញុំភ័យញ័រខ្លួនចំពោះការព្រមានរបស់តាម៉ុក។តាម៉ុកបានសម្លុតខ្ញុំថា «អាណាឲ្យជិះម៉ូតូដោយគ្មានការអនុញ្ញាតយ៉ាងដូច្នេះ»? ខ្ញុំបានប្រាប់តាម៉ុកថាជានីរសាររបស់តាប្រាក់នៅតំបន់២៥និងមានភារកិច្ចយកសំបុត្រទៅឲ្យគណៈតំបន់១៣។ តាម៉ុកបានគំរាមថា «ថ្ងៃក្រោយត្រូវជិះសេះរត់សំបុត្របើមិនដូច្នេះទេ គាត់នឹងចាប់សម្លាប់ចោល»។ ខ្ញុំបានត្រឡប់មកតំបន់២៥វិញដោយថ្មើរជើងហើយប្រាប់មូលហេតុនេះដល់តាប្រាក់ ប៉ុន្តែគាត់ពុំមានមាត់កប្ញ និយាយថាម៉េចឡើយ គឺគ្រាន់តែស្តាប់ហើយនៅស្ងៀមប៉ុណ្ណោះ។

នៅក្នុងឆ្នាំ១៩៧៦ ខ្ញុំបានអមដំណើរតាប្រាក់ទៅទទួលគណៈប្រតិភូចិន ដែលមកទស្សនកិច្ចប្រទេសកម្ពុជា។ គណៈប្រតិភូនេះបានដើរទស្សនារោងចក្រ និងការដ្ឋានជីកប្រឡាយមួយចំនួននៅក្នុងតំបន់២៥។

នៅឆ្នាំ១៩៧៧ ខ្ញុំក៏ត្រូវផ្លាស់ទៅធ្វើការជាមួយតាប្រាក់នៅតំបន់១៣ក្នុងខេត្តតាកែវ។ ជាញឹកញាប់ខ្ញុំបានបើកឡានជូនតាប្រាក់ទៅចូលរួមប្រជុំ ជាមួយ តាម៉ុក នៅមន្ទីរភូមិភាគនិរតី និងសមរភូមិភ្នំដិនដើម្បីស្ទាបស្ទង់សភាពការណ៍នៅតាមព្រំដែនវៀតណាមនិងដើម្បីលើកទឹកចិត្តយុទ្ធជនទាំងអស់ឲ្យខិតខំប្រឹងប្រែងការពារមាតុភូមិ។ នៅពេលនោះតាប្រាក់គឺជាអនុប្រធានរបស់តាម៉ុកផងនិងលេខាតំបន់១៣ផង។

ខ្ញុំធ្វើការនៅតំបន់១៣មិនទាន់បានមួយឆ្នាំផងតាម៉ុកបានដកតាប្រាក់ឲ្យទៅប្រចាំការនៅតំបន់៣៣ ក្នុងខេត្តកំពង់ស្ពឺដែលមានទីតាំងនៅស្រុកត្រាំខ្នារ។ នៅទីនោះខ្ញុំមានតួនាទីមួយទៀតគឺដឹកស្បៀង និងសម្ភារសឹកទៅសមរភូមិមុខតាមបណ្តោយព្រំដែនវៀតណាម។

នៅចុងឆ្នាំ១៩៧៧ ខ្ញុំបានទទួលបញ្ជាពីតាប្រាក់ឲ្យយកសំបុត្រទៅឲ្យគណៈស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ នៅចុងឆ្នាំដដែលតាប្រាក់ក៏បានផ្លាស់មកធ្វើការនៅស្រុកតាខ្មៅ តំបន់២៥វិញ។

នៅដើមឆ្នាំ១៩៧៨ តាប្រាក់,ខ្ញុំនិងមនុស្ស៥នាក់ទៀតបានធ្វើដំណើរឆ្ពោះទៅខេត្តស្វាយរៀង។ នៅសល់ចម្ងាយតែ៧គីឡូម៉ែត្រ ដល់ព្រំដែនវៀតណាមតាម៉ុក បានហៅតាមគេអូឲ្យតាប្រាក់វិលត្រឡប់ទៅប្រជុំ នៅភូមិភាគនិរតីវិញ។ មកដល់តំបន់២៥ ខ្ញុំ និងកងការពារទាំងអស់ត្រូវបានដកហូតអាវុធតាប្រាក់ និងប្រពន្ធឈ្មោះ ចាន់ គីមស្រ៊ុន ហៅសាងព្រមទាំងកូនតូចម្នាក់ត្រូវអង្គការ ចាប់បញ្ជូន ទៅមន្ទីរសន្តិសុខស-២១។ ក្រោយពីចាប់ខ្លួនតាប្រាក់បានមួយថ្ងៃ ខ្ញុំ ក៏ទទួលដំណឹងថាតាផនគណៈស្រុកកំពង់រោទិ៍ ក៏ត្រូវចាប់ខ្លួនដែរ។ ខេមរ៉ា និងបុគ្គលិកតំបន់២៥មួយចំនួនក៏ត្រូវបានចាប់ខ្លួន។

ខ្ញុំ,កូនស្រីពីរនាក់របស់តាប្រាក់,ឪពុកម្តាយ,បងប្អូន,សាច់ញាតិរបស់តាប្រាក់៤គ្រួសារទៀត ដែលមានសមាជិក២០នាក់រស់នៅ ខេត្តស្វាយរៀង ត្រូវបានចាប់បញ្ជូនទៅគុកជ្រៃអូរញ្ញោតំបន់៣៣ក្នុងខេត្តកំពង់ស្ពឺដែលមានតាខុន(កំបុតដៃ)គឺជាប្រធាន។

ខ្ញុំបានរស់នៅក្នុងភាពភ័យខ្លាចជានិច្ច ព្រោះឃើញសន្តិសុខចាប់អ្នកដែល នៅក្រុមជាមួយខ្ញុំយកទៅសម្លាប់ជារៀងរាល់ថ្ងៃ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំខ្ញុំបានទទួលដំណឹងថាតាប្រាក់ និងប្រពន្ធរបស់គាត់ឈ្មោះ ចាន់ គីមស្រ៊ុន បានស្លាប់អស់ហើយ។ ដូច្នេះ ខ្ញុំក៏បានចុះផ្សាយដំណឹងតាមរយៈទស្សនាវដ្តីស្វែងរកការពិត ដើម្បីស្វែងរកកូនស្រីរបស់គាត់ទាំងពីរនាក់ដែលត្រូវជា ជីដូនមួយរបស់ខ្ញុំ។ រយៈពេល

មួយខែក្រោយមកខ្ញុំបានដំណឹងថា ប្អូនស្រីជីដូនមួយរបស់ខ្ញុំឈ្មោះសេកសាយ ដែលត្រូវជាកូនរបស់តាប្រាក់នៅរស់។ ខ្ញុំបានទៅជួបប្អូនជីដូនមួយនៅផ្ទះរបស់នាងស្ថិតក្នុងខេត្តកំពង់ស្ពឺក្បែរអតីតមន្ទីរសន្តិសុខជ្រៃអូរញ្ញៅ ដែលនាងធ្លាប់ជាប់ឃុំឃាំង។ពេលបានជួបគ្នាភ្លាមយើងបាន ស្រក់ទឹកភ្នែក ដោយមិនដឹងខ្លួនដោយសារតែរឿងរ៉ាវដែលកើតឡើងកន្លងមក ហើយខ្ញុំក៏មិនដែលគិតថាបានជួបមុខគ្នាវិញដែរ។ក្រោយមកទៀតខ្ញុំក៏បានណាត់ប្អូនស្រីជីដូនមួយ ទៅលេងស្រុកកំណើត ដើម្បីឲ្យស្គាល់បងប្អូនដែលនៅរស់រានមានជីវិត និងបានធ្វើបុណ្យឧទ្ទិសកុសលជូនឪពុកម្តាយរបស់នាងផងៗ

**រកឃើញរូបថតឪពុក និងឯកសារ**

សេក សាយ តែងតែទន្ទឹងរង់ចាំមើលផ្លូវឪពុកវិលត្រឡប់មកជួបគាត់នៅថ្ងៃណាមួយហើយ គាត់ក៏បានស្នើមជ្ឈមណ្ឌលឯកសារកម្ពុជាជួយស្វែងរកឪពុករបស់គាត់ នៅអំឡុងពេលដែលគាត់ត្រូវបានអញ្ជើញឲ្យ មកនិយាយពីរឿងរ៉ាវដែលគាត់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហម នៅក្នុងកម្មវិធីទស្សនកិច្ចសិក្សានៅប្រទេសកម្ពុជារបស់សារមន្ទីរប្រល័យពូជសាសន៍ (HolocaustMuseum) ដែលមានទីតាំងនៅប្រទេសអាមេរិកកាលពីចុងខែកញ្ញា ឆ្នាំ២០១៩។ ប៉ុន្តែជាអកុសល្យការទន្ទឹងរង់ចាំរបស់គាត់គឺបានត្រឹមតែ ដំណឹងនៃការស្លាប់រួមជាមួយនឹងរូបថតមួយសន្លឹក និងឯកសារចម្លើយសារភាពដែលមានកម្រាស់២២០ ទំព័ររបស់ឪពុកគាត់ដែលនៅសេសសល់ប៉ុណ្ណោះ។ រូបថតនិងឯកសារទាំងនេះត្រូវបានបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា យកទៅប្រគល់ជូនគាត់នៅផ្ទះស្ថិតនៅក្នុងភូមិព្រៃទួប ឃុំស្នងក្រពើ ស្រុកគងពិសី ខេត្តកំពង់ស្ពឺកាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៩ កន្លងមក ។

សេកសាយស្ថិតក្នុងវ័យ៥២ឆ្នាំ បានរៀបរាប់ទាំងអារម្មណ៍ក្តុកក្តួលលាយឡំជាមួយទឹកភ្នែកថា «ខ្ញុំបានបែកពីឪពុក(សេកសាតហៅនិន ហៅប្រាក់នាទីលេខា តំបន់២៥) អស់រយៈពេលជាង៤០ឆ្នាំ ហើយតាំងពីខ្ញុំមានអាយុ១១ឆ្នាំ។ការជួបគ្នាជាលើកចុងក្រោយរវាងឪពុក និងខ្ញុំគឺនៅពេលដែលម្តាយរបស់ខ្ញុំ បានយកខ្ញុំទៅផ្ញើនៅមន្ទីរពេទ្យសំប៉ានក្នុងខេត្តកណ្តាល នៅឆ្នាំ១៩៧៨។ ក្រោយមកខ្ញុំត្រូវបានបញ្ជូនទៅមន្ទីរឃុំឃាំងជ្រៃអូរញ្ញៅនៅខេត្តកំពង់ស្ពឺ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំខ្ញុំ បានព្យាយាមតាមរកដំណឹងឪពុករបស់ខ្ញុំនៅគ្រប់ទីកន្លែង និងបានប្រកាសសួររកដំណឹងរបស់គាត់នៅតាមវិទ្យុ។ ប៉ុន្តែមិនបានទទួលដំណឹងគាត់ទាល់តែសោះ។ ថ្ងៃមួយ ខ្ញុំបានសួរទៅកាន់បងប្រុសជីដូនមួយរបស់ខ្ញុំថា តើមានបានទទួលដំណឹងពីឪពុករបស់ខ្ញុំដែរឬទេ? គាត់បានឆ្លើយតបមកខ្ញុំវិញថាគាត់បានព្យាយាមរកអស់ជាច្រើនកន្លែងដែរ ប៉ុន្តែ នៅតែមិនទទួលបានដំណឹងអ្វីសោះ។ ប្រហែលជាគាត់បានស្លាប់ហើយ ហើយប្រសិនបើគាត់នៅរស់គាត់នឹងមករកយើងមិនខាន។ ក្តីសង្ឃឹមដ៏តិចតួចរបស់ខ្ញុំបានរសាយប៉ុន្តែអារម្មណ៍របស់ខ្ញុំនៅតែគិតថា ឪពុករបស់ខ្ញុំគឺនៅរស់រានមានជីវិតនៅឡើយ។ ខ្ញុំនឹករឭកដល់ឪពុករបស់ខ្ញុំជារៀងរាល់ថ្ងៃ។

បន្ទាប់ពីខ្ញុំទទួលបានរូបថតមួយសន្លឹក និងចម្លើយសារភាពមួយច្បាប់របស់ឪពុកខ្ញុំដែលឆ្មាំគុកនៃមន្ទីរសន្តិសុខស-២១បានសួរចម្លើយគាត់ធ្វើឲ្យខ្ញុំ មានអារម្មណ៍តក់ស្លុតនិងរំជួលចិត្តយ៉ាងខ្លាំង។ ខ្ញុំគិតថាឪពុករបស់ខ្ញុំត្រូវបានឆ្មាំគុកវាយបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរដើម្បីឲ្យគាត់ឆ្លើយសារភាព។

រូបថតឪពុករបស់ខ្ញុំដែល ខ្ញុំទទួលបាននេះគឺមើលទៅហាក់ដូចជាគាត់នៅវ័យក្មេងនៅឡើយ ដោយសារតែខ្ញុំបានបែកពីគាត់យូរឆ្នាំមកហើយ។ ប៉ុន្តែអ្វីដែលខ្ញុំដឹងច្បាស់ពីគាត នៅពេលនោះគឺគាត់មានឈ្មោះ សេក សាត ហៅប្រាក់។ ខ្ញុំនឹងប្រាប់ពីដំណឹង និងផ្ញើរូបថតឪពុករបស់ខ្ញុំទៅបងប្អូននៅស្រុកកំណើតនៅខេត្តស្វាយរៀង ហើយខ្ញុំនឹងឲ្យកូនស្រីរបស់ខ្ញុំដែលបច្ចុប្បន្នកំពុងរៀនថ្នាក់ទី៧ នៅអនុវិទ្យាល័យ អានចម្លើយរបស់ជីតាឲ្យខ្ញុំស្តាប់ព្រោះខ្ញុំមិនបានរៀនសូត្រ។

*ក្រុមទស្សនាវដ្តីស្វែងរកការពិត*

# គម្រោងប្រកួតជ្រើសរើសស្នាដៃតែងនិពន្ធរឿងខ្លីពានរង្វាន់អក្សរសិល្ប៍ស្ទឹករីត លើកទី១ ឆ្នាំ២០២០

សមាគមអ្នកនិពន្ធខ្មែរ គឺជា សមាគមជាតិ ឯករាជ្យ បង្កើតឡើងនៅថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៥៦។ ក្រោយសង្គ្រាមស៊ីវិលប្រល័យពូជសាសន៍ បីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃសមាគមនេះបានបង្កើតឡើងវិញនៅឆ្នាំ១៩៩៣ដោយបានសុំច្បាប់ពីព្រះករុណាអង្គម្ចាស់ជីវិតលើត្បូង ក្នុងឋានៈព្រះអង្គជាព្រះប្រធានឧត្តមក្រុមប្រឹក្សាជាតិ និងបានសុំច្បាប់ពីរដ្ឋអំណាច “រដ្ឋកម្ពុជា”។បន្ទាប់មកតាមសេចក្តីស្នើសុំពីគណៈកម្មាធិការកណ្តាលនៃសមាគមអ្នកនិពន្ធខ្មែរ សម្តេចព្រះបាទ នរោត្តម សីហនុ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ គង់ប្រថាប់ជាព្រះប្រធានកិត្តិយសនៃសមាគម អ្នកនិពន្ធខ្មែរ ឡើងវិញដូចកាលពីសម័យសង្គមរាស្ត្រនិយម។ ពីឆ្នាំ១៩៩៤ រហូតដល់ចុងឆ្នាំ១៩៩៦សមាគមអ្នកនិពន្ធខ្មែរ ដែលទើបនឹងរស់រានមានជីវិតឡើងវិញជាថ្មី គឺដឹកនាំដោយសាស្ត្រាចារ្យ យូ បូ ដែលមានទីស្នាក់កណ្តាលក្នុងបរិវេណវត្តបទុមវតីវិថីឧកញ៉ាស៊ូស្រ៊ុន៧ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

នៅចុងឆ្នាំ២០១៧ សមាគមអ្នកនិពន្ធខ្មែរបានធ្វើមហាសន្និបាត របស់ខ្លួនជ្រើសរើសថ្នាក់ដឹកនាំថ្មីដើម្បីដំណើរការ និងចុះបញ្ជីសមាគមអ្នកនិពន្ធខ្មែរក្នុងបញ្ជីអង្គការសមាគមនៃក្រសួងមហាផ្ទៃនៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៨។ ក្នុងអាណត្តិទី១០សមាគមអ្នកនិពន្ធខ្មែរ ដឹកនាំដោយ ឯកឧត្តម ព្រឿងប្រណីត កំពុងមានសកម្មភាពបណ្តុះបណ្តាលសិក្ខាកាមអ្នកនិពន្ធជំនាន់ថ្មីជាបន្តបន្ទាប់។ ក្រៅពីនេះទៀតសមាគមមានការប្រកួតស្នាដៃ ពានរង្វាន់អក្សរសិល្ប៍ ទន្លេមេគង្គនិងជ្រើសរើសអ្នកនិពន្ធឆ្នើម ទៅទទួលពានរង្វាន់អាស៊ីអាគ្នេយ៍ជារៀងរាល់ឆ្នាំ។ ជាងនេះទៅទៀត សមាគមអ្នកនិពន្ធខ្មែរបានចូលរួមជាគណៈកម្មការវាយតម្លៃ ស្នាដៃនិពន្ធ ក្នុងការប្រកួតជ្រើសរើសស្នាដៃនៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងធម្មការ និងសាសនា និងសហការជាមួយសមាគមអ្នកនិពន្ធខ្មែរនៅបរទេសប្រចាំប្រទេសបារាំង ប្រកួតពានរង្វាន់អក្សរសិល្ប៍សន្តិភាពផងដែរ។

ដើម្បីសម្រេចទៅតាមទស្សនវិស័យរួមគឺ ការតែងនិពន្ធស្រាវជ្រាវបោះពុម្ពនិងនវានុវត្តន៍ ប្រកបដោយគុណភាពឧត្តមភាពលើកកម្ពស់វិស័យតែងនិពន្ធនៅកម្ពុជា សមាគមអ្នកនិពន្ធខ្មែរកំពុងស្វែងរកដៃគូសហការជាមួយស្ថាប័នផ្សេងៗដែលមានគោលបំណងរួម ក្នុងការលើកស្ទួយគាំទ្រការស្រាវជ្រាវនិងវិស័យតែងនិពន្ធ។ ដោយយល់ឃើញថាមជ្ឈមណ្ឌលឯកសារកម្ពុជា មានគោលបំណងចូលរួមក្នុងការលើកស្ទួយ គាំទ្រការស្រាវជ្រាវនិងវិស័យតែងនិពន្ធសមាគមអ្នកនិពន្ធខ្មែរបានសហការជាមួយ មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីរៀបចំការប្រកួតជ្រើសរើសស្នាដៃ ពានរង្វាន់រឿងខ្លីអំពីជីវិតរស់នៅប្រចាំថ្ងៃ របស់ប្រជាជនកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត។

ការបង្កើតគម្រោងប្រកួតជ្រើសរើសស្នាដៃ តែងនិពន្ធរឿងខ្លីពានរង្វាន់អក្សរសិល្ប៍ស្ទឹករីត លើកទី១ឆ្នាំ២០២០ នេះឡើងក្នុងគោលបំណង១)ដើម្បីលើកកម្ពស់ការស្រាវជ្រាវនិពន្ធអំពីជីវិតរស់នៅប្រចាំថ្ងៃ របស់ប្រជាជនកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុលពត។ ២)ដើម្បីរួមចំណែករក្សាឯកសារប្រវត្តិសាស្ត្រ នៃជីវិតមនុស្សជាតិរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត តាមរយៈស្នាដៃតែងនិពន្ធរបស់អ្នកនិពន្ធខ្មែរអ្នក ដែលរស់រានមានជីវិត និងអ្នកដែលធ្លាប់បានឮរឿងរ៉ាវ ដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត។ ***សមាគមអ្នកនិពន្ធខ្មែរ***

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សមាគមអ្នកនិពន្ធខ្មែរ**

Khmer Writers Association

លេខ...៣០/១៩....ស.អ.ខ.

## សេចក្តីជូនដំណឹង

## ការប្រកួតជ្រើសរើសស្នាដៃតែងនិពន្ធរឿងខ្លី ពានរង្វាន់អក្សរសិល្ប៍ស្លឹករឹត លើកទី១ ឆ្នាំ២០២០

## សមាគមអ្នកនិពន្ធខ្មែរ

សូមប្រគេន ជម្រាបជូនដំណឹងដល់សមាជិក សមាជិកានៃសមាគមអ្នកនិពន្ធខ្មែរ និងសាធារណជនទូទៅ មេត្តាជ្រាបថា ក្នុងគោលបំណងរួមចំណែកថែរក្សាឯកសារប្រវត្តិសាស្ត្រនៃជីវិតរស់នៅរបស់ប្រជាជនខ្មែរក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត  តាមរយៈស្នាដៃតែងនិពន្ធ និងដើម្បីលើកស្ទួយតម្លៃអក្សរសាស្ត្រជាតិខ្មែរ។ សមាគមអ្នកនិពន្ធខ្មែរសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំប្រកួតជ្រើសរើសស្នាដៃតែងនិពន្ធរឿងខ្លី **“ពានរង្វាន់អក្សរសិល្ប៍ស្លឹករឹត”** លើកទី១ ឆ្នាំ២០២០ ប្រធានបទ **“ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត”**។

**លក្ខខណ្ឌនៃការជ្រើសរើសវាយតម្លៃ**

១. ខ្លឹមសាររឿងខ្លី ជាស្នាដៃនិពន្ធថ្មី ត្រូវតែនិយាយអំពីជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត  ប៉ុន្តែមិនសង្កត់ទៅលើតែប្រធានបទឧក្រិដ្ឋកម្មយង់ឃ្នងកាប់សម្លាប់។

២. ចំនួនពី៥ ដល់ ១៥ទំព័រ (អត្ថបទវាយដោយកុំព្យូទ័រ ឬសំណេរដៃពី១០ ដល់២០ទំព័រ)។

៣. ក្រដាស អេ៤ ពុម្ពអក្សរ ខ្មែរ អូ.អេស សៀមរាប(Khmer OS Siemreap) ទំហំ១២ មិនដាក់ក្បាលឬជើងទំព័រ។

**បេក្ខជនដែលអាចចូលរួមប្រកួតបានគឺ**

១. អ្នកនិពន្ធ និងសាធារណជនទូទៅ ជាជនជាតិខ្មែរ ឬ បរទេស (មានសមត្ថភាពអក្សរសិល្ប៍)។

២. អ្នករស់រានមានជីវិតពីសម័យ ប៉ុល ពត  និងធ្លាប់មានរឿងរ៉ាវនៅក្នុងសម័យនោះ។

៣. អ្នកឮរឿងរ៉ាវពិតដែលរៀបរាប់ឡើងវិញដោយអ្នករស់រានមានជីវិតពីសម័យ ប៉ុល ពត។

ស្នាដៃរឿងខ្លីចំនួន១០រឿង នឹងត្រូវជ្រើសរើសផ្តល់ពានរង្វាន់រួមមាន ពានកិត្តិយស វិញ្ញាបនបត្រ និងថវិកា។  ស្នាដៃដែលបានជ្រើសរើសនឹងត្រូវបោះពុម្ព និងពិចារណាផលិតជាភាពយន្តខ្លី ឬចម្រៀង។

សមាជិកសមាជិកានៃ ស.អ.ខ និងសាធារណជនទូទៅ ដែលមានបំណងចូលរួមប្រកួត សូមផ្ញើស្នាដៃមកកាន់សមាគមអ្នកនិពន្ធខ្មែរចាប់ពីថ្ងៃ១ ខែតុលា ដល់ថ្ងៃទី៣០ ខែវិច្ឆិកាឆ្នាំ២០១៩  វេលាម៉ោង ១៧.០០នាទី ជាកំណត់។

ទីកន្លែងទទួលស្នាដៃ ទីស្នាក់ការសមាគមអ្នកនិពន្ធខ្មែរ ក្នុងបរិវេណវត្តបទុមវតី រាជធានីភ្នំពេញ ឬផ្ញើតាមសារអេឡិចត្រូនិច៖ Khmerwriterkwa@gmail.com ឬទាក់ទងទូរសព្ទលេខ ០៨៩ ៨៥៦ ៧៦៤, ០១២ ៧៩២៩៥៩ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០១៩

ប្រធានសមាគមអ្នកនិពន្ធខ្មែរ

KHMER WRITER'S ASSOCIATION

**គ្រឿង ប្រណីត**

សមាគមអ្នកនិពន្ធខ្មែរ អាសយដ្ឋាន៖ វត្តបទុមវតី វិថីឧកញ៉ាស៊ូ ស្រុន ៧  សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Add: Khmer Writers Association: Wat Badum Wadey Oknha Sousrun 7, Khan Daun Penh, Phnom Penh CAMBODIA
Email: khmerwriterkwa@gmail.com FB: Khmer Writers Association, Tel: 012 792 959, 092 788 990

# សាលក្រមសំណុំរឿង០០២/០២
## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

(តពីលេខមុន)

៤០. អង្គហេតុទាំងអស់ដែលបញ្ជាក់អំពីធាតុផ្សំនៃបទឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់ ព្រមទាំងអង្គហេតុទាំងអស់ ដែលមិនអាចខ្វះបានសម្រាប់ការសម្រេចចិត្តលើការផ្តន្ទាទោស ជាពិសេសអង្គហេតុទាំងឡាយដែលបង្កើតជាធាតុផ្សំនៃបទឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវដែលត្រូវបាន ចោទប្រកាន់លើជនជាប់ចោទ ត្រូវបង្ហាញឲ្យហួសពីវិមាតិសង្ស័យ។ នេះត្រូវមានការគាំទ្រដោយមតិដែលមានសំអាងហេតុ ដោយផ្អែកលើភ័ស្តុតាង ទាំងស្រុងដោយពុំចាំបាច់អនុវត្តបទដ្ឋាន នៃការបង្ហាញភ័ស្តុតាងឲ្យហួសពីវិមតិសង្ស័យជាផ្នែកៗនោះទេ។ដាក់ស្តែងដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានសម្រេច ករណីនេះពុំមានន័យថាភ័ស្តុតាងផ្សេងៗជាច្រើនអាចបូកបញ្ចូលគ្នា ដើម្បីបំពេញលក្ខខណ្ឌនៃការបង្ហាញឲ្យហួសពីវិមតិសង្ស័យ ដោយពុំគិតពីទម្ងន់នៃភ័ស្តុតាងនីមួយៗនោះដែរ។ អង្គជំនុំជម្រះបញ្ជាក់ដូចខាងក្រោមអំពីផលប៉ះពាល់ នៃបទដ្ឋានក្នុងការបង្ហាញភ័ស្តុតាង ឲ្យហួសពីវិមតិសង្ស័យ ទៅលើការវាយតម្លៃលើតម្លៃនៃភ័ស្តុតាង ដែលត្រូវបានដាក់នៅចំពោះមុខខ្លួន។

### ២.៤.៣. ភាពដែលអាចទទួលយកបាននៃភ័ស្តុតាង

#### ២.៤.៣.១. ការគ្រប់គ្រងលើសំណើសុំឲ្យទទួលយកភ័ស្តុតាង

៤១. នៅមុនពេលចាប់ផ្តើមការជំនុំជម្រះអង្គជំនុំជម្រះបានបង្គាប់ឲ្យ ភាគីដាក់បញ្ជីបឋមស្តីពីការបង្ហាញអត្តសញ្ញាណការពិពណ៌នាសង្ខេបនិងការបញ្ជាក់អំពីភាពពាក់ព័ន្ធនៃភ័ស្តុតាងទាំងអស់ដែលបានស្នើសុំ។ នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះបានបង្គាប់បន្ថែម ឲ្យភាគីទាំងអស់ផ្តល់បញ្ជីចុងក្រោយស្តីពីឯកសារដែលបានស្នើសុំ។ នៅថ្ងៃទី០៨ខែមេសាឆ្នាំ២០១៤អង្គជំនុំជម្រះបានបង្គាប់បន្ថែមឲ្យភាគីទាំងអស់ផ្តល់បញ្ជីចុងក្រោយស្តីអំពីឯកសារដែលបានដាក់នាពេលមុន និងបញ្ជីចុងក្រោយនៃវត្ថុតាង ដែលភាគីមានបំណងដាក់នៅក្នុងសំណុំរឿង ០០២/០២ រួមទាំងការពិពណ៌នាអំពីប្រភេទនិងខ្លឹមសារ ព្រមទាំងភាពពាក់ព័ន្ធនឹងដីកាដំណោះស្រាយ។

#### ២.៤.៣.២. ក្របខណ្ឌគតិយុត្តិ

៤២. លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះភ័ស្តុតាងទាំងអស់អាចទទួលយកបាន។ រាល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះត្រូវតែផ្អែកលើភ័ស្តុតាង ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ហើយត្រូវពិភាក្សាដេញដោល។ អង្គជំនុំជម្រះអាចប្រានចោលសំណើ សុំឲ្យពិនិត្យភ័ស្តុតាងណាដែលពុំជាប់ពាក់ព័ន្ធឬជាន់គ្នា ឬពុំអាចរកបានក្នុងរយៈពេលសមស្របណាមួយ ពុំសមស្របក្នុងការបញ្ជាក់អង្គហេតុដែលជាគោលដៅ នៃការស្នើសុំពិនិត្យភ័ស្តុតាងដែលច្បាប់មិនអនុញ្ញាតឬ ដែលមានចេតនាពន្យារកិច្ចដំណើរការនីតិវិធី។

៤៣. ទោះបីជាភាគីអាចស្នើសុំឲ្យទទួលយកភ័ស្តុតាងនៅក្នុងដំណាក់កាលណាមួយនៃការជំនុំជម្រះក៏ដោយក៏ភ័ស្តុតាងទាំងអស់ដែលបានស្នើឡើងហើយ ពុំអាចរកបាននៅក្នុងពេលបើកការជំនុំជម្រះ ត្រូវបានចាត់ទុកថា ភ័ស្តុតាងថ្មីអនុលោមតាមលក្ខខណ្ឌនៃវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។ភាគីស្នើសុំត្រូវបង្ហាញថា ភ័ស្តុតាងថ្មីនោះពុំអាចរកបាននៅមុនពេលបើកការជំនុំជម្រះនិង/ ឬពុំអាចរកឃើញបើទោះជាបាននិតខំប្រឹងប្រែងស្វែងរកយ៉ាងសមស្របក៏ដោយ។ ប្រសិន

បើសំណើសុំឲ្យទទួលយកភស្តុតាងពុំបាន ធ្វើឡើងទាន់ពេលវេលានោះទេអង្គជំនុំជម្រះនៅតែ អាចទទួលយកភស្តុតាងដែលបានស្នើសុំនោះ ដើម្បីជាប្រយោជន៍នៃយុត្តិធម៌។

*៤៤.* ដើម្បីចាត់ទុកថាភស្តុតាងត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះភស្តុតាងទាំងនោះត្រូវបានសង្ខេបអានឲ្យភាគីស្តាប់ឬ បើមិនដូចច្នេះទេត្រូវកំណត់អត្តសញ្ញាណឲ្យបានសមស្រប។ ក្នុងករណីអង្គជំនុំជម្រះប្រានចោលការជំទាស់ទៅនឹងឯកសារណាមួយ ឬក្នុងករណីគ្មានការជំទាស់ណាមួយទេនោះឯកសារដែលត្រូវបានសង្ខេបឬកំណត់អត្តសញ្ញាណសមស្របនោះដែលរួមទាំងសំណើសុំឲ្យទទួលយកនិងបើមិនដូច្នោះទេបាន បំពេញលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងវិធាន៨៧ (៣)(៤) នៃវិធានផ្ទៃក្នុង ត្រូវបានទទួលយក ហើយចាត់ទុកថាត្រូវបាន ដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ ឯកសារនីមួយដែលត្រូវបានទទួលយកនិងដាក់នៅចំពោះមុខអង្គជំនុំជម្រះនោះ ត្រូវផ្តល់ជាលេខឯកសារE3។

*៤៥.* នៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលនិងសេចក្តីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន មេធាវីការពារក្តី នួន ជា បានយោងទៅលើភស្តុតាងដែលមិនត្រូវបានទទួលយកធ្វើជាភស្តុតាង ដោយសារតែភស្តុតាងនោះមិនបានបំពេញទៅតាមលក្ខណ្ឌនៃវិធាន៨៧នៃវិធានផ្ទៃក្នុង ឬភស្តុតាងនោះមិនត្រូវបានបង្ហាញ និងស្នើសុំឲ្យទទួលយកធ្វើជាភស្តុតាង។ ដោយហេតុថាសម្ភារនោះពុំត្រូវបានដាក់ឲ្យបានសមស្រប នៅចំពោះមុខអង្គជំនុំជម្រះអនុលោមតាមវិធាន៨៧នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះមិនអាចសំអាងលើសម្ភារនោះនៅក្នុងសាលក្រមនោះឡើយ។

*៤៦.* អង្គជំនុំជម្រះរម្លឹកថា នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានសន្និដ្ឋានថាវិធីសាស្ត្រដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបាន ប្រើប្រាស់ក្នុងការទទួលបានឯកសារការធ្វើបណ្ណសារ និងការរក្សាទុកឯកសារសេសសល់ពីរបបកម្ពុជាប្រជាធិបតេយ្យ មានភាពអាចជឿជាក់បានហេតុដូច្នេះអង្គជំនុំជម្រះយល់ថាឯកសារបែបនេះ ត្រូវទទួលបានការសន្មតបឋមនៃភាពពាក់ព័ន្ធ និងភាពគួរឲ្យខទុកចិត្តបាន (រួមទាំងយថាភាព)។ ដូចគ្នានេះផងដែរ អង្គជំនុំជម្រះយល់ឃើញថាការសន្មតនៃភាពពាក់ព័ន្ធ និងភាពគួរឲ្យទុកចិត្តបាន (រួមទាំងយថាភាព) ចំពោះឯកសារនានា ដែលបានយោងនៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង០០២ ផ្អែកលើការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតទៅ លើឯកសារទាំងនេះនិងការណ៍ដែលថាដីកាដំណោះស្រាយត្រូវបានប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងពីគោលការណ៍នេះ សាជាថ្មីនៅក្នុងសាលក្រមនៃសំណុំរឿង០០២/០១។ អង្គជំនុំជម្រះតុលាការកំពូលមិនបានឃើញមានកំហុសនៅក្នុងវិធីសាស្ត្រនេះនោះទេ ហើយបានកត់សម្គាល់ថា«អាស្រ័យលើភាគីដែលជាអ្នកជំទាស់ទៅនឹងភាពត្រឹមត្រូវនៃឯកសារ ដែលតុលាការបានផ្តល់សច្ចធារណ៍ដែលអាចជំទាស់បានថា មានភាពត្រឹមត្រូវតាមសេចក្តីបញ្ជាក់ដំបូង។ អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា ភាគីដែលជំទាស់ទៅនឹងភាពគួរឲ្យទុកចិត្តបាន ឬយថាភាពនៃភស្តុតាងចាំបាច់ត្រូវតែបង្ហាញភស្តុតាង និងផ្តល់សំអាងហេតុដើម្បីជំទាស់នឹងការសន្មត់នេះ។ នៅពេលមានបញ្ហាបែបនេះកើតឡើង អង្គជំនុំជម្រះនឹងដោះស្រាយទៅតាមករណីជាក់ស្តែង។កាលណាពុំមានផ្តល់សំអាងហេតុ អំពីការជំទាស់ទាំងនោះ ការសន្មតនៃភាពគួរឲ្យទុកចិត្តបាន(រួមទាំងយថាភាព) នៅតែមានសុពលភាពដដែល។

## ២.៤.៤.ប្រភពនៃភស្តុតាងដាក់នៅចំពោះមុខអង្គជំនុំជម្រះ

### ២.៤.៤.១.ភស្តុតាងរបស់ជនជាប់ចោទ

*៤៧.* អនុលោមតាមវិធាន២១(១)(ឃ) និងវិធាន៩០(១)នៃវិធានផ្ទៃក្នុង ប្រធានអង្គជំនុំជម្រះបានជូនដំណឹងដល់ជនជាប់ចោទនីមួយៗថា ជនជាប់ចោទមានសិទ្ធិជាមូលដ្ឋានក្នុងការនៅស្ងៀមមិនឆ្លើយតប។ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤បន្ទាប់ពីមានការរម្លឹកបែបនេះរួចមក នួន ជា និងខៀវ សំផនត្រូវបានផ្តល់ឱកាសឲ្យធ្វើសេចក្តីថ្លែងការណ៍បើករឿង

ៗខ្លួនៗ ជនជាប់ចោទទាំងពីរនាក់បានបញ្ជាក់ថា អនុលោមតាមវិធាន៩០នៃវិធានផ្ទៃក្នុងពួកគាត់នឹងមិនឆ្លើយតបទៅនឹងសំណួរណាមួយទេៗប្រធានអង្គជំនុំជម្រះបានជូនដំណឹងដល់ជនជាប់ចោទថា អង្គជំនុំជម្រះនឹងដំណើរការទៅ ដោយផ្អែកលើមូលដ្ឋានថាជនជាប់ចោទបាន អនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយទៅនឹងសំណួរណាមួយនោះទេ លើកលែងតែនិងរហូតទាល់តែពេលណាដែលអង្គជំនុំជម្រះបានទទួលព័ត៌មានផ្សេងពីនេះយ៉ាងច្បាស់ពីជនជាប់ចោទ ឬពីមេធាវីរបស់ពួកគាត់ៗ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីបាន ស្នើសុំសួរសំណួរនានាទៅកាន់ជនជាប់ចោទ តាមរយៈប្រធានអង្គជំនុំជម្រះប្រធានអង្គជំនុំជម្រះ បានឆ្លើយតបទៅដើមបណ្តឹងរដ្ឋប្បវេណីថាជនជាប់ចោទបានអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបហើយនឹងមិនឆ្លើយទៅនឹងសំណួរទាំងនោះទេៗ នៅក្នុងអំឡុងពេលសវនាការអង្គជំនុំជម្រះបាន ចង្អុលបង្ហាញថាអង្គជំនុំជម្រះអាចនឹងទាញសេចក្តីសន្និដ្ឋាន ចេញពីការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបនេះ ក្នុងករណីដែលជនជាប់ចោទមិនបានអនុវត្តគ្រប់ពេលវេលានោះៗ

៤៨. នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ ក្រោយពីទទួលសំណើរបស់សហព្រះរាជអាជ្ញា រួចមកអង្គជំនុំជម្រះបានស្នើឲ្យជនជាប់ចោទបញ្ជាក់ថា តើពួកគាត់មានបំណងផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២/០២ដែរឬទេៗ ខៀវ សំផនបានឆ្លើយតបថា គាត់នៅតែរក្សាជំហរថា គាត់នៅតែរក្សាជំហរថាគាត់នឹងមិនឆ្លើយតប ទៅនឹងសំណួរណាមួយនោះទេៗ នួន ជា ក៏បានបញ្ជាក់អំពីចេតនារបស់គាត់ក្នុងការមិនឆ្លើយតបទៅនឹងសំណួរទាំងឡាយនៅក្នុងសំណុំរឿង ០០២/០២ ដែរ ប៉ុន្តែបានកត់សម្គាល់ថា គាត់នឹងពិចារណាឡើងវិញអំពីជំហរនេះប្រសិនបើអង្គជំនុំជម្រះកោះហៅ លោកហេង សំរិនឲ្យមកផ្តល់សក្ខីកម្ម និងផ្តល់ឱកាស ឲ្យមេធាវីការពារក្តីសួរដេញដោលចំពោះរូបគាត់ៗ ជនជាប់ចោទមិនបានឆ្លើយតបទៅនឹងសំណួរនានា ដែលភាគីដទៃនិងអង្គជំនុំជម្រះបានចោទសួរនោះឡើយៗ ប៉ុន្តែ ខៀវ សំផន បានធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ និងបានអះអាងថាគាត់មានបំណងឆ្លើយតបទៅនឹងសំណួរខ្លះៗ ដែលដើមបណ្តឹងរដ្ឋប្បវេណីបានសួរកន្លងមកៗ

## ២.៤.៤.២.ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ

៤៩. ក្នុងឋានៈពិសេសរបស់ពួកគាត់តុលាការពុំតម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសម្បថនោះទេៗ អង្គជំនុំជម្រះពិនិត្យលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញតាមករណីជាក់ស្តែងនីមួយៗ ដោយផ្អែកលើភាពអាចជឿជាក់បាននៃសក្ខីកម្ម និងដោយការពិចារណាផ្អែកលើកត្តាមួយចំនួនដូចជា អត្តចរិតរបស់បុគ្គលដែលផ្តល់សក្ខីកម្មភាពស៊ីចង្វាក់គ្នា និងភាពមិនស៊ីចង្វាក់គ្នាទាក់ទងនឹងអង្គហេតុសំខាន់ៗ ការជំរុញពីខាងក្រៅដែលអាចមានការអះអាងបញ្ជាក់ និងកាលៈទេសៈទាំងអស់នៃរឿងក្តីនេះៗ

៥០. សាក្សីទាំងអស់ត្រូវបានជូនដំណឹងអំពីសិទ្ធិមិនឆ្លើយដាក់បន្ទុកលើខ្លួនឯង និងត្រូវបានទទួលជំនួយពីមេធាវីក្នុងករណីចាំបាច់ៗ អង្គជំនុំជម្រះ ក៏បានស្តាប់មតិយោបល់របស់អ្នកជំនាញ លើបញ្ហាបច្ចេកទេសជាក់លាក់មួយចំនួនផងដែរ ដើម្បីជួយដល់ការស្វែងយល់ពីភស្តុតាងដែលបានបង្ហាញនៅក្នុងអំឡុងពេលសវនាការៗ

៥១. អង្គជំនុំជម្រះ បានទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីរួមទាំងប្រតិចារឹក ស្តីពីកិច្ចដំណើរការនីតិវិធីមុនៗរួមទាំងឬជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ ដើម្បីផ្តល់ឱកាសឲ្យភាគីសួរតទល់ជាមួយនឹងបុគ្គល ដែលរងការចោទប្រកាន់ថាមានភាពមិនស៊ីចង្វាក់គ្នា រវាងភស្តុតាងផ្ទាល់មាត់និងកំណត់ហេតុនៃការស្តាប់ចម្លើយមុនៗរបស់ពួកគាត់ នៅក្នុងសវនាការៗ ក្នុងគោលបំណងដូចគ្នា និងដើម្បីជាប្រយោជន៍នៃយុត្តិធម៌អង្គជំនុំជម្រះក៏ទទួលយកផងដែរ នូវកំណត់ហេតុនៃការស្តាប់ចម្លើយមុនៗទាំងអស់របស់សាក្សីអ្នកជំនាញនិងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានយកពីក្នុង

*សំណុំរឿង០០៣និង ០០៤ មកបង្ហាញនៅពេលដែលបុគ្គលទាំងនេះត្រូវបានស្តាប់ចម្លើយនៅក្នុងសវនាការ។*

*៥២. ចាប់ពីខែមិថុនា ឆ្នាំ២០១២ មកដើម្បីជាប្រយោជន៍នៃភាពឆាប់រហ័សអង្គជំនុំជម្រះ បានបង្គាប់ឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញផ្តល់ឲ្យបុគ្គលដែលត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្មនូវកំណត់ហេតុនៃស្តាប់ចម្លើយជាលាយល័ក្ខអក្សរ ឬអានឯកសារទាំងនោះឲ្យអ្នកដែលមិនអាចអានអក្សរបាន ដើម្បីផ្តល់ឱកាសឲ្យពួកគាត់ ដើម្បីពិនិត្យឡើងវិញនូវចម្លើយដែលពួកគាត់ បានឆ្លើយពីពេលមុនៗ បន្ថែមពីនេះទៀតប្រធានអង្គជំនុំជម្រះក៏ចាប់ផ្តើមសួរទៅកាន់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះឲ្យបញ្ជាក់អះអាង ពីភាពត្រឹមត្រូវនៃចម្លើយមុនៗនៅក្នុងកំណត់ហេតុ នៃការស្តាប់ចម្លើយដែលពួកគាត់បានផ្តល់ជូន ក.ស.ច.ស.។ ក្រោយពីការបញ្ជាក់រួចហើយនិងដោយកត់សម្គាល់ពីសិទ្ធិ របស់ភាគីក្នុងការពិនិត្យទៅលើភាពអាចជឿជាក់បាននូវអ្វី ដែលបុគ្គលទាំងនោះបានឆ្លើយកន្លងមកឬបញ្ហាពាក់ពន្ធ័នឹងចម្លើយទាំងនោះ អង្គជំនុំជម្រះអនុញ្ញាតឲ្យភាគីសួរដេញដោលបុគ្គលទាំងនោះ បន្ថែម ប៉ុន្តែកម្រិតត្រឹមសំណួរដែលចាំបាច់ ដើម្បីបញ្ជាក់អំពីភាពពាក់ព័ន្ធនៃបញ្ហា ដែលមិនទាន់បានឆ្លើយគ្រប់គ្រាន់នៅឡើយនៅក្នុងចម្លើយទាំងនោះ ឬមិនត្រូវបានអ្នកស៊ើបអង្កេតនៃក.ស.ច.ស.សម្ភាសសួរតែប៉ុណ្ណោះ។អង្គជំនុំជម្រះតុលាការកំពូលបានសម្រេច តម្កល់វិធីសាស្ត្រនេះនៅក្នុងសាលដីកានៃសំណុំរឿង ០០២/០១។*

*៥៣. ទាក់ទងនឹងបញ្ហាពាក់ព័ន្ធ មេធាវីការពារក្តី នួន ជា បានលើកឡើងអំពីបញ្ហានៃការអនុវត្តជាក់ស្តែងដែលបានប្រើនៅក្នុងពេលសួរសំណួរខ្លះៗ ដើម្បីរម្លឹកដល់ការចងចាំរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដោយលើកឡើងពីការដកស្រង់ចម្លើយមុនៗ របស់ពួកគាត់នៅក្នុងអំឡុងការផ្តល់សក្ខីកម្ម។ មេធាវីការពារក្តី នួន ជា បានលើកឡើងថាការអនុវត្តបែបនេះវាធ្វើឲ្យសក្ខីកម្ម របស់បុគ្គលទាំងនេះត្រូវបានចាត់ទុកថាកាជាការសួរសំណួរនាំមុខដល់សាក្សីឬដើមបណ្តឹងរដ្ឋប្បវេណី ហេតុនេះវាធ្វើអោយសក្ខីកម្មរបស់បុគ្គលទាំងនេះ មិនគួរឲ្យទុកចិត្តបាន។ អង្គជំនុំជម្រះសង្កេតឃើញថាការជំទាស់ទាំងនេះត្រូវបានបដិសេធ ក្នុងករណីដែលសំណួរបើកត្រូវសួរជាមុន និងពេលដែលសម្រង់នានាត្រូវបានលើកឡើងក្នុងគោលបំណងសួរដេញដោលដល់អ្នកផ្តល់ភស្តុតាងនោះ។ អង្គជំនុំជម្រះរម្លឹកបន្ថែមទៀតថា ភាពអាចជឿជាក់បាននៃសក្ខីកម្មត្រូវវាយតម្លៃទៅតាមករណីជាក់ស្តែងដោយ ពិចារណាទៅលើកត្តាមួយចំនួនដូចជា ភាពស៊ីសង្វាក់គ្នាឬមិនស៊ីចង្វាក់គ្នាទាក់ទងនឹង អង្គហេតុសំខាន់ៗ ការអះអាងបញ្ជាក់និងកាលៈទេសៈនានានៃរឿងក្តី។ ការប្រើសំណួរនាំមុខដូចជាការប្រើប្រាស់ចម្លើយពីមុនរបស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីដើម្បីជួយរម្លឹកដល់ការ ចងចាំរបស់ពួកគេក៏ជាប់ពាក់ពន្ធផងដែរជាមួយនឹងភាពអាចជឿជាក់បាន និងភាពគួរឲ្យទុកចិត្តបាននៃសក្ខីកម្ម ដែលអង្គជំនុំជម្រះនឹងយកមកពិចារណា។*

*៥៤. នៅក្នុងសវនាការលើសំណុំរឿង០០២/០២មានបុគ្គលចំនួន១៨៥នាក់ បានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ពាក់ព័ន្ធនឹងបញ្ហានានានៃអង្គជំនុំជម្រះពាក់ព័ន្ធនឹងបញ្ហានានានៃអង្គសេចក្តី ដែលត្រូវធ្វើការវិនិច្ឆ័យដែលក្នុងនោះមានសាក្សីចំនួន១១៤នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៦៣នាក់និងអ្នកជំនាញចំនួន៨នាក់។បុគ្គលចំនួន១៥នាក់បានបង្ហាញខ្លួនតាមរយៈប្រពន្ធ័សោតទស្សន៍។*

### ២.៤.៤.៣. ភស្តុតាងជាឯកសារ

*នៅថ្ងៃទី៨ ខែមេសាឆ្នាំ២ ០ ១ ៤ អង្គជំនុំជម្រះបានណែនាំដល់ភាគីទាំងអស់ឲ្យផ្តល់បច្ចុប្បន្នភាព នៃបញ្ជីឯកសារដែលបានដាក់កាលពីលើកមុន និងបញ្ជីវត្ថុតាងសម្រាប់សំណុំរឿង ០០២/០២ រួមទាំងការរៀបរាប់អំពីលក្ខណៈ និងខ្លឹមសាររបស់ឯកសារទាំងនោះព្រមទាំងចំណុចពាក់ព័ន្ធទៅនឹងដីការដំណោះស្រាយផងដែរ។* **(នៅមានត)**

***អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា***

# ភាពយន្តឯកសារ «ឆ្នាំព្រៃ»

ភាពយន្តឯកសារ«ឆ្នាំព្រៃ» នឹងត្រូវចាក់បញ្ចាំងជាលើកចុងក្រោយក្នុងឆ្នាំ២០១៩ នេះសម្រាប់ក្រុមយុវជន- យុវនារីនៃវិទ្យាល័យត្រពាំងតាវដើម្បីលើកកម្ពស់ ការយល់ដឹង ពីគំនិតផ្តួចផ្តើមគំរូវីរភាពនិងការតាំងព្រះទ័យយ៉ាងមុតមាំរបស់ព្រះតេជគុណប៊ុន សាលូតនិងសហគមន៍របស់ព្រះតេជគុណក្នុងការការពារព្រៃឈើនិងធនធានធម្មជាតិ។ វិទ្យាល័យនេះស្ថិតនៅចម្ងាយប្រមាណជាង ១០គីឡូម៉ែត្រប៉ុណ្ណោះពី «ព្រៃសហគមន៍សង្ឃរុក្ខវន្ត» ដែលជាគំរបព្រៃឈើជាង៣ ម៉ឺនហិកតា។មួយផ្នែកធំនៃព្រៃឈើអភិរក្សនេះគឺបាន គ្របដណ្តប់មកលើស្រុកអន្លង់វែង ដែលធ្លាប់ជាទីតាំងតស៊ូចុងក្រោយរបស់ចលនាខ្មែរក្រហម។

ភាពយន្តឯកសារ «ឆ្នាំព្រៃ» នេះត្រូវបានបង្កើតឡើងដើម្បីជាការផ្ញើសាររំឭក និងដាស់តឿនដល់មនុស្សគ្រប់រូបឲ្យចូលរួមចំណែក និងលះបង់កម្លាំងកាយចិត្តព្រមទាំងលះបង់ចោលនូវកិលេសទាំងឡាយ សម្រាប់បុព្វហេតុសមូហភាពនៃសហគមន៍និងប្រទេសជាតិ។គំរូវីរភាពរបស់ព្រះតេជគុណប៊ុនសាលូតបាន និងកំពុងជំរុញទឹកចិត្តដល់ព្រះសង្ឃ និងបថុចជនទាំងឡាយឲ្យចូលរួមក្នុងបុព្វហេតុការពារ ធនធានធម្មជាតិនៅទីឋានមួយដ៏ស្ងប់ស្ងាត់ប្រកបទៅដោយភាពស្រស់ត្រកាលនេះដែរ។

តាំងពីបុរាណកាលមក ព្រៃឈើបានគ្របដណ្តប់មកលើទិដ្ឋភាពរស់នៅប្រចាំថ្ងៃរបស់មនុស្ស។ ការពឹងផ្អែកនិងការអាស្រ័យផលពីព្រៃឈើធម្មជាតិ គឺបានកើតឡើងដំណាលគ្នាទៅនឹងការកកើតនៃជីវិតមនុស្សដែរ។ ខ្សែភាពយន្តឯក



ព្រះតេជគុណ ប៊ុន សាលូត កំពុងមានសង្ឃដីកាទៅកាន់សិស្សានុសិស្សមុនការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ «ឆ្នាំព្រៃ»

សារនេះបាននិងកំពុងរួមចំណែកមួយដ៏សំខាន់ក្នុងការបណ្តុះការយល់ដឹងសម្រាប់សាធារណជនក្នុងបំណងថែរក្សា និងបណ្តុះមនោសញ្ចេតនាអាណិតអាសូររវាងមនុស្ស ទៅលើធនធានធម្មជាតិដ៏មានតម្លៃនៅក្នុងសង្គមជាតិរបស់ខ្លួនៗ

មកដល់ពេលនេះខ្សែភាពយន្ត «ឆ្នាំព្រៃ» ត្រូវបានចាក់បញ្ចាំងចំនួន១១លើកដោយរាប់ទាំងវិទ្យាល័យ ត្រពាំងតាវផងៗខ្សែភាពយន្តនេះត្រូវបានចាក់បញ្ចាំងលើកដំបូងនៅរាជធានីភ្នំពេញ និងបន្តនៅតាមស្ថានទូតគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនព្រមទាំងនៅតាមបណ្តាខេត្តនានាក្នុងប្រទេសកម្ពុជារួមមាន៖ ខេត្តឧត្តរមានជ័យ តាកែវ ខេត្តសៀមរាបបាត់ដំបង និងចុងក្រោយបង្អស់គឺនៅក្នុងស្រុកអន្លង់វែងៗ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ បានជួយឧបត្ថម្ភគាំទ្រយ៉ាងពេញលេញចំពោះការចាក់ បញ្ចាំងភាពយន្តឯកសារនេះចំនួនពីរលើកនៅក្នុងស្រុកអន្លង់វែងៗ

នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ នេះខ្សែភាពយន្តនេះត្រូវបានរៀបចំឡើងនៅក្នុងបរិវេណ នៃវិទ្យាល័យត្រពាំងតាវដែលមានសិស្សានុសិស្សប្រមាណជាង៤០០នាក់ចូល រួមទស្សនាៗក្នុងឱកាសនោះដែរសៀវភៅ« ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)»ចំនួន៥០០ក្បាលត្រូវបានចែកជូនដល់សិស្សានុសិស្សនិងសាធារណជនៗ

ការចាក់បញ្ចាំងខ្សែភាពយន្ត «ឆ្នាំព្រៃ»ចំនួន១១លើកកន្លងមកសាធារណជនដែលចូលរួមសរុបមានចំនួនប្រហែលជាងបីពាន់នាក់ដែល ក្នុងនោះរួមមានព្រះសង្ឃសិស្សានុសិស្សនិងប្រជាជនជាដើមៗ

ទស្សនៈយោបល់គួរឲ្យកត់សម្គាល់ជាច្រើន ត្រូវបានសម្តែងចេញបន្ទាប់ពីបានទស្សនាផ្ទាល់ៗ សាធារណជនមួយចំនួនពិតជាយល់ស្របថាជីវិតមនុស្សតាំងពីកើត រហូតដល់ស្លាប់គឺត្រូវការព្រៃឈើៗឯអ្នកខ្លះទៀតយល់ថា ខ្លួនស្ទើរតែពុំជឿថាធនធានធម្មជាតិដ៏មានតម្លៃដូចជាព្រៃឈើនិងសត្វព្រៃ



សិស្សានុសិស្សនៅវិទ្យាល័យត្រពាំងតាវ

ក្នុងប្រទេសរបស់ខ្លួនអាចបន្តរក្សារហូតមកដល់ពេលបច្ចុប្បន្ននេះសោះ។ ប្រជាជនភាគច្រើនក្រោយពីបានទស្សនាខ្សែភាពយន្តនេះហើយបានបង្ហាញចេញ នូវក្ដីសង្ឃឹមយ៉ាងមុតមាំទៅវិញថាការថែរក្សាធនធានធម្មជាតិរបស់ខ្លួនតាមរយៈការលើកស្ទួយនូវតម្លៃព្រះពុទ្ធសាសនា ដោយការចូលជាបច្ច័យនិងជំនួយឧបត្ថម្ភផ្សេងៗ គឺជាកិច្ចការដែលយើងទាំងអស់គ្នាគួរតែអាចធ្វើទៅបាន។ អាស្រ័យហេតុនេះ ហើយទើបអ្នកចូលរួមទស្សនាភាពយន្តនេះមួយចំនួនបាននិយាយបន្ថែមទៀតថា ខ្លួនគាំទ្រនិងអប់រំកូនចៅ និងកុមារតូចៗរបស់ខ្លួនឲ្យរៀនស្គាល់ពីតម្លៃនៃការថែរក្សាបរិស្ថានធម្មជាតិ នៅក្នុងសហគមន៍រ



សិស្សានុសិស្សរង់ចាំការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ

បស់ខ្លួនឲ្យបានគង់វង្សទៅថ្ងៃអនាគត។ ទស្សនៈខ្លះទៀតបានភ្ជាប់នូវការភ្ញាក់ផ្អើលយ៉ាងខ្លាំង ទៅនឹងប្រវត្តិសាស្ត្ររបស់អន្លង់វែង ដោយនិយាយថាខ្លួនមិននឹកស្មានថាអន្លង់វែងបានវិវឌ្ឍន៍ចេញពីភាពអន្ធការ ឆ្ពោះទៅរកតំបន់ទាក់ទាញមួយតាមរយៈទេសចរណ៍បៃតង ប្រវត្តិសាស្ត្រនិងជីវៈចម្រុះបែបនេះសោះ។

តាមរយៈការចាក់បញ្ចាំងនូវខ្សែភាពយន្ត «ឆ្នាំព្រៃ» ជាច្រើនលើកកន្លងមកទីភ្នាក់ងារសារព័ត៌មានក្នុងស្រុក និងអន្ត



លោក លី សុខឃាង កំពុងធ្វើបទបង្ហាញទៅកាន់សិស្សានុសិស្ស

រជាតិប្រហែលជា២០ បានសរសេរនិងផ្សព្វផ្សាយយ៉ាងទូលំទូលាយអំពីការអភិរក្សព្រៃឈើ ដែលផ្ដួចផ្ដើមចេញពីព្រះតេជគុណប៊ុនសាលួត ដែលសហការជាមួយក្រុមការងាររបស់ព្រះអង្គនិងស្ថាប័នសមត្ថកិច្ច ដើម្បីតស៊ូជម្នះនឹងឧបសគ្គជាច្រើនក្នុងកិច្ចការពារព្រៃឈើនេះ។

ព្រះតេជគុណធ្លាប់មានសង្ឃដីការថា «ធម្មជាតិបានព្រមរស់នៅជាមួយមនុស្សហើយ នៅឡើយតែមនុស្សទៅវិញទេដែលពុំទាន់សម្របខ្លួនចេះរស់នៅជាមួយធម្មជាតិ»។

**សួត វិចិត្រ**

# ប៉ុត ជួន
# សមាជិកសភា

***កូនស្រីរបស់ ប៉ុត ជួន ឈ្មោះ ប៉ុត ចន្ទមារតី បាននិយាយប្រាប់ថា ៖***

*ឪពុករបស់ខ្ញុំកើតនៅឆ្នាំ១៩២០ គាត់ជាអ្នកស្នេហាជាតិម្នាក់និងជាសកម្មជននយោបាយ។ ឪពុកម្តាយរបស់ឪពុកខ្ញុំឈ្មោះគៀនប៉ុត និង អៀត នៃ បានឲ្យតម្លៃទៅលើការអប់រំគាត់ទាំងពីរ បានធ្វើអ្វីៗទាំងអស់ដើម្បីបញ្ជូនឪពុកខ្ញុំឲ្យចូលសាលារៀន។ ឪពុករបស់ខ្ញុំមានមុខតំណែងជាច្រើនក្នុងរាជរដ្ឋាភិបាល។ គាត់មាននាទីជាអ្នកកាន់បញ្ជីដីធ្លី ជានាយកគយនៅក្នុងខេត្តស្ទឹងត្រែងនិងជាមេឃុំក្នុងខេត្តកំពង់ចាម ហើយគាត់ក៏ត្រូវបានចាត់តាំងឲ្យធ្វើការងារ លើគម្រោងអភិវឌ្ឍ៥ឆ្នាំសម្រាប់រាជធានីភ្នំពេញដែរ។ គាត់ត្រូវបានជ្រើសតាំងជាសមាជិកសភាបម្រើការងារបានពីរអាណត្តិ ហើយគាត់ក៏ជាអ្នកកាន់បញ្ជីដីធ្លីរបស់ក្រុងដែរដែលមុខតំណែងនេះគាត់បានធ្វើការងាររហូតដល់ខែមេសាឆ្នាំ១៩៧៥។*

*ឪពុករបស់ខ្ញុំចង់ឲ្យប្រជាជនកម្ពុជា ស្រឡាញ់សេរីភាពនៃលោកសេរីជាខ្លាំង។ គាត់បានធ្វើការជាមួយមិត្តភក្តិដូចជាព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរីមតៈ លោកឧត្តមសេនីយ៍ លន់ នល់ ដែលនាំមកនូវគំនិតសាធារណរដ្ឋនិយមចូលប្រទេសកម្ពុជា។ (នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ទ្រង់សិរីមតៈបានជួយឧបនាយករដ្ឋមន្ត្រី លន់ នល់ ចាត់ចែងឲ្យសភាជាតិទម្លាក់ព្រះអង្គម្ចាស់នរោត្តម សីហនុ ដែលជាប្រមុខរដ្ឋរបស់ព្រះរាជាណាចក្រកម្ពុជា។ រដ្ឋសភាបានចាត់វិធានការបង្កើតឡើងនូវរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ដែលមានលោក លន់ នល់ ជាអ្នកដឹកនាំ)។*




*ប៉ុត ជួន នៅពិធីសម្ពោធរដ្ឋសភា ភ្នំពេញ ឆ្នាំ១៩៦៣ ឬឆ្នាំ១៩៦៤។ សម្តេចនរោត្តម សីហនុ ឈរនៅកណ្តាល។ មានសមាជិកសាធារណរដ្ឋខ្មែរច្រើនរូបបង្ហាញខ្លួននៅទីនោះ ដែលជាអ្នកទម្លាក់សម្តេចនរោត្តម សីហនុ (អ៊ិន តាំ, ចេង ហេង និង ទ្រិញ ហ៊ាញ) និងខ្មែរក្រហម (ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម)*

ឪពុករបស់ខ្ញុំចង់ឲ្យគ្រួសាររបស់គាត់រស់នៅជុំគ្នាៗថ្វីបើខ្ញុំបានរៀបការ និងមានកូនពីរហើយក៏ដោយ ក៏គាត់បានទទូចឲ្យយើងមករស់នៅជាមួយគាត់ដែរ។នៅពេលនោះយើងមានសមាជិក១៥នាក់ រស់នៅក្នុងផ្ទះធំរបស់គាត់មានទាំងប្អូនស្រីខ្ញុំស្មើនិងប្តីរបស់នាងរួមនិងកូនពីរនាក់, ប្អូនស្រីខ្ញុំពីរនាក់ទៀតគឺសួស្តីនិងធីតា, ជីដូនរបស់ខ្ញុំឈ្មោះអៀតឆៃនិងអ្នកបម្រើពីរនាក់ទៀត។ ឪពុករបស់ខ្ញុំ បានជួយដល់អ្នកផ្សេងទៀតដែរដោយបានផ្តល់ជាបន្ទប់ឲ្យស្នាក់នៅ និងផ្តល់អាហារដល់កូនក្មួយប្រុសស្រីជា ច្រើននាក់ មកពីគ្រួសារទាំងសងខាងនជួយឲ្យបានចូលសាលារៀន។

ឪពុករបស់ខ្ញុំចូលចិត្តតន្ត្រីនិងសិល្បៈ។ គាត់បានចូលរួមសំដែងនៅក្នុងរោងល្ខោនមួយ កាលពីពេលគាត់នៅក្មេង។ គាត់ជាតួឯកឈ្មោះសុផាតនៅក្នុងរឿងល្បីមួយ។ គាត់ចេះលេងឧបករណ៍ភ្លេងមួយចំនួនមានដូចជាព្យ៉ាណូស្គរ និងកូតទ្រ។ គាត់បានជំរុញលើកទឹកចិត្តកូនស្រីទាំងអស់ ឲ្យច្រៀងរាំនិងគូររូប ដែលកម្រមានឪពុកណាឲ្យកូនរៀនមុខវិជ្ជានេះណាស់នៅជំនាន់នោះ។ ឪពុករបស់ខ្ញុំតែងតែនាំយើងទៅអង្គុយមើលរបាំព្រះរាជទ្រព្យការសំដែងសិល្បៈផ្សេងៗ និងការប្រគុំតន្ត្រី។គាត់ក៏បាននាំខ្ញុំទៅមើលគារថ្មីមួយ គឺលោកជុំកែមដែលនាំចូលមកប្រទេសកម្ពុជានូវចង្វាក់រាំបបស្ទិមប្រទេសហៅថា "ទ្វីស" ។



សម្តេចនរោត្តមសីហនុ បំពាក់មេដាយកិត្តិយសជូនលោក ប៊ុត ជួន

ឪពុកខ្ញុំបានទទួលព័ត៌មានពីទំនាក់ទំនងនយោបាយរបស់គាត់ថាសាធារណរដ្ឋខ្មែរ និងចាញ់សង្គ្រាមឆាប់ៗជាមួយខ្មែរក្រហម។នៅក្នុងខណៈនោះ គាត់មានឱកាសច្រើនក្នុងការនាំគ្រួសារចាកចេញពីប្រទេស។គាត់បានជ្រើសរើសយកការស្នាក់នៅទីនេះដោយជឿជាក់ថា អ្នកដឹកនាំខ្មែរក្រហមនឹងមិនធ្វើបាបប្រជាជនរបស់ខ្លួនឯងទេ។ គាត់មិនបានស្រមើស្រមៃទៅរស់នៅកន្លែងផ្សេងទៀតឡើយ។

នៅពេលដែលខ្មែរក្រហមបានឈ្នះ សង្គ្រាមនៅឆ្នាំ១៩៧៥ខ្មែរក្រហមបានបង្ខំអ្នករស់នៅក្នុងក្រុងភ្នំពេញ ឲ្យចាកចេញ។ឪពុករបស់ខ្ញុំពិបាកចិត្តនិងតក់ស្លុតជាខ្លាំង។ គាត់បានប្រាប់យើងថា" ប្រសិនបើយើងចាកចេញពីផ្ទះយើងមិនអាចត្រឡប់មកវិញទេ"។ គាត់បានបន្តថាយើងរង់ចាំនៅផ្ទះយើងបីថ្ងៃទៀតប៉ុន្តែបើគ្មានជម្រើសផ្សេងយើងត្រូវតែចាកចេញ។ យើងគឺជាអ្នកចុងក្រោយគេ ក្នុងចំណោមអ្នកជិតខាងរបស់យើងដែលបានចាកចេញពីទីក្រុង។ខ្ញុំនៅចងចាំពីទឹកមុខអស់សង្ឃឹមរបស់ឪពុកខ្ញុំយើងបានដើរចូលក្នុងហ្វូងមនុស្សពីរលាននាក់ដែលរុញច្រានដោយការភ្លន់នឹងចុងកាណុងកាំភ្លើងឲ្យដើរតាមផ្លូវជាច្រើន។ឪពុករបស់ខ្ញុំ បានព្យាយាមមិនឲ្យពួកយើងមើលសាកសពជាច្រើននៅតាមដងផ្លូវក្នុងក្រុងភ្នំពេញទេ។

បន្ទាប់ពីស្នាក់នៅជ្រោយអំពិល រយៈពេលមួយខែមកស្បៀងអាហាររបស់យើងជិតអស់ ប៉ុន្តែសង្ឃឹមថាយើងនឹងអាចត្រឡប់ទៅផ្ទះវិញ។ បន្ទាប់មកខ្មែរក្រហមបានប្រកាសថាប្រជាជនកម្ពុជាទាំងអស់ ត្រូវតែត្រឡប់ទៅស្រុកកំណើតរ

របស់ខ្លួនឬទៅស្រែចម្ការនៅតាមជនបទ។ ហេតុនេះយើងបានសម្រេចចិត្តទៅស្រុកកំណើតរបស់ម្តាយខ្ញុំ។

នៅពេលយើងកំពុងឆ្លងទន្លេមេគង្គ តាមទូកចម្លងរបស់ខ្មែរក្រហមបងថ្លៃប្រុសខ្ញុំ បានឮខ្មែរក្រហមម្នាក់និយាយថាគាត់បានស្គាល់ឪពុករបស់ខ្ញុំ ដែលជាសមាជិកសភាជាតំណាងរាស្រ្តមណ្ឌលព្រែកពោធិ៍ជាភូមិ ដែលទូកចម្លងរបស់យើងកំពុងធ្វើដំណើរឆ្ពោះទៅទីនោះ។ ទូកចម្លងបានមកដល់ប្រាំងនៅម៉ោងប្រាំរសៀល នៅពេលនោះ ទាហានខ្មែរក្រហមមួយក្រុមបានដើរសំដៅមករកឪពុករបស់ខ្ញុំ រួចក៏ចាប់គាត់យកទៅដែលមេបញ្ជាការរបស់ខ្មែរក្រហមនៅចម្ងាយប្រហែល៥០០ម៉ែត្រពីកំពង់ចម្លងនោះ។

ប្រហែលម៉ោងពីរទៀតភ្លឺយោធាខ្មែរក្រហមបានត្រឡប់មកវិញដោយនាំយកលិខិតមួយច្បាប់ពីឪពុករបស់ខ្ញុំ។ គាត់បានសរសេរថា“ប្រសិនបើគាត់មានសំណាងល្អ........គាត់នឹងមកជួបជុំវិញ”។វាជាពេលវន្ទត់តក់ស្លុត សម្រាប់គ្រួសារយើងគ្មាននរណាម្នាក់ចង់ចាកចេញពីទីនោះដោយគ្មានរូបគាត់ទៅជាមួយឡើយប៉ុន្តែវាជាការពិតពួកយើងមិនត្រូវបានអនុញ្ញាតិឲ្យជួបគាត់ឡើយ។

យើងបានតាំងទីលំនៅនៅក្នុងភូមិស្តីជាភូមិកំណើតរបស់ម្តាយខ្ញុំបានប្រហែលពីរខែ។ខ្ញុំបានយល់សប្តិឃើញឪពុកខ្ញុំស្លៀកពាក់សាមញ្ញធម្មតាជិះលើដំរីមួយដែលហែហមដោយទេវតា ជាច្រើន។ ខ្ញុំ បាននិយាយប្រាប់ម្តាយខ្ញុំ និងប្អូនស្រីបី



ប៊ុន អៀន និង ប៊ុត ជួន បន្ទាប់ពីអពាហ៍ពិពាហ៏របស់អ្នកទាំងពីរនៅឆ្នាំ១៩៤០ នៅផ្ទះដំបូង នៅក្នុងខេត្តកំពង់ចាម។



ប៊ុត ចន្ទមារតី អាយុ៩ឆ្នាំ, ឆ្នាំ១៩៥៩, នៅខេត្តកំពង់ចាម

នាក់ទៀតពីការយល់សប្តិរបស់ខ្ញុំ។ បន្ទាប់មកយើងទាំងអស់គ្នាចាប់ផ្តើមយំព្រោះយល់ថា យើងបានបាត់បង់ឪពុកហើយ។វាហាក់ដូចជាគាត់ បានមករកខ្ញុំនៅក្នុងយល់សប្តិនោះ និងបាននិយាយលាយើងទាំងអស់គ្នា។ខ្ញុំគិតថា ឪពុករបស់ខ្ញុំបានស្លាប់នៅថ្ងៃនោះហើយព្រលឹងរបស់គាត់បានហោះទៅកាន់ឋានសួគ៌។

រយៈពេលបួនឆ្នាំដែលយើងបានរស់នៅក្នុងរបបខ្មែរក្រហម ខ្ញុំបានរៀនសម្របខ្លួនពេញលេញទៅនឹងរឿងរ៉ាវថ្មីនៃជីវិតខ្ញុំបានរៀនពីការដាំដុះ នៅស្រែចម្ការរកចំណីអាហារ និងលួចចំណីអាហារដោយប្រថុយប្រថានជាមួយនឹងសេចក្តីស្លាប់។ ខ្ញុំ មានកូនស្រីទីបីម្នាក់ទៀតឈ្មោះចិន្តាពេជ្រ ដែលមានទម្ងន់មួយគីឡូក្រាមនៅពេលនាងកើតមក។ ខ្ញុំ បានរៀនរស់នៅដែលព័ទ្ធជុំវិញដោយការភ័យខ្លាចការអត់ឃ្លាន និងជំងឺដង្កាត់មិនមានថ្នាំព្យាបាល។

នៅក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហមបានបញ្ជូនប្តីរបស់ខ្ញុំពីការដ្ឋានត្រឡប់មកផ្ទះវិញ។ គាត់គិតថាគាត់ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅតាមផ្លូវ ប៉ុន្តែខ្មែរក្រហមមិនបានចាប់គាត់ឡើយ។ប៉ុន្តែខ្មែរក្រហមបានមកតាមរកគាត់ នៅពេលយប់ជ្រៅនិងបញ្ជាឲ្យគាត់ទៅចូលរួមប្រជុំមួយ។ នៅពេលមកដល់កន្លែងខ្មែរក្រហមបានចងដៃប្តីរបស់ខ្ញុំនឹងខ្សែក្រហមរួចបណ្តើរគាត់ទៅមន្ទីរសន្តិសុខ។ ទោសឧក្រិដ្ឋរបស់គាត់គឺគាត់ធ្លាប់បានធ្វើជាគ្រូបង្រៀន។

ជាចៃដន្យខ្ញុំបានជួបមិត្តហុកគណៈតំបន់ ខ្ញុំបានឈរទល់មុខគាត់រួចសួរគាត់ថា ហេតុអ្វីបានជាចាប់គ្រូបង្រៀនស្លូតត្រ



ប៉ុត ស៊ុនថូ (ប្អូនស្រីពៅ ប៉ុត ដួន, ប៊ុន អៀន, លោកយាយឡាត, ប៉ុត ដួន, ឆ្នាំ១៩៤១, នៅខេត្តកំពង់ចាម

ង់ដែលមិនបានធ្វើអ្វីខុសក្រៅពីខំអប់រំ និងបង្រៀនក្មេងៗ?។ បន្ទាប់មកមិត្តហុកបានទៅមន្ទីរសន្តិសុខ និងបាននិយាយជាមួយប្តីរបស់ខ្ញុំយ៉ាងយូរ អ្នកទាំងពីរមានភាពសាមញ្ញស្និទ្ធស្នាលនឹងគ្នាមិត្តហុក បានសារភាពថាខ្លួនក៏ធ្លាប់បានធ្វើជាសាស្ត្រាចារ្យដែរ។ មិត្តហុក បាននិយាយប្រាប់ប្តីខ្ញុំថាវាមិនមានសុវត្ថិភាពរស់នៅក្នុងឃុំស្ពឺនេះទៀតទេ ហើយបានបញ្ជាឲ្យគ្រួសារខ្ញុំផ្លាស់ប្តូរទៅរស់នៅភូមិមួយផ្សេងទៀត នៅក្បែរនោះដោយជិះរថយន្តៗពីរថ្ងៃក្រោយមក ប្តីខ្ញុំត្រូវបានដោះលែងពីមន្ទីរសន្តិសុខ។

ពីរបីថ្ងៃក្រោយមកម្តាយខ្ញុំ និងប្អូនស្រីធីតាត្រូវបានជ្រើសឲ្យផ្លាស់ទីលំនៅទៅនៅភូមិថ្មីមួយនៅក្នុងតំបន់៤២។ខ្ញុំមានការព្រួយបារម្ភពីធីតានាងអាយុ១៧ឆ្នាំគត់ មិនអាចថែរក្សាម្តាយខ្ញុំបានទេ។ក្មេងស្រីមិនទាន់រៀបការជាច្រើន មិនបានអនុញ្ញាតិឲ្យធ្វើការនៅក្នុងភូមិទេ។ អ៊ីចឹងម្តាយខ្ញុំ នៅម្នាក់ឯងស្ទើរពេញមួយថ្ងៃ។យើងបានអង្វរខ្មែរក្រហមឲ្យបញ្ជូនយើងទាំងអស់គ្នាទៅនៅជាមួយម្តាយខ្ញុំ និងប្អូនស្រីប៉ុន្តែបើទៅទាំងអស់គ្នាវាប្រឆាំងនឹងបទបញ្ជារបស់មិត្តហុក។ ខ្មែរក្រហមបានប្រាប់យើងឲ្យនិយាយកុហកអ្នកភូមិផ្សេងទៀតថា រថយន្តពេញណែនហើយ។រថយន្តបានបើកចេញទៅ ចម្ការកៅស៊ូដោយនាំយកប្រជាជនទាំងអស់ នៅលើរថយន្តទៅសម្លាប់ដោយប្រើឧបករណ៍ដំបងព្រនង់ រួចរុញទម្លាក់ចូលទៅក្នុងអណ្តូងដែលមានជម្រៅជ្រៅៗជាច្រើន។ នៅក្នុងចំណោមអ្នកទាំងនោះមានគ្រួសារឪពុកមាខ្ញុំ និងកូនក្មួយឪពុករបស់ខ្ញុំទាំងអស់គ្នាមានចំនួនសាមសិបនាក់។ក្រោយមកយើងដឹងថាមិត្តហុកត្រូវបានប៉ុលពតកម្ទេចចោល។

នៅដើមឆ្នាំ១៩៧៩ យើងបាន ទទួលព័ត៌មានសំខាន់ខ្លះ



*ញ៉ាក់ សម្ព័ស្សមុនី អង្គុយលើភ្លៅឪពុកគាត់ និងញ៉ាក់ មារតីអង្គុយលើភ្លៅម្តាយគាត់, ឆ្នាំ១៩៧១, នៅផ្ទះរបស់ពួកគេ នៅក្រុងភ្នំពេញ*

តាមវិទ្យុវ៉ៃដៃ តូចមួយ ដែលលាក់ទុកនៅក្នុងភូមិ។ សំឡេងសហរដ្ឋអាមេរិកបានរាយការណ៍ថាមានចំនួនជនភៀសខ្លួនដ៏ច្រើនបានហូរចូលប្រទេសថៃ។ យើងបានប្រមូលចំណីអាហារនិង គ្រឿងផ្គត់ផ្គង់ ហើយចាប់ផ្តើមធ្វើដំណើរចេញពីតំបន់កណ្តាលប្រទេសកម្ពុជា ទៅកាន់ព្រំដែន ថៃ ដែលមានចម្ងាយ ៨០០គី ឡូម៉ែត្រៗធ្វើដំណើរដោយដើង និងរទេះគោឆ្លងកាត់សមរភូមិ ប្រយុទ្ធ ជាច្រើនរវាង កងទ័ពវៀតណាម និងខ្មែរក្រហមក្រុមរបស់យើង មានសមាជិក២៦គ្រួសារនិងមិត្តភក្តិដើរបានចម្ងាយ២០គីឡូម៉ែត្រក្នុងមួយថ្ងៃ។

ក្មួយស្រីរបស់ខ្ញុំពីរនាក់ហៅឡូណានិងសេរី( ឈ្មោះនេះមានន័យថា សេរីភាព) បានកើតនៅតាមផ្លូវ។ យើងបានជួលអ្នកនាំផ្លូវយើងកាត់ព្រៃស្រោងជាថ្នូរនឹងមាស និងគ្រឿងអលង្កាដែលឪពុករបស់យើង បានបន្សល់ទុក។ បន្ទាប់ពីមកដល់ជំរំជនភៀសខ្លួននៅក្នុងប្រទេសថៃយើងត្រូវបានយល់ព្រមឲ្យទៅតាំងទីលំនៅថ្មីនៅសហរដ្ឋអាមេរិក។

ការចងចាំរបស់ប៊ុតចន្ទ មារតី និងប្អូនស្រីពីឪពុករបស់ពួកគេ ៖



យុវតី ប៊ុន អៀន និងមិត្តរបស់នាង នៅឆ្នាំ១៩៣៨ ខេត្តកំពង់ចាម

នៅក្នុងវប្បធម៌កម្ពុជា កូនៗហាក់ ញញើតញញើមក្នុងការនៅជិតឪពុកនិងមិនហ៊ានសួរនាំពីសិទ្ធិអំណាច របស់គាត់ៗយើងផ្តល់តម្លៃដល់លោកឪពុក។ ទោះជាយ៉ាងណាក៏ដោយ ឪពុករបស់ខ្ញុំមិនមែនជាបុរសធម្មតាទេ គាត់ជាមនុស្សស្រឡាញ់ក្រុមគ្រួសារគាត់បានជំរុញឲ្យខ្ញុំច្រៀង និងសប្បាយជាមួយសិល្បៈទូទៅដែលមិនមែនជារឿងធម្មតា សម្រាប់បុរសកម្ពុជានៅក្នុងជំនាន់គាត់ៗ គាត់បាននាំយើងទៅញ៉ាំអាហារ

នៅភោជនីយដ្ឋានល្បីៗទស្សនាភាពយន្ត និងការប្រគុំតន្ត្រីនៅទូទាំងប្រទេស។ ចំណង់ចំណូលចិត្តរបស់ប៉ិតរស្មីជាមួយឪពុកខ្ញុំគឺនាងបានធ្វើបង្អែមបាយដំណើបស្វាយទុំ ឬធុរេនដែលឪពុកខ្ញុំចូលចិត្ត។

ប៉ិត សួស្តី បានចងចាំអំពីឪពុករបស់ខ្ញុំគាត់សុភាពរាបសានឹងបានជំរុញកូនស្រីទាំងអស់របស់គាត់ទទួលបាននូវការអប់រំល្អៗ។គាត់មិនមែនគិតតែពីគ្រួសារផ្ទាល់ខ្លួននោះទេ ប៉ុន្តែបានជួយដល់សាច់ញាតិទៀតផង។ គាត់បានផ្តល់កន្លែងស្នាក់នៅនិងអាហារដល់ក្មួយៗ ដែលជាសិស្សល្អៗទឹកចិត្តសប្បុរសធម៌របស់ឪពុកខ្ញុំ មិននៅត្រឹមហ្នឹងទេនៅពេលខ្លះគាត់បានជួយអ្នកស្រុកដែលមកពីស្រុកកំណើតរបស់គាត់ទៀត។

ប៉ិត ធីតា នៅពេលខ្ញុំមានអាយុ១៥ឆ្នាំខ្មែរក្រហមបានចាប់ឪពុកយើងបំបែកចេញពីគ្រួសារយើង។ នៅពេលព្រល



ប៉ិត រស្មី នៅក្នុងពិធីអាពាហ៍ពិពាហ៍របស់នាង

ប់មួយបន្ទាប់ពីការឆ្លងទូកដ៏យូរ នៅកំពង់ចម្លងរបស់ខ្មែរក្រហមខ្ញុំបានវង្វេងស្មារតី។ មុននេះខ្ញុំកំពុងអង្គុយនៅលើទូកឪពុករបស់ខ្ញុំបានដើរមករកខ្ញុំ គាត់អង្អែលក្បាលខ្ញុំថ្នមៗដែលជាទម្លាប់របស់គាត់បង្ហាញពីអារម្មណ៍ ស្រឡាញ់កូនគាត់ បានប្រាប់ខ្ញុំឲ្យជួយមើលរបស់របរផ្ទាល់ខ្លួនយើង ក្នុងខណៈដែលអ្នកធំៗបានរើរបស់ទាំងនោះចេញពីទូកចម្លង។ បន្ទាប់មកគាត់បានប្រាប់ទៀត« កូនមិនត្រូវទៅទីណាទេរង់ចាំនៅទីនេះ.. .........“គាត់បានញញឹមដាក់ខ្ញុំប្រាកដថាអ្វីៗទាំងអស់វារលូនត្រឹមត្រូវ។ នោះគឺជារូបភាពចុងក្រោយរបស់ខ្ញុំពីការចងចាំអំពីឪពុកខ្ញុំដែលដក់ជាប់ជាមួយខ្ញុំមកដល់ថ្ងៃនេះ។វាជាពេលចុងក្រោយនៅក្នុងជីវិតរបស់ខ្ញុំដែល ខ្ញុំមានអារម្មណ៍ថាឪពុករបស់ខ្ញុំស្រឡាញ់និងការពារខ្ញុំ»។

***រូបថត និង អត្ថបទដោយមជ្ឈមណ្ឌលឯកសារកម្ពុជា***

# តាំង ហាងម៉េង ៖ មន្ត្រីរុក្ខាប្រម៉ាញ់

***កូនប្រុសរបស់តាំងហាងម៉េង ឈ្មោះម៉េង រស្មីបាន រៀបរាប់អំពីរឿងរ៉ាវរបស់ឪពុកគាត់ថា ៖***

*ឪពុកខ្ញុំជាប្រធានរុក្ខាប្រម៉ាញ់ និងអភិរក្សសត្វព្រៃ នៅក្រសួងកសិកម្ម។ នៅឆ្នាំ១៩៧៣ ក្រសួងបានចាត់តាំងគាត់ឲ្យទៅត្រួតពិនិត្យការងារនៅតាមបណ្តោយឆ្នេរសមុទ្រឯខេត្តកោះកុង។ គាត់បានសម្រេចចិត្តនាំគ្រួសារទៅកោះកុងបន្ទាប់ពីចូលឆ្នាំខ្មែរនៅឆ្នាំ១៩៧៥។ ប៉ុន្តែអ្វីៗត្រូវបានប្តូរផ្លាស់នៅថ្ងៃទី១៧ខែមេសា។*

*នៅពេលដែលខ្មែរក្រហមដណ្តើមបានទីក្រុងភ្នំពេញ គ្រួសារយើងបាននៅក្នុងក្រសួងកសិកម្ម។ ឪពុកខ្ញុំ បានប្តូរការិយាល័យរបស់គាត់ ទៅជាជម្រកការពារគ្រាប់ផ្លោងចូលក្នុងទីក្រុងដែលបាញ់ដោយកងទ័ពរំដោះ។ មេបញ្ជាការជាន់ខ្ពស់ម្នាក់មកពីភូមិភាគបូព៌ា បានចូលក្នុងបរិវេណក្រសួងពីព្រោះគាត់មិនធ្លាប់បានស្គាល់ទីក្រុងភ្នំពេញ គាត់បានសុំឲ្យឪពុកខ្ញុំបើករថយន្តជូនគាត់នៅជុំវិញនោះ។ ខ្ញុំបានអង្គុយនៅចាំងក្រោយនៃរថយន្តឡង់រ៉ូវ៉ែ។*

*ឪពុកខ្ញុំបានចតរថយន្តនៅខាងមុខ ទិសថស្ថានមួយហើយបានចូលទៅខាងក្នុងជាមួយមេបញ្ជាការនោះពេលចេញមកវិញគាត់យកបានថ្នាំពីរថង់មកជាមួយ មានថ្នាំសម្រាប់ព្យាបាលជំងឺគ្រុនចាញ់រាករូស និងឈឺចាប់។ មេបញ្ជាការនោះបានសួរថា«អ្នកឯងបានប្រាប់ខ្ញុំថា ជាតែកុងឡានហេតុម្តេចបានជាស្គាល់ប្រភេទថ្នាំពេទ្យច្រើនម្ល៉េះ?»។*

*ឪពុកខ្ញុំបានឆ្លើយទាំងញញឹមថា «វាមិនមានចម្លែកអីទេសម្រាប់តែកុងឡាន របស់អនុរក្សព្រៃឈើត្រូវតែស្គាល់ថ្នាំពេទ្យច្រើនមុខ។ខ្ញុំធ្លាប់បើកបរចូលក្នុងតំបន់គ្រុនចាញ់និងបានរៀនសម្គាល់ប្រើប្រាស់ថ្នាំពេទ្យជាច្រើន»។*

*មេបញ្ជាការនោះបាននិយាយខ្សឹបៗ ប្រាប់ឪពុកខ្ញុំថា «អង្គការបានប្រកាសថា ប្រជាជននឹងត្រូវជម្លៀសចេញក្នុងរយៈពេលខ្លីមួយ(បីថ្ងៃ)។ ជាក់ស្តែងវាមិនប្រាកដថានៅពេលណាពួកគាត់ ត្រូវបានអនុញ្ញាតឲ្យត្រឡប់មកវិញទេ។ នៅពេលដែលអ្នកឯងចេញទៅតំបន់ជនបទ អ្នកមិនត្រូវយកប្រាក់កាសទៅជាមួយទេព្រោះអីប្រាក់មិនត្រូវបានប្រើប្រាស់នៅទីនោះទេ។ យកល្អអ្នកត្រូវយកអង្ករឲ្យបានច្រើនអំបិល និងប្រហុកបើអាចយកបាន។ អ្នកឯងគ្រាន់តែជាតៃកុងឡាន ប៉ុណ្ណោះអ្នកមិនមានបញ្ហាអ្វីឡើយ។ ប៉ុន្តែ យោធានិងមន្ត្រីរដ្ឋការនឹងមានបញ្ហា»។ មេបញ្ជាការនោះ បានដឹងថាឪពុកខ្ញុំកើតនៅក្នុងខេត្តពោធិ៍សាត់ គាត់បាននិយាយទៀតថ«អង្គភាពគាត់នឹងចេញទៅបាត់ដំបង"។ប្រសិនបើអ្នកយល់ព្រមទៅជាមួយយើង...... ខ្ញុំនឹងជូនគ្រួសាររបស់អ្នកទៅស្រុកកំណើត»។*

*ប៉ុន្តែនៅពេលដែលឪពុកម្តាយខ្ញុំ ពិភាក្សារឿងនេះម្តាយខ្ញុំមិនយល់ព្រមទៅពោធិ៍សាត់ទេ។ គាត់នឹករឭកសាច់ញាតិរបស់គាត់នៅក្នុងតំបន់រំដោះ(ព្រោះបានបែកគ្នាជាច្រើនឆ្នាំមកហើយ) ឪពុកខ្ញុំមិនបានជំទាស់នឹងបំណងប្រាថ្នារបស់ម្តាយខ្ញុំទេ។យើងទាំងអស់គ្នា បានចេញទៅភូមិកំណើតខាងឪពុករបស់ម្តាយខ្ញុំនៅខ្ពបលើក្នុងខេត្តកណ្តាល។*

*មានឈ្លបសហករណ៍ម្នាក់ឈ្មោះសាត រស់នៅចម្ងាយ៥០ម៉ែត្រពីផ្ទះរបស់យើង។ គាត់មាន«បញ្ជីខ្មៅ»ហើយអង្គការបានអនុញ្ញាតឲ្យគាត់ ធ្វើសេចក្តីសម្រេចចិត្តដោយមិនមានកំណត់ក្នុងការសម្លាប់មនុស្ស។ បញ្ជីខ្មៅមានរាយឈ្មោះប្រជាជន១៧មេសាជាច្រើន និងប្រជាជនមូលដ្ឋានខ្លះៗដែលជាជនជាតិចិនឬកម្ពុជាក្រោម (ភូមិរបស់ប្រជាជនកម្ពុជាដែល*



តាំង ហាងម៉េង

បញ្ចូលជា ឧបសម្ព័ន្ធដោយប្រទេសវៀតណាម)។ជីវិតរបស់ប្រជាជនត្រូវបានកំណត់ដោយ ចុងប៊ិកពណ៌ក្រហមរបស់សាត។ឈ្មោះរបស់ប្រជាជនដែលបានសរសេរដោយប៊ិកពណ៌ក្រហម នឹងត្រូវសម្លាប់។

មានពេលខ្លះមីងរបស់ខ្ញុំ ឈ្មោះញ៉ឹងបានអង្វរសាតឲ្យទុកជីវិតឲ្យឪពុកខ្ញុំ។ បន្ទាប់ពីគាត់អង្វរសាតច្រើនដងមក សាតបានប្រាប់មីងខ្ញុំថា «កុំបារម្ភ.......ប្រសិនបើខ្ញុំចង់ឲ្យវាស្លាប់វានឹង.....»។ មីងរបស់ខ្ញុំជឿថាសាតនិយាយដូច្នេះមិន

បានយល់ពីអត្ថន័យនៃសំដីរបស់គាត់ឡើយ។ នៅយប់នោះ ឈ្លបបានចាប់ចងឪពុករបស់ខ្ញុំរួចបណ្តើរចេញទៅ។

នៅក្នុងចំណោមបងប្អូនខ្ញុំប្រាំនាក់ មានតែបងស្រីបង្អស់របស់ខ្ញុំទេដែលបានឃើញឪពុកខ្ញុំនៅគ្រាចុងក្រោយ។ ប្រជាជនបាន ទទួលបបរាវកក្កូកសម្រាប់អាហារថ្ងៃត្រង់។ ថ្ងៃមួយនៅក្នុងកំឡុងពេលសម្រាក បន្ទាប់ពីហូបអាហារថ្ងៃត្រង់ឪពុកខ្ញុំបានឃើញបងស្រីខ្ញុំកំពុងរកស្លាបព្រា។ គាត់បានសួរបងស្រីខ្សឹបៗ«ស្លាបព្រារបស់ឯងនៅឯណា?»បងស្រីខ្ញុំឆ្លើយថា«ខ្ញុំធ្វើឲ្យបាត់កាលពីយប់មិញខ្ញុំមិនដឹងថាអ្នកណាយកទេ!...»ឪពុកខ្ញុំបានឲ្យស្លាបព្រាគាត់ទៅបងស្រីខ្ញុំហើយប្រាប់ថា«យករបស់គាត់ទៅហើយហូបឲ្យបានលឿន»។ បងស្រីខ្ញុំបានសួរថា«តើប៉ាបានអីប្រើ?»គាត់ឆ្លើយថា«មិនអីទេទុកវាប្រើផ្ទាល់ខ្លួនចុះ»។ បន្ទាប់មកប៉ាបានដើរចេញទៅរោងបាយសម្រាប់មនុស្សចាស់វិញ។

ឪពុកខ្ញុំបានយល់យ៉ាងច្បាស់លាស់ថាចានមួយនិងស្លាបព្រាមួយជារបស់កម្មសិទ្ធិផ្ទាល់ខ្លួនយ៉ាងត្រឹមត្រូវដែលត្រូវបានអនុញ្ញាត ដោយគោលនយោបាយរបស់អង្គការខ្មែរក្រហម។គ្រប់ៗគ្នាមានថង់សំពាយតូចមួយដែលគ្មានអ្វីក្រៅពីចានមួយនិងស្លាបព្រាមួយ។

នៅយប់នោះបងស្រីខ្ញុំ បានលួចយកស្លាបព្រាមួយពីរោងបាយសហករណ៍ដោយបានគិតថា ត្រូវឲ្យស្លាបព្រារបស់ឪពុកខ្ញុំទៅគាត់វិញ។ ព្រឹកឡើងបងស្រីបានទៅរកឪពុកខ្ញុំប៉ុន្តែមិនឃើញគាត់ឡើយ។ បងស្រីបានទៅសួរបុរសម្នាក់នៅក្នុងក្រុមមនុស្សចាស់ពីដំណឹងឪពុកខ្ញុំ ក្នុងកំឡុងពេលសម្រាកបន្ទាប់ពីហូបអាហារថ្ងៃត្រង់។ គាត់ឈ្មោះមឿននៅក្នុងក្រុមជីកប្រឡាយជាមួយឪពុកខ្ញុំគាត់ស្ទុះមកសួរបងស្រីខ្ញុំថា«ឯងមកតាមរកឪពុករបស់ឯងមែនទេ?» បងស្រីខ្ញុំបានឆ្លើយថា«ចា៎ះខ្ញុំយកស្លាបព្រាមកឲ្យគាត់វិញ» មឿនបានឆ្លើយទាំងទឹកមុខទុក្ខព្រួយថា«មិនចាំបាច់រកឪពុកឯងទេ គាត់ត្រូវបានបញ្ជូនទៅធ្វើការឆ្ងាយហើយ»។បងស្រីខ្ញុំយល់ពីពាក្យសំដីរបស់មឿន។

មឿនបានប្រាប់បងស្រីទៀតថា ឈ្លបបានមកកាន់ប្រឡាយនេះជាទីដែលគាត់ និងឪពុកខ្ញុំកំពុងធ្វើការ។ អ្នកបញ្ជាម៉ាស៊ីនភ្លើងបានពន្លត់ម៉ាស៊ីនហើយការដ្ឋានបានងងឹត បន្ទាប់មកឈ្លបបានចាប់ចងឪពុកខ្ញុំរួចបណ្តើរកាត់ទឹកសំដៅទៅភូមិ។

ថ្ងៃបន្ទាប់មកយឿងប្រធានសហករណ៍បាននិយាយបែបប្រមាថប្រាប់មីងញ៉ឹងថា «យប់មិញគាត់បាននាំម៉េងឡើងទូកទឹកភ្នែករបស់ម៉េង បានស្រក់មកក្តៅខណ្ឌៗប៉ះដៃគាត់...នៅលើទូកម៉េងបានអង្វរគាត់ឲ្យបន្ធូរចំណង ព្រោះអីចំណងនោះវាធ្វើឲ្យលំបាកអន្តុយ...»។

ឪពុកម្តាយរបស់យឿងរស់នៅក្បែរផ្ទះយើង។ យឿងនិងម្តាយខ្ញុំធ្លាប់ជាមិត្តភក្តិនឹងគ្នាកាលពីនៅក្មេង និងធ្លាប់បានប្រឡែងលេងជាមួយគ្នា។ប៉ុន្តែ នៅក្នុងរបបនេះយឿងបានក្លាយទៅជាមនុស្សមានអំណាចដែល មិនមានអ្នកភូមិណាម្នាក់នៅក្នុងខ្ពបលើហ៊ានសម្លឹងមើលមុខគាត់បំឡើយ។ចាប់តាំងពីពេលដែលយើងមកដល់ឪពុកខ្ញុំ ធ្លាប់បានសុំទោសចំពោះយឿងដែលគាត់ មិនបានទៅលេងឪពុកម្តាយរបស់យឿង។ ហេតុនេះហើយយឿងអាចតាមឃ្លាំមើលពីសកម្មភាពរបស់ឪពុកខ្ញុំ។

យឿងបាននិយាយថាឪពុកខ្ញុំ ត្រូវបានធ្វើទារុណកម្ម និងសម្លាប់ចោលនៅយប់នោះ ដោយអង្គភាពសន្តិសុខនៃមន្ទីរសន្តិសុខកោះថ្មី។យឿងបានអនុវត្តពាក្យស្លោករបស់ខ្មែរក្រហមគឺ«ជីកស្មៅត្រូវជីកទាំងឫស»។ដូច្នេះបន្ទាប់ពីឪពុកខ្ញុំត្រូវបានសម្លាប់យឿងបានបញ្ជាឲ្យខ្ញុំទៅកសាងខ្លួននៅកងចល័តកុមារនៅក្នុងភូមិមួយផ្សេងទៀត។ ធ្វើបែបនេះយឿងជឿជាក់ថាខ្ញុំត្រូវបានកម្ទេចចោល។

បងស្រីខ្ញុំបានរក្សាទុកស្លាបព្រា ដែលបានលួចសម្រាប់ឲ្យឪពុកខ្ញុំវិញរហូតដល់សព្វថ្ងៃ។បងស្រីបានដាក់ស្លាបព្រានោះនៅជិតរូបថតឪពុកខ្ញុំ និងគោរពបូជាស្លាបព្រានោះដែលជាកម្មសិទ្ធិដ៏មានតម្លៃសម្រាប់គ្រួសារយើង។

***រូបថត និង អត្ថបទដោយមជ្ឈមណ្ឌលឯកសារកម្ពុជា***

# អ៊ុម ស្បោង
# ប្រធានសហករណ៍ (សម័យសង្គមរាស្ត្រនិយម)

ប្អូនស្រីរបស់ អ៊ុម ស្បោង ឈ្មោះ អ៊ុម សារ៉េត បាន រៀបរាប់ប្រាប់ថា ៖

នៅក្នុងចំណោមកូនៗទាំងប្រាំពីរនាក់នៃគ្រួសារយើងស្បោងជាកូនដែលមានសំណាងជាងគេដោយគាត់មានមុខតំណែងខ្ពង់ខ្ពស់ៗ គាត់ជានិស្សិតពូកែម្នាក់និងចេះភាសាបារាំងយ៉ាងស្ទាត់ជំនាញៗ នៅក្នុងរបបសម្តេចនរោត្តមសីហនុ គាត់បានប្រឡងជាប់មន្ត្រីរាជការស៊ីវិល និងបានក្លាយជាប្រធានសហករណ៍មួយនៅក្នុងខេត្តព្រៃវែងៗ គាត់បានគ្រប់គ្រងប្រព័ន្ធកសិកម្មទូទាំងខេត្តៗ

ស្បោងចូលចិត្តខ្ញុំខ្លាំងណាស់ៗ នៅពេលខ្ញុំឈឺគាត់បានធ្វើដំណើរយ៉ាងឆ្ងាយមកយកខ្ញុំទៅមន្ទីរពេទ្យមួយនៅក្នុងក្រុងភ្នំពេញៗនៅពេលណាខ្ញុំមិនសប្បាយចិត្តគាត់បានលួងលោមខ្ញុំនិងជួយលើកទឹកចិត្តខ្ញុំៗ

នៅឆ្នាំ១៩៧៤ ទាហានលន់នល់បានជម្លៀសគ្រួសារយើង និងអ្នកភូមិផ្សេងៗទៀតទៅកាន់ខេត្តកណ្តាលព្រោះទាហាន លន់ នល់ ត្រូវវាយប្រយុទ្ធតទល់នឹងខ្មែរក្រហមនៅក្នុងស្រុករបស់យើងៗ ប៉ុន្តែពីរបីសប្តាហ៍បន្ទាប់មកខ្មែរក្រហមបានជម្លៀសប្តីខ្ញុំកូនៗនិងខ្ញុំឲ្យទៅខេត្តកំពង់ចាមៗ ក្រោយមកមិនយូរប៉ុន្មាន ខាងលន់នល់បាននាំយើងទៅភ្នំពេញវិញតាមទូកៗ

នៅក្នុងឆ្នាំ១៩៧៥គ្រួសារយើងបានត្រឡប់ទៅស្រុកកំណើតវិញៗ ផ្ទះរបស់យើងត្រូវបានបំផ្លាញនិងមិនអាចស្នាក់នៅទីនោះកើតទេៗ ម្តាយខ្ញុំបានសុំការអនុញ្ញាតពីខ្មែរក្រហម ដើម្បីរស់នៅក្នុងភូមិរបស់យើង ប៉ុន្តែខ្មែរក្រហមបាននិ



អ៊ុម ស្បោង និង អ៊ុម សារ៉េត នៅក្នុងពិធីមង្គលការរបស់ អ៊ុម ស្បោង នៅខេត្តកំពង់ស្ពឺ ឆ្នាំ១៩៧២

យាយថាទេ។ខ្ញុំបានគិតថា ដោយសារខ្មែរក្រហមបានសង្ស័យថាគ្រួសារយើងជាគ្រួសារអ្នកមាន និងជាគ្រួសារដែលមានមុខតំណែងខ្ពស់។ ស្បោង ត្រូវបានចោទប្រកាន់ថាជានាយទាហានជាន់ខ្ពស់ព្រោះគាត់មានរូបរាងសង្ហារ។ ក្រោយមកគាត់បានធ្វើឲ្យគោមួយក្បាលលង់ទឹកងាប់ដោយចៃដន្យមិនយូរប៉ុន្មានខ្មែរក្រហមបានចាប់គាត់យកទៅ។ អង្គការក៏បានបញ្ជូនប្រពន្ធនិងកូនរបស់គាត់ទៅសម្លាប់ដែរ។

ចាប់ពីពេលនោះមកខ្មែរក្រហម បានតាមដានគ្រួសារយើង។ប្រធានភូមិឈ្មោះរ៉េតបានសួរអំពីជីវប្រវត្តិរបស់យើង។ខ្ញុំបានប្រាប់ទៅរ៉េតវិញថាប្តីខ្ញុំជាអ្នកធាក់ស៊ីក្លូ។ ប៉ុន្តែរ៉េត មិនជឿខ្ញុំឡើយហើយនិយាយថា “កុំកុហកខ្ញុំដឹងហើយអ្នកឯងទាំងពីរជាគ្រូបង្រៀន”។ខ្ញុំបានបែកញើសជោគនៅពេលដែលរ៉េតសួរខ្ញុំចំដូច្នេះ ពីព្រោះខ្ញុំបាននិយាយប្រាប់ម្ចាស់ផ្ទះដែលយើងកំពុងរស់នៅនោះអំពីអតីតកាលរបស់យើង។ ខ្ញុំមិនប្រាកដថាម្ចាស់ផ្ទះបានរាយការណ៍អំពីយើងឲ្យទៅរ៉េតឬក៏អត់ទេ។

នៅក្នុងឆ្នាំ១៩៧៦ ឪពុករបស់យើងមិនអាចទ្រាំទ្រនឹងការស្រេកឃ្លានតទៅទៀត បានទេយើងបានយកល្អីកញ្ច្រែងចេញទៅរកចាប់សត្វល្អិតៗយកមកហូប។ ម្តាយរបស់ខ្ញុំបានប្រាប់ឪពុកខ្ញុំថាកុំឲ្យធ្វើទៀត ប៉ុន្តែឪពុករបស់ខ្ញុំមិនបានស្តាប់សំដីរបស់ម្តាយខ្ញុំទេ។ ថ្ងៃមួយ គាត់បានឃើញកម្មាភិបាលម្នាក់បានសម្លាប់ពស់ខៀវមួយក្បាល រួចទុកចោលនៅមាត់ប្រកឪពុកខ្ញុំបានយកពស់នោះទៅស្ងោរហូបទោះជាដឹងថាពស់នោះមានពិសក៏ដោយ។ ភ្លាមៗនោះគាត់បានហើមខ្លួនរួចក៏ស្លាប់ទៅ។ ប្អូនស្រីរបស់ខ្ញុំឈ្មោះសារីនិងអ្នកផ្សេងទៀតមានការស្រេកឃ្លានជាខ្លាំង បន្ទាប់មកកូនរបស់សារីម្នាក់បានស្លាប់។

យើងត្រូវបានជម្លៀសទៅកាន់ភូមិពីរផ្សេងទៀតនៅក្នុងរបបខ្មែរក្រហម។ការងាររបស់ខ្ញុំគឺកាប់ដើមទន្រ្ទានខែត្រលាយជាមួយដី-ផេះ-លាមកសត្វ និងលាមកមនុស្ស។គួរឲ្យខ្ពើមរអើមខ្លាំងណាស់ ប៉ុន្តែខ្ញុំត្រូវតែធ្វើបើមិនដូច្នោះទេខ្មែរក្រហមនឹងសម្លាប់ខ្ញុំ។

នៅទីនោះអ្នកភូមិទាំងអស់ មានការស្រេកឃ្លានយ៉ាងខ្លាំងហើយកូនៗរបស់យើងបានធ្លាក់ខ្លួនឈឺធ្ងន់។ មានមនុស្សប្រុសម្នាក់ធ្លាប់ធ្វើជាគ្រូពេទ្យនៅទីក្រុងភ្នំពេញ បានប្រាប់ខ្ញុំថាកូនស្រីរបស់ខ្ញុំឈឺបណ្តាលមកពី អត់អាហារជាច្រើនខែមកហើយនាងមានបញ្ហាពោះវៀនខ្លាំង។ដូច្នេះខ្ញុំយកខ្សែកមាសរបស់ខ្ញុំទៅដូរយកអង្ករមកដាំបាយឲ្យនាងហូប។ កូនស្រីខ្ញុំបានហូបបាយច្រើនណាស់។ ការណ៍ដែលនាងហូបច្រើននេះបានធ្វើឲ្យជំងឺរបស់នាងធ្ងន់ជាងមុន។ យប់មួយនោះនាងបានខ្សឹបប្រាប់ខ្ញុំសុំទឹកផឹក ខ្ញុំព្យាយាមយកទឹកឲ្យកូនស្រីផឹក ប៉ុន្តែអណ្តាតរបស់នាងហើមប៉ោង។ ឃើញសភាពរបស់កូនស្រីបែបនេះខ្ញុំបានដាស់ប្តីខ្ញុំ។កូនស្រីរបស់ខ្ញុំស្លាប់ហើយយើងបានត្រកងបីសពកូនស្រី និងស្រែកយំរហូតទល់ភ្លឺ។ បន្ទាប់មកប្តីខ្ញុំបានស្នើសុំបន្ទះក្តារពីកម្មាភិបាលម្នាក់សម្រាប់ធ្វើក្តារមឈូស ប៉ុន្តែកម្មាភិបាលនោះបានបដិសេធ។ ភ្លាមនោះកម្មាភិបាលម្នាក់នោះ បានយកចបកាប់មួយរួចប្រាប់ប្តីខ្ញុំឲ្យយកសពឲកូនស្រីរបស់យើងទៅក្នុងព្រៃក្រោយមន្ទីរពេទ្យ។កម្មាភិបាលម្នាក់នោះ និងប្តីខ្ញុំបានជីករណ្តៅកប់សាកសពកូនស្រីខ្ញុំនៅទីនោះ។

នៅចុងឆ្នាំ១៩៧៨ អ្នកភូមិម្នាក់ឈ្មោះសាង បានស្តាប់វិទ្យុជាសម្ងាត់ និងបានឮថាប្រជាជននិងត្រូវបានរំដោះក្នុងពេលឆាប់ៗនេះ។ គ្រប់គ្នាមានសេចក្តីត្រេកអរណាស់។ បន្តិចក្រោយមកមានការបាញ់កាំភ្លើងធំ និងរថពាសដែកនៅគ្រប់ទិសទី។ទាហានខ្មែរក្រហម បានរត់ភៀសខ្លួនចូលក្នុងព្រៃ។នៅពេលដែលកងទ័ពរំដោះចូលមកប្តី របស់ខ្ញុំកំពុងកាប់ឈើនៅឆ្ងាយពីភូមិ។ ខ្ញុំរង់ចាំមើលផ្លូវគាត់ត្រឡប់មកវិញអស់រយៈពេលដប់ថ្ងៃ។ នៅពេលគាត់មកដល់គាត់មិនអាចដើរទៅណាបានទេ។ នៅពេលមួយដែលគាត់មានកម្លាំងមាំទាំហើយ យើងបានសម្រេចចិត្តធ្វើដំណើរត្រឡប់មកភ្នំពេញវិញ។

***រូបថត និង អត្ថបទដោយមជ្ឈមណ្ឌលឯកសារកម្ពុជា***

# រូបថតពីខាលពិឃាតនៃជំរំជនភៀសខ្លួនឆ្នាំ១៩៧៩

កន្លងហួសរយៈពេល៤០ឆ្នាំហើយចាប់តាំងពីខ្ញុំបានទៅកាន់ជំរំ សាកែវ ក្នុងប្រទេសថៃ។ នៅក្នុងឆ្នាំ១៩៧៩ ខ្ញុំបានធ្វើដំណើរឆ្លងកាត់ទីក្រុងបាងកក ទៅកាន់ប្រទេសភូមា ហើយបានចំណាយអស់រយៈពេលមួយរសៀលដើម្បីថតរូបនៅក្នុងជំរំស្រះកែវ។ រូបភាពដែលខ្ញុំបានថតគឺបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តី Time និង Life និងទស្សនាវដ្តីផ្សេងៗជាច្រើនទៀតនៅអឺរ៉ុប។ វាគ្រាន់តែជាការចាប់ផ្តើមនៃការចែកចាយព័ត៌មាន និងរូបភាពពីវាលពិឃាតនៃជនភៀសខ្លួនដែលបានរត់ភៀសខ្លួនទៅដល់ប្រទេសថៃ។

នៅក្នុងមណ្ឌលថែទាំកុមារនៅក្នុងជំរំនោះ ខ្ញុំបានថតរូបក្មេងៗមួយចំនួននិងម្តាយម្នាក់ ព្រមទាំងកូនរបស់គាត់ដែលយើង អាចមើលឃើញជើងរំលេចចេញមកក្រៅតាមប្រឡោះដៃរបស់គាត់។ រូបថតនេះ បានជាប់ជ័យលាភីសារព័ត៌មានប្រចាំឆ្នាំ ពីមូលនិធិសារព័ត៌មានពិភពលោកនៅក្នុងប្រទេសហូឡង់ ថែមទាំងទទួលបានការបោះពុម្ពផ្សព្វផ្សាយយ៉ាងទូលំទូលាយថែមទៀត។ ក្នុងនាមខ្ញុំគឺជាអ្នកសារព័ត៌មានម្នាក់ខ្ញុំមិនពូកែខាងកត់ចំណាំឬទទួលបានឈ្មោះនោះទេ ហើយករណីនេះជាពិសេសចំពោះកុមារជាច្រើននៅមណ្ឌលថែទាំង ហើយមានកុមារមួយចំនួនឈឺទៀតផង។ ខ្ញុំ មិនអាចទទួលបានព័ត៌មានដែលទាក់ទងនឹងឈ្មោះ អាយុសម្រាប់ដាក់ចំណងជើងរូបថតរបស់ខ្ញុំនោះទេ។ ខ្ញុំដឹងថាស្ត្រីដែល ជាម្តាយនោះអាចជាម្តាយម្នាក់ ក្នុងចំណោមម្តាយរាប់ពាន់នាក់



ស្ត្រីម្នាក់កំពុងបីកូននៅក្នុងជំរំស្រះកែវប្រទេសថៃ



កុមារដែលមានរាងកាយស្គមស្គាំងដោយភាពអត់ឃ្លាន ក្រោយសង្គ្រាម

ផ្សេងទៀត ប៉ុន្តែ ប្រហែលជាអាចមានវិធីសាស្ត្រណាមួយ ក្នុងការស្វែងរកនាង និងស្គាល់ថានាងគឺជានរណា ថែមទាំងរឿងរ៉ាវផ្សេងៗទៀតរបស់នាង។ ចំពោះទារកវិញ ខ្ញុំពិតជាសង្ឃឹមថាទារកនោះនៅរស់រានមានជីវិត និងធំលូតលាស់បានយ៉ាងល្អៗដូចគ្នានោះដែរ ខ្ញុំមានអារម្មណ៍រំជួលចិត្តណាស់ចំពោះក្មេងតូចៗដ៏ស្រស់ស្អាត ដែលមុខមាត់របស់ពួកគេបានឆ្លុះបញ្ចាំងពីខ្សែជីវិតដែល ពោរពេញទៅដោយការឈឺចាប់និងភាពលំបាកលំបិន។ ក្ដីសង្ឃឹមរបស់ខ្ញុំ គឺថាប្រហែលជាមានវិធីសាស្ត្រណាមួយ ដើម្បីផ្សព្វផ្សាយ រូបថតទាំងអស់នេះនៅក្នុងសារពត៌មាន ឬតាមរយៈទូរទស្សន៍ក្នុងប្រទេសកម្ពុជា ហើយប្រហែលជា៤០ឆ្នាំក្រោយមកអាចមាននរណាម្នាក់ស្គាល់ និងអាចផ្ដល់ឈ្មោះរបស់នរណាម្នាក់ក្នុងចំណោមរូបថតទាំងនេះ។ លុយកាក់ មាស ប្រាក់ មិនមែនបានមកដោយឯកឯង ហើយគ្មានអ្វីបានមកដោយការមិនខិតខំជាជាងការព្យាយាម និងផ្សារភ្ជាប់ទំនាក់ទំនងដែលបានបាត់បង់ហើយប្រហែលជាចែករំលែករឿងរ៉ាវរបស់ពួកគេទៅកាន់មនុស្សគ្រប់គ្នានៅក្នុងពិភពលោកនេះ។ ខ្ញុំមានគម្រោងធ្វើដំណើរមកកាន់ប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍នៅក្នុងខែមេសាខាងមុខនេះ ដើម្បីជួបជាមួយអតីតអ្នកយកព័ត៌មានអំពីសង្គ្រាម ហើយខ្ញុំពិតជារីករាយនឹងធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ប្រទេសថៃ និងកន្លែងណាដែលមនុស្សទាំងអស់នេះអាចរស់នៅ។ កាលពីឆ្នាំមុន ខ្ញុំបានរៀបចំជួបជាមួយមនុស្សប្រហែល៨នាក់ ដែលខ្ញុំធ្លាប់បានថតរូបជាច្រើនឆ្នាំកន្លងមកហើយ។ អ្នកមិនអាចដឹងទេថាពេលណាមាននរណាម្នាក់កំពុងសម្លឹងមើលឬស្ដាប់អ្នក។ ដូច្នេះ ខ្ញុំដឹងថាវាពិតជាអាចទៅរួច។ ខ្ញុំពិតជាអរគុណខ្លាំងណាស់សម្រាប់ការជួយរបស់អ្នក។

***រូបថត និងអត្ថបទដោយមជ្ឈមណ្ឌលឯកសារកម្ពុជា***



*កុមារដែលមានរូបកាយស្គមស្គាំងដោយសារកង្វះអាហាររូបត្ថម្ភ*

# ប្រវត្តិរូប អ៊ឹង ដុយ

អ៊ឹង ដុយ កើតនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៤៣ នៅខេត្តស្វាយរៀង។ ឪពុករបស់ អ៊ឹង ដុយ ឈ្មោះ អ៊ឹង ដាង (ស្លាប់) និងម្តាយ ឈ្មោះ នាង សុគាន អាយុ៧០ឆ្នាំ (នៅឆ្នាំ១៩៧៦) រស់នៅជាមួយបងស្រី អ៊ឹង ហោសាក។ អ៊ឹង ដុយ ពីមុនមានមុខរបរជាគ្រូបង្ហាត់វិជ្ជាកាំភ្លើងធំ បានរៀបការជាមួយប្រពន្ធឈ្មោះ តាំង មួយហេង នៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៥៨។ តាំង មួយហេង កើតនៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៤៥ នៅខេត្តស្វាយរៀង មានមុខរបរ ជាមេផ្ទះ ស្នាក់នៅជាមួយបងស្រី អ៊ឹង ហោសាក ដែលមានទីតាំងស្ថិតនៅផ្ទះ១០០R ផ្លូវមុន្នីវង្ស បឹងត្របែក ភ្នំពេញ។

អ៊ឹង ដុយ បានចាកចេញពីប្រទេសកម្ពុជានៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៤ ដោយបុព្វហេតុនៃការចាកចេញពីប្រទេសកម្ពុជា គឺដើម្បីបំពេញកម្មសិក្សាវិជ្ជាកាំភ្លើងធំ។ អ៊ឹង ដុយ បានឈប់សំចតនៅអូខ្លាហូមា សហរដ្ឋអាមេរិក មុនពេលទៅដល់ប្រទេសបារាំងនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៦។ នៅប្រទេសបារាំង អ៊ឹង ដុយ រស់នៅទីក្រុងប៉ារីស។

អ៊ឹង ដុយ បានស្នើសុំស្ថានតំណាងបេសកកម្មរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាប្រចាំនៅ ប្រទេសបារាំង ដើម្បីប្តូរលិខិតឆ្លងដែន និងសុំត្រឡប់ចូលស្រុកវិញ ដោយមានការចុះហត្ថលេខារបស់សាមីខ្លួនផ្ទាល់ ធ្វើនៅប៉ារីស ថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៧៦។

ឯកសារស្នើសុំប្តូរលិខិតឆ្លងដែននេះត្រូវបានចុះលេខ N0582P និងមានក្រសួង ត្រួតពិនិត្យឃើញថាព័ត៌មានខាងលើនេះត្រឹមត្រូវតាម លិខិតឆ្លងដែនចាស់។ ក្រសួងយល់ព្រមតាមសំណូមពររបស់សាមីជន (អ៊ឹង ដុយ) ។ លិខិតនេះធ្វើនៅប៉ារីស ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៦ ដែលមានអ្នកទទួលខុសត្រូវ ក្រសួងលិខិតឆ្លងដែន ចុះហត្ថលេខាដោយឈ្មោះ តាន់ សម្បត្តិ។

លិខិតឆ្លងដែននេះ យល់ស្របព្រមតាមសេចក្តីបញ្ជាក់ខាងលើធ្វើនៅប៉ារីសថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៦ ដែលមានអ្នកទទួលខុសត្រូវក្រសួងកម្ពុជា ចុះហត្ថលេខាដោយឈ្មោះ ប៊ិចុងទី។

បេសកកម្មសម្រេចចេញលិខិតឆ្លងដែនឲ្យទៅសាមីជន (អ៊ឹង ដុយ)។ ធ្វើនៅប៉ារីស ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៦ ចុះហត្ថលេខាដោយឈ្មោះ កែម ធី (ជ.បេសកកម្ម)។

ប្រសិនបើបងប្អូនណា បានស្គាល់ឈ្មោះខាងលើ សូមទំនាក់ទំនងមកទស្សនាវដ្តី ស្វែងរកការពិត នៃមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈអាសយដ្ឋាន ៖ ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញឬលេខទូរសព្ទ០១២៩៩៦៧៥០ និង អ៊ីម៉ែល truth-bunthorn.s@dccam.org។ សូមអរគុណ!

**ដាត ចាន់សុនិតា**



អ៊ឹង ដុយ

# បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមចារទុកក្នុងសៀវភៅរំឭកវិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

ជៀប ជឿន ហៅ ផុន អាយុ៣៣ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅជើងព្រៃ ខេត្តកំពង់ចាម ជាកូនរបស់អ៊ំ ញឹម ជៀម និងអ៊ំស្រី អ៊ុត គួន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរទេះភ្លើង ថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះឆ បន្ទប់ធំ៥ បន្ទប់តូច៨។ ខ្មែរក្រហមសម្លាប់ ជៀប ជឿន នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៧៧។

ជៀប ឈុត ហៅ រុន មានអាយុ២៧ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅបារាយណ៍ ខេត្តកំពង់ធំ ជាកូនរបស់ពូ ជៀប ឡុង និងមីង គឹម ឡេង មានប្រពន្ធឈ្មោះ គាំ លីម ហៅ រ៉ែង មានកូនស្រី ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរកងពល៣១០ ថ្ងៃទី២២ ខែមករា ឆ្នាំ ១៩៧៧។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ជៀប យ៉េត ហៅ ភាន់ មានអាយុ២៤ឆ្នាំក្នុងឆ្នាំ១៩៧៧មានស្រុកកំណើតនៅដំបែ ខេត្តកំពង់ចាម ជាកូនរបស់ពូ ជៀប យ៉ុក និងមីង ញែម រ៉ែត ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រអ៊ុកស៊ីសែន ខ-១ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយសម្លាប់នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៧។

ជៀម ខេង មានអាយុ២៣ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅល្វាឯម ខេត្តកណ្តាល ជាកូនរបស់ពូ ជៀម ចេង និងមីង ឃីម អ៊ឹម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំពង់សោម ថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ឆ បន្ទប់ធំ៥ បន្ទប់តូច ១៣។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

ជៀមភាម ហៅភឹមមានអាយុ៤២ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតទាហាន មានស្រុកកំណើតនៅស្វាយរៀង ខេត្តស្វាយរៀងជាកូនរបស់លោកតា ឡឹក ជៀម និងលោកយាយ ម៉ម មុំមានប្រពន្ធឈ្មោះហាក់ស្រួយមានកូនប្រុស៤នាក់និងស្រី១នាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភ្នំស្រុកថ្ងៃទី២០ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ០៨ បន្ទប់តូច១៧។ ខ្មែរក្រហមសម្លាប់ជៀម ភាម នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៦។

ដៃ ជួន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅតំបន់២៥ ក្នុងឆ្នាំ១៩៧៦។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង មាន២ខុសគ្នា មួយនៅថ្ងៃទី២៧ និងមួយទៀតនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦។ រីឯកាលបរិច្ឆេទនៃការសម្លាប់ក៏មាន២ដែរ មួយនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦ និងមួយទៀតនៅខែកញ្ញា ឆ្នាំ១៩៧៧។

ដៃ សុវណ្ណ មានអាយុ២៩ឆ្នាំ ក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅកំពត ខេត្តកំពត ជាកូនរបស់ពូ ដៃ វ៉ិត និងមីង ប៉ែន ចិន មានប្រពន្ធឈ្មោះ ម៉ុច ដាលី ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅអូគ្រេះ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ១១ បន្ទប់ធំ ៩។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងគឺ នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ដៃ សែ មានអាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅបារាយណ៍ ខេត្តកំពង់ធំ ជាកូនរបស់ពូ កង់ សឿន និងមីង សាយ ធួង មានប្រពន្ធឈ្មោះ មុំ សៀងហៅ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រស្រា ស-២ ថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែ

ផក្នុងផ្ទះឆ បន្ទប់ធំ៣ បន្ទប់តូច១៧។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ខុសគ្នាមួយនៅថ្ងៃទី២៦ និងមួយទៀតនៅថ្ងៃទី២៧ខែតុលាឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ជ្រេង ផួន មានអាយុ៣២ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រៃឈរខេត្តកំពង់ចាមជាកូនរបស់អ៊ំ ជ្រេង ប៉ូវនិងអ៊ំស្រីហួយមានប្រពន្ធឈ្មោះស៊ាង អោ មានកូនប្រុស១នាក់ និងស្រី២នាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅអគ្គិសនីផ្សារតូច២ ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ឆបន្ទប់ធំ ១ បន្ទប់តូច៩។ ខ្មែរក្រហមសម្លាប់ ជ្រេង ផួន នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៩៣ ថ្ងៃ។

ជ័យ ពើន មានអាយុ១៩ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅជីក្រែងខេត្តសៀមរាប ជាកូនរបស់ពូ ជ័យ សើម និងមីង ងើន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៤៥០ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ជ័យពើនឬចឺពើននៅថ្ងៃទី១៨ខែមីនាឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល២៨ថ្ងៃ។

ជ័យសំអុលហៅសូមានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្ទោង ខេត្តកំពង់ធំ ជាកូនរបស់ពូ គឹម អាន និងមីង ប៉ាំង សយ មានប្រពន្ធឈ្មោះ ស៊ុន លី ហៅ ភាស់ មានកូនប្រុស ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ជ័យសំអុលនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៤០ ថ្ងៃ។ សូមមើលព័ត៌មានលម្អិតរបស់ប្រពន្ធឈ្មោះ ចេង ស៊ុនលី ។

ឈង ស្រេង យុទ្ធជនកង១៣ នៃស-២១ យ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅ ស-២១ យ ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៧៦។

ឈន ស៊ីមរុង មានអាយុ៣៦ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រែកប្ញាស ខេត្តតាកែវ ជាកូនរបស់អ៊ំ ឈនណប និងអ៊ំស្រីណៃហេត្រូវបានខ្មែរក្រហមចាប់ខ្លួននៅព្រែកហូរថ្ងៃទី២២ខែមីនា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ០៤។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងគឺនៅថ្ងៃទី៣១ខែមីនាឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឈន ស៊្រួល ហៅ ស្រ៊ន មានអាយុ៣៦ឆ្នាំក្នុងឆ្នាំ១៩៧៦មានស្រុកកំណើតនៅព្រែកប្ញាស ខេត្តតាកែវ ជាកូនរបស់អ៊ំ ឈន ណប និងអ៊ំស្រី ណៃ ហេ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅជប់ ស្រុកព្រះនេត្រព្រះ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះក០២បន្ទប់ធំលេខ៤។ ខ្មែរក្រហមបញ្ជូនឈន ស៊្រួលឬឈនស្រ៊ួនមកដល់គុកទួលស្លែងនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៦និងសម្លាប់ចោលនៅថ្ងៃទី២០ខែឧសភា ឆ្នាំ១៩៧៦បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៩៦ ថ្ងៃ។

ឈន ហ៊ិរ ហៅ វ៉ាន់ មានអាយុ២២ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកោះធំ ខេត្តកណ្តាល ជាកូនរបស់ពូ ទូច សន និងមីង ឈន ហុង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៥០២ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ឈន ហ៊ិរ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ២៨ ថ្ងៃ។

ឈាង គឹមសួរ មានអាយុ៣៦ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅជីក្រែង ខេត្តសៀមរាប ជាកូនរបស់អ៊ំ ឈាង ហ៊ាង និងអ៊ំស្រី តាន់ ណាត់ មានប្រពន្ធឈ្មោះ មាស កេតកាន់យ៉ា មានកូនប្រុស ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភូមិស្ដី ថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ កបន្ទប់ធំ ០១បន្ទប់តូច៩។ ខ្មែរក្រហមបញ្ជូនឈាង គឹមសួរ មកដល់គុកទួលស្លែងនៅថ្ងៃទី១៣ខែកុម្ភៈ ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១០៥ ថ្ងៃ។

ឈាង ថៃ ហៅ ដីណា មានអាយុ ២៦ឆ្នាំ

ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅភ្នំពេញជាកូនរបស់ពូ ឈាង ចុង និងមីង ហួត ឆាយ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភ្នំស្រុក ថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៦ ហើយ បញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៥បន្ទប់តូច ១៣។ខ្មែរក្រហមបញ្ជូនឈាងថៃមកដល់គុកទួលស្លែងនៅថ្ងៃទី១៣ខែកុម្ភៈឆ្នាំ១៩៧៦និងសម្លាប់ចោលនៅថ្ងៃទី១៨ខែឧសភាឆ្នាំ១៩៧៦បន្ទាប់ ពីជាប់ឃុំឃាំងអស់រយៈពេល៩៥ថ្ងៃ។

ឈាង ហាក់ ហៅ ថោង មានអាយុ ៤៤ឆ្នាំក្នុងឆ្នាំ១៩៧៦មានស្រុកកំណើតនៅបាភ្នំ ខេត្តព្រៃវែងជាកូនរបស់អ៊ំ ដេង ដាង និងអ៊ំស្រី តឹក មានប្រពន្ធឈ្មោះ កំចាយ ហៅ ថា មានកូនស្រី ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ០៨ បន្ទប់ធំ ១១។ អាយុ៤៤ឆ្នាំក្នុងឆ្នាំ១៩៧៥ ស្រុកកំណើតនៅបាភ្នំខេត្តព្រៃវែង ឪពុកម្តាយ ដេង ដាង និង តឹក ចាប់ខ្លួនថ្ងៃទី១៥ខែមករាឆ្នាំ១៩៧៦

ឈាវ ណា មានអាយុ១៩ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកោះធំខេត្តកណ្តាលជាកូនរបស់ពូតឹកឈាវ និងមីងប៊ុងម៉ែនយុទ្ធនារីពេទ្យត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរពេទ្យ ព-៩៨ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ គ បន្ទប់ធំ ៥។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឈាវ តិចហួរ អាយុ២០ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅបាទីខេត្តតាកែវជាកូនរបស់ពូ ឈាវ ហៀង និងមីង សួយ លុយ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅវ៉ារទេះភ្លើងពោធិ៍សាត់ ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៦ បន្ទប់តូច ៥។ ខ្មែរក្រហមសម្លាប់ ឈាវ តិចហួរ នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៦។

ឈាវម៉ុង ហៅ ឆេង មានអាយុ២០ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស៊ីធរកណ្តាល ខេត្តព្រៃវែង ជាកូនរបស់ពូអ៊ីង ឈាវ និងមីង អ៊ិត អុន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ ថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឈិក ឈក ហៅ មីរ មានអាយុ២០ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្ទោង ខេត្តកំពង់ធំ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំពត នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៧៦ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ១០ បន្ទប់លេខ៣។ ខ្មែរក្រហមបញ្ជូនឈិកឈកឬឈិត ឈតមកដល់គុកទួលស្លែងនៅថ្ងៃទី២៥ខែមិថុនា ឆ្នាំ ១៩៧៦និងសម្លាប់ចោលនៅថ្ងៃទី៥ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល១០៣ ថ្ងៃ។

ឈិត គីម លី ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅអគ្គីសនីទី២ ក្នុងឆ្នាំ១៩៧៦។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយលទៅធ្វើបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ឈិត គីម លី មានឈ្មោះថា ឈិត គីមនី ត្រូវជាប្រពន្ធរបស់ឈ្មោះ ជឹម ង៉ី ហេង ត្រូវបានខ្មែរក្រហមចាប់បញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃបន្ទាប់តែម្តង។ សូមមើលព័ត៌មានអំពី ជឹម ង៉ី ហេង នៅខាងដើម។

ឈិត គីម ឈៀង ហៅ ឡោ សារុំ មានអាយុ៣៨ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅសង្កែ ខេត្តបាត់ដំបង ជាកូនរបស់អ៊ំ យិត ស្រឡោ និងអ៊ំស្រី ឡោ ឈឿន មានប្រពន្ធឈ្មោះ យិន យ៉ុម ហៅ យ៉ាន់ មានកូនប្រុស ២នាក់និងស្រី ៥នាក់ ត្រូវបានខ្មែរក្រហម ចាប់ខ្លួននៅភូមិស្រែ ខេត្តកំពង់ធំ ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៥ បន្ទប់ធំ៨។កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ខុសគ្នា មួយនៅថ្ងៃទី៥ និងមួយទៀតនៅថ្ងៃទី១៣ខែកុម្ភៈឆ្នាំ១៩៧៦។ខ្មែរក្រហមសម្លាប់ ឈិតគីមឈៀងនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៧៦។

ឈិត ឆេង ហៅ ថាំ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅតំ

បន់៣៣ ក្នុងឆ្នាំ១៩៧៦។ កាលបរិច្ឆេទនៃការមកដល់គុកទួ-លស្លែងមាន២ខុសគ្នា មួយនៅថ្ងៃទី៦ និងមួយទៀតនៅថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ឈិត ឆេង ឬ ឈិតថេង ហៅ ថាំ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧។

ឈិត ជត មានអាយុ២០ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក១៤ តំបន់៣១ (ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង) ជាកូនរបស់ពូ ឈិត ជ័យ និងមីង យឿ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកសិកម្មតំបន់ ៣១ ថ្ងៃទី៩ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ច បន្ទប់ធំ ៥ បន្ទប់តូច ១៥។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឈិត អ៊ីវ ហៅ ឆាត មានអាយុ៤៥ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅព្រៃឈរ ខេត្តកំពង់ចាម ជាកូនរបស់អ៊ំ ឆយ និងអ៊ំស្រី សៀក មានប្រពន្ធឈ្មោះ កុយ គីឈឿន ហៅ ជឿន មានកូនប្រុស ១នាក់និងស្រី ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅសង្កាត់ទឹកឆា ថ្ងៃទី២៦ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៨ បន្ទប់តូច ១៤។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ខុសគ្នា មួយនៅថ្ងៃទី១៨ និងមួយទៀតនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ឈិតអ៊ីវនៅថ្ងៃទី៥ខែមិថុនា ឆ្នាំបន្ទាប់ពី១៩៧៦។

ឈិន ឌុន ហៅ គេង ជាយុទ្ធជនកងពល៤៥០ ត្រូវបានខ្មែរក្រហម ចាប់ខ្លួននៅកងពល៤៥០ ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមបញ្ជូន ឈិន ឌុន ឬ ឌន មកដល់គុក-ទួលស្លែងនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឈិម ធុល មានអាយុ៣២ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅភ្នំពេញ ជាកូនរបស់អ៊ំ ឈិម ឡុង និងអ៊ំស្រី ហេង យ៉េន មានប្រពន្ធឈ្មោះ ស៊ឹម ចន្ទ័នា ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅជប់ តំបន់ ៥ ថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ០១ បន្ទប់លេខ ៥។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ខុសគ្នា មួយនៅថ្ងៃទី១៣ និងមួយទៀតនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៦។ រីឯកាលបរិច្ឆេទនៃការសម្លាប់ក៏មាន២ដែរ គឺថ្ងៃទី២០ និង២១ ខែឧសភា ឆ្នាំ១៩៧៦។

ឈិត ស្រេង មានអាយុ៣០ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក ១៨ (ស្រុកកោះធំ) ខេត្តកណ្តាល ជាកូនរបស់ពូ ទូច ឈិត និងមីង ឌៀ នួន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកង១៣ ថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧។ នៅពុំទាន់មានឯកសារ បញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឈឹម ជន់ មានអាយុ៣៦ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកោះធំ ខេត្តកណ្តាល ជាកូនរបស់អ៊ំ ឈឹម ជន និងអ៊ំស្រី ញ៉ឹម ចេង មានប្រពន្ធឈ្មោះ ច្រឹង ហៃ មានកូនប្រុស ១នាក់និងស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រុកកោះធំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងបន្ទប់ធំ ០១ បន្ទប់តូច ១០។ បីយាងតាមឯកសារនាបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ឈឹម ជន់ ត្រូវបានខ្មែរក្រហមចាប់បញ្ជូនទៅដល់គុកទួលស្លែងនៅថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៧៦ ទៅវិញ។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឈឹម ដូ ឬ ឈឹម ផូ មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកោះសូទិន ខេត្តកំពង់ចាម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ ថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ១១ បន្ទប់ធំ ៥។ ខ្មែរក្រហមសម្លាប់ ឈឹម ដូ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៧០ ថ្ងៃ។

ឈឹម ដោតរី មានអាយុ២៩ឆ្នាំក្នុងឆ្នាំ១៩៧៥

មានស្រុកកំណើតនៅភ្នំពេញ ជាកូនរបស់ពូ ឈឹម យី និងមីង ឆន យ៉ន មានប្រពន្ធឈ្មោះ ហួត សុមនា ហៅ ណា មានកូនប្រុស ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រុកបាកាន ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ០៧ បន្ទប់ធំ ៧។ កាលបរិច្ឆេទ នៃការមកដល់គុកទួលស្លែងមាន៣ខុស គ្នា មួយនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៥ មួយទៀតនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងមួយទៀតនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ឈឹម ដោតរី នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៧៦។

ឈឹម ឌុក ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ឈឹម ឌុក ទៅដាល់គុកទួលស្លែងនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៦និងសម្លាប់ចោលនៅថ្ងៃទី៥ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីដាប់ឃុំឃាំងអស់រយៈពេល១៤ថ្ងៃ។

ឈឹម មឿន មានអាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅបារាយណ៍ ខេត្តកំពង់ធំ ជាកូនរបស់ពូ ឈឹម នៅ និងមីង នុត ទេស ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ឈឹម មឿន នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីដាប់ឃុំឃាំងអស់រយៈពេល ២៩ ថ្ងៃ។

ឈឹម វ៉ាន់ មានអាយុ៣៣ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅទឹកផុស ខេត្តកំពង់ឆ្នាំង ជាកូនរបស់អ៊ំ ឈឹម វ៉ន និងអ៊ំស្រី តាន់ ប៉ុង មានប្រពន្ធឈ្មោះ ស៊ីវ ហម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភូមិភាគ្គដាន់ ថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០២ បន្ទប់តូច ១២។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឈឹមស៊ីម ហៅពីន មានអាយុ២៧ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅសំរោងទង ខេត្តកំពង់ស្ពឺ ជាកូនរបស់ពូ ឈឹម ទឹម និងមីង យិន យ៉ាន់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរកងពល៣១០ ថ្ងៃទី២២ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ខ បន្ទប់ធំ ០៥ បន្ទប់តូច៤។ ខ្មែរក្រហមសម្លាប់ ឈឹម ស៊ីម ឬ ស៊ឹម នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ពីដាប់ឃុំឃាំងអស់រយៈពេល ១០៤ ថ្ងៃ។

ឈឹម សុជិត មានអាយុ៣២ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅសង្កែ ខេត្តបាត់ដំបង ជាកូនរបស់អ៊ំ ឈិម ជា និងអ៊ំស្រី សំរិទ្ធហួន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរ តាឡី ថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ឈឹម សុជិត នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ បន្ទាប់ពីដាប់ឃុំឃាំងអស់រយៈពេល ១០៩ ថ្ងៃ។

ឈឹម សំណាង មានអាយុ៤៣ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតតំណាងរាស្ត្រមណ្ឌលបឹងក្រាញ់ មានស្រុកកំណើតនៅភ្នំពេញជាកូនរបស់អ៊ំ ហុក ជ្រីវ និងអ៊ំស្រី ឈុន គោ មានប្រពន្ធឈ្មោះ ឈាវ គីមហុង មានកូនប្រុស ៦នាក់និងស្រី ៣នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រុកភ្នំស្រុក ថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០២ បន្ទប់ធំ ១។ ខ្មែរក្រហមចាប់បញ្ជូន ឈឹម សំណាង ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩-៧៦បន្ទាប់ពីដាប់ឃុំឃាំងអស់រយៈពេល ១០០ ថ្ងៃ។

ឈឹម គេក ស្រ៊ាង មានអាយុ៣២ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតវិស្វករ មានស្រុកកំណើតនៅកោះសូទិន ខេត្តកំពង់-ចាមជាកូនរបស់អ៊ំ គឹមឈាន និងអ៊ំស្រីសានយាន មានប្រពន្ធឈ្មោះ សម ណាថាលីន មានកូនប្រុស ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភូមិទ្រាំងលើ (តំបន់២២) ថ្ងៃទី២២ ខមែករាឆ្ននាំ១៩៧៦ហីយបញ្ជូនទាឃុំឃាំងនាគុកទួលស្លែងក្នុងផ្ទះ ក០២បន្ទប់លេខ ១។ខ្មែរក្រហមចាប់បញ្ជូន ឈឹម គេកស្រ៊ាងទៅដល់គុកទួលស្លែងនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ពីដាប់ឃុំឃាំងអស់រយៈពេល ៩២ ថ្ងៃ។

ឈឹម សាក់ មានអាយុ៣៨ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតវិស្វករ មានស្រុកកំណើតនៅពញាឮ ខេត្តកណ្តាល ជាកូនរបស់អ៊ំ ឈឹម ឈឺន និងអ៊ំស្រី ឡុង ខេន មានប្រពន្ធឈ្មោះ គីម ហំប៊ុន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅដប់ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ តំបន់ ៥ ថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០២ បន្ទប់លេខ ៨។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមានពាខុសគ្នា មួយនៅថ្ងៃទី៧ មួយទៀតនៅថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៦ និងមួយទៀតនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ឈឹម សាក់ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៧៦។

ឈឺ រួម ជនជាតិសៀម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅផែកំពុងសោម ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦។

ឈុ (យុ) មឿង ហៅ បួ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំពង់ចាម ក្នុងឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទ នៃការមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

ឈុន ចយ មានអាយុ២៥ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅ ខេត្តព្រៃវែង ជាកូនរបស់ពូ ឈុន វ៉ាន់ និងមីង មួក ខិន ត្រូវបានខ្មែរក្រហមចាប់ខ្លួន នៅកងពល១៧០ ថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ឈុន ចយ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៥៨ ថ្ងៃ។

ឈុន ថុលសារី ហៅ ពូ មានអាយុ៣៦ឆ្នាំ ក្នុងឆ្នាំ១៩៧៧មានស្រុកកំណើតនៅ ពាមជីលាំងខេត្តកំពង់ចាម ជាកូនរបស់អ៊ំ ប៉ក់ ឈុន និងអ៊ំស្រី យីវ បូរ មានប្រពន្ធឈ្មោះសឿមៀនហៅអោកមានកូនប្រុសពានាក់និងស្រី ១នាក់

ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅឧត្តរថ្ងៃទី១៨ខែកុម្ភៈ ឆ្នាំ១៩៧៧។ខ្មែរក្រហមសម្លាប់ឈុនថុលសារីនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៧៧។

ឈុន បួយ ហៅ ចាក់ យ៉ា ជាប្រជាជន ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ឈុន បួយ ទៅដល់គុកទួលស្លែងពីពោធិ៍ចិនតុង នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៦ ថ្ងៃ។

ឈុន ពៀច ហៅ រុំ យុទ្ធជនខាងឋាមពល ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៧៦។

ឈុន លុន ហៅ សំអាត មានអាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅល្វាឯម ខេត្តកណ្តាល ជាកូនរបស់ពូ ឈុន សូបាន និងមីង អ៊ុំ ប៊ូ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៧ បន្ទប់ធំ ៣។ ខ្មែរក្រហមសម្លាប់ ឈុន លុន នៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៩៥ ថ្ងៃ។

ឈុន សន មានអាយុ២០ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅសន្ទុក ខេត្តកំពង់ធំ ជាកូនរបស់ពូ ឈុន សៀង និងមីង ហួន សំ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកប់ស្រូវ កងពល៣១០ ក្នុងឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ឆ បន្ទប់ធំ ៤បន្ទប់តូច១៤។ខ្មែរ-ក្រហមចាប់បញ្ជូនឈុនសនទៅដល់គុកទួលស្លែងនៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៧៦ សម្លាប់ចោលនៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៥៦ ថ្ងៃ។

ឈុន សាប៊ិន មានអាយុ៣២ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រៃវែង ខេត្តព្រៃវែង ជាកូនរបស់អ៊ំ ឈុន វ៉ាន់ និងអ៊ំស្រី មោក ខិន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ២ បន្ទប់តូច ៧។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ខុសគ្នា មួយនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៦ និងមួយទៀតនៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ឈុន សាប៊ិន នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧។

ឈុន សារុន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកង

ពេល១៧០ ក្នុងឆ្នាំ១៩៧៦។កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ខុសគ្នា មួយនៅថ្ងៃទី១៩ និងមួយទៀតនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ឈុន សារុន នៅថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៦។

ឈុន សុក ហៅ ញ៉ង់វរៈសុធន់ មានអាយុ២៨ ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅត្រមុង តំបន់២១ ជាកូនរបស់ពូ ញ៉ង់ ឈុន និងមីង សរ ធីម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ ថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឈុន ហ៊ាង យុទ្ធជនកង១៣ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស-២១យក្នុងឆ្នាំ១៩៧៦។ខ្មែរក្រហមចាប់បញ្ជូន ឈុន ហ៊ាង ទៅដល់គុកទួលស្លែងនៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៦ និងសម្លាប់ចោល នៅថ្ងៃខុសៗគ្នាគឺថ្ងៃទី២, ទី៣ ខែតុលា ឆ្នាំ១៩៧៦ ឬថ្ងៃទី២ ខែតុលា ឆ្នាំ១៩៧៧។

ឈុន ហែម ហៅ ស្រស់ មានអាយុ៤៦ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើត នៅស្រែអំបិលខេត្តកោះកុង ជាកូនរបស់អ៊ំស្រី ភួយ ទទួលខុសត្រូវធ្វើស្ពានថ្នល់នៅខេត្តស្ទឹងត្រែង មានប្រពន្ធឈ្មោះ ធុល មានកូនប្រុស៥នាក់និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ឈុន ហែម នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ២២៧ ថ្ងៃ។

ឈុំ ឆាត ហៅ ឈុំ ឆាន់មានអាយុ២៥ឆ្នាំ ក្នុងឆ្នាំ១៩៧៦មានស្រុកកំណើតនៅស្រីសន្ធរ ខេត្តកំពង់ចាម ជាកូនរបស់ពូ ឈុំ និងមីង វ៉ាន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅទួលគោក ភ្នំពេញ ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំង នៅគុកទួលស្លែងក្នុងបន្ទប់ធំទី២បន្ទប់តូច១១។ ខ្មែរក្រហមចាប់បញ្ជូន ឈុំ ឆាត ទៅដល់គុកទួលស្លែងនៅថ្ងៃទី១១ខែធ្នូ ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៧០ ថ្ងៃ។

ឈុំ ឈឿន ត្រូវបានខ្មែរក្រហមចាប់ខ្លួនកងពល១៧០ ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ឈុំ ឈឿន ទៅដល់គុកទួលស្លែងនៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់ចោល នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១១ ថ្ងៃ។

ឈុំ ឈន យុទ្ធជនកង១៣ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស-២១យថ្ងៃទី៩ខែវិច្ឆិកាឆ្នាំ១៩៧៦។ខ្មែរក្រហមសម្លាប់ឈុំឈននៅថ្ងៃទី១១ខែវិច្ឆិកា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៣ថ្ងៃ។

ឈូក ចាន់ថា ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅអគ្គីសនីផ្សារតូច ថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឈូក ម៉ឺងម៉ៅ មានអាយុ៥៧ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកំពង់ត្រាច ខេត្តកំពត ជាកូនរបស់លោកតា ឈូក ម៉ឺង និងលោកយាយ អ៊ុក ហ៊ុន ភ្នាក់ងារស្ថាន-ទូតខ្មែរនៅស៊ីសមានប្រពន្ធឈ្មោះ វង ហ៊ាន មានកូនប្រុស ២នាក់និងស្រី ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅ-ភ្នំពេញថ្ងៃទី៧ខែធ្នូឆ្នាំ១៩៧៦។ ខ្មែរក្រហម ចាប់បញ្ជូនឈូកម៉ឺងម៉ៅទៅដល់គុកទួលស្លែងនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៦និងសម្លាប់ចោលនៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៨៩ថ្ងៃ។

ឈូក សយ ហៅ ផល់ មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៦មានស្រុក កំណើតនៅកំពង់សៀម ខេត្តកំពង់ចាម ជាកូនរបស់ពូ ឈូក ស៊ន និងមីង នឹម ខេន មានប្រពន្ធឈ្មោះ នាក ខឿន ហៅ ឃីម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំពង់សៀម ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ១ បន្ទប់តូច ២។ កាលបរិច្ឆេទនៃការមកដល់ គុកទួលស្លែងមាន២ខុសគ្នាមួយនៅថ្ងៃទី២០ និងមួយទៀតនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ឈូក សយ នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦។

ឈូក មួង មានអាយុ២៣ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅត្រាំកក់ខេត្តតាកែវ ជាកូនរបស់ពូ ឈូក ញ៉ៀន និងមីង ប៊ុន ប្រាង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅផ្សារពោធិ៍ចិនតុង ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០២ បន្ទប់តូច ៣។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ខុសគ្នា មួយនៅថ្ងៃទី២៧ ខែកុម្ភៈ និងមួយទៀតនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ឈូក មួង នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៧៦។

ឈួនឈនហៅភាពមានអាយុ១៨ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្ទោង ខេត្តកំពង់ធំ ជាកូនរបស់ពូ រស់ រុន និងមីង ឈាន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅ ស្រុកស្ទោង ថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៦។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ខុសគ្នា មួយនៅថ្ងៃទី១៧ និងមួយទៀតនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ឈួន ឈន នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៦។

ឈួន ឈឿន មានអាយុ៣៣ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅពញាឮ ខេត្តកណ្តាល ជាកូនរបស់អ៊ំឈួន ឈុំ និងអ៊ំស្រី កែវ បូរ មានប្រពន្ធឈ្មោះ កែវ ចាន់សាយ មានកូនស្រី ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរទេះភ្លើងភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ឆ បន្ទប់ធំ ៣ បន្ទប់តូច ១៥។ ខ្មែរក្រហមសម្លាប់ ឈួន ឈឿន នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៩៣ ថ្ងៃ។ ចំណែកឯប្រពន្ធត្រូវ បានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃជាមួយប្តី ហើយសម្លាប់ចោលនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៦។ សូមមើលព័ត៌មានបន្ថែមអំពី ចាន់ សាយ នៅខាងដើម។

ឈួន ស្រឿន ហៅ សែ មានអាយុ២៧ឆ្នាំក្នុងឆ្នាំ១៩៧៧មានស្រុកកំណើតនៅកំពង់សៀមខេត្តកំពង់ចាមជាកូនរបស់ពូឈួនម៉ននិងមីង សេន សាន មានប្រពន្ធឈ្មោះ ឆេង អាន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅលងពល៣១០ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ឃ បន្ទប់ធំ ០៣ បន្ទប់តូច ១១។ ខ្មែរក្រហមសម្លាប់ ឈួន ស្រឿន នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៧៦ ថ្ងៃ។

ឈួន សារូ មានអាយុ២៣ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស៊ីធរកណ្តាល ខេត្តព្រៃវែងជាកូនរបស់ ពូអ៊ូឈួន និងមីងឃឺ ឃីង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រតម្បាញ ត-៣ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ឈួន សារូ នៅថ្ងៃទី១៨ ខែ មីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១១៤ ថ្ងៃ។ឈួន វ៉ែន ហៅ ឈិន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ក្នុងឆ្នាំ១៩៧៦។

ឈៀង ឈីន មានអាយុ២៩ឆ្នាំក្នុងឆ្នាំ១៩៧៥ ស្រុកកំណើតនៅស្រុក១៦ ខេត្តកណ្តាល ជាកូនរបស់ពូឈៀង និងមីង ស្តើង ប៊ុ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅ៧០៣ ភ្នំពេញ ថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ១០។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទ នៃមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

ឈោន ឆត ហៅ រី មានអាយុ២០ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្ទោង ខេត្តកំពង់ធំ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅពេទ្យ ៩៨ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៧។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដែលយលទៅផ្ញើបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារកឃើញថា ឈោន ឆត ហៅ រី គឺឈ្មោះ ឈោន ធត ហៅ រី ត្រូវបានខ្មែរក្រហមចាប់ខ្លួនបញ្ជូនដល់គុកទួលស្លែងនៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៧ ហើយសម្លាប់ចោលនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១២៧ ថ្ងៃ។**(នៅមានត)**

***វ៉ាន ចាន់ពោធារ៉ា និង ឡុង ដានី***



កុមារដែលរស់នៅជំរំស្រះកែវ ប្រទេសថៃ

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 240, December 2019 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 0291 P.M/99, 2 August 1999.